**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de Droit et des Sciences Economiques

Royal University of Law and Economics

**សារណាបញ្ចប់ការសិក្សា**

# ដែនអនុវត្តន៍ក្នុងលំហ
# នៃក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ២០០៩

ស្រាវជ្រាវពីថ្ងៃទី ០៣ ខែ មេសា ដល់ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ២០១៧

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **លោក. ហោ ឈុនឡុង**

**លោកស្រី. អ៊ឹង សុផា**

សាស្ត្រាចារ្យណែនាំ

ឯកឧត្តម **លី ច័ន្ទតុលា**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ១៧

ឆ្នាំចូលសិក្សា ២០១៣

ឆ្នាំសរសេរសារណា ២០១៧

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំទាំងពីរនាក់ឈ្មោះ **ហោ ឈុនឡុង** និង **អ៊ឹង សុផា** ជានិស្សិតបរិញ្ញាបត្រ ជំនាន់ទី១៧ ឆ្នាំសិក្សា២០១៣-២០១៧ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

## សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតជូនចំពោះ

លោក **ឪពុក អ្នកម្តាយ** ជាទីគោរពរបស់កូន ដែលបានផ្តល់កំណើត និងចិញ្ចឹមបីបាច់ថែរក្សា ផ្តល់ការអប់រំគ្រប់បែបយ៉ាង ព្រមទាំងផ្គត់ផ្គង់ឱ្យកូនបានសិក្សាចាប់ពីបឋមសិក្សារហូតមកដល់ថ្នាក់ឧត្តមសិក្សានេះ។ នៅក្នុងភារៈជាអ្នកចិញ្ចឹមបីបាច់ថែរក្សាកូន លោកទាំងពីរបានលះបង់គ្រប់បែបយ៉ាងទាំងកម្លាំងកាយចិត្តមិនខ្លាចនឿយហត់ដើម្បីរកប្រាក់ចិញ្ចឹមបីបាច់ថែរក្សា ព្រមទាំងអប់រំទូន្មានឱ្យកូនខិតខំប្រឹងប្រែងសិក្សាដើម្បីក្លាយខ្លួនជាកូនល្អ សិស្សល្អ និងពលរដ្ឋនៅក្នុងសង្គម។ កូនមានថ្ងៃនេះក៏ដោយសារពាក្យទូន្មានរបស់លោកទាំងពីរ ហើយកូននឹងមិនអាចបំភ្លេចបានឡើយចំពោះគុណូបការៈដែលពុំអាចកាត់ថ្លៃបាននេះ។

ឯកឧត្តមសាកលវិទ្យាធិការ បណ្ឌិត **លុយ ចាន់ណា** សាកលវិទ្យាធិការរង ព្រឹទ្ធបុរស និង លោក លោកស្រីសាស្ត្រាចារ្យ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចទាំងអស់ ដែលបានខិតខំដឹកនាំ និងបង្ហាត់បង្រៀននិស្សិតនៅក្នុងសាកលវិទ្យាល័យ ដោយក្នុងនោះរួមទាំងយើងខ្ញុំទាំងពីរនាក់ដែរ ឱ្យទទួលបាននូវចំណេះដឹងពាក់ព័ន្ធជាមួយនឹងមុខវិជ្ជានីតិសាស្ត្រនេះ។

ឯកឧត្តមសាស្ត្រាចារ្យ **លី ច័ន្ទតុលា** ដែលបានខិតខំយកចិត្តទុកដាក់ក្នុងការបង្រៀន រហូតដល់ពេលនេះ បានខិតខំឆ្លៀតពេលវេលាដ៏មមាញឹកដើម្បីដឹកនាំយើងខ្ញុំទាំងពីរនាក់ក្នុងការសរសេរសារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រនេះដោយជោគជ័យ។

យើងខ្ញុំទាំងពីរនាក់ សូមបួងសួងដល់វត្ថុសក្តិសិទ្ធិទាំងអស់ មេត្តាជួយថែរក្សាដល់លោកទាំងអស់រួមជាមួយនឹងក្រុមគ្រួសារ បងប្អូន ឱ្យជួបតែពុទ្ធពរទាំងប្រាំប្រការគឺ **អាយុ វណ្ណៈ សុខៈ ពលៈ បដិភានៈ** កុំបីឃ្លៀងឃ្លាតឡើយ៕

# អារម្ភកថា

ការសរសេរសារណាគឺជាដំណាក់កាលមួយសម្រាប់និស្សិតថ្នាក់បរិញ្ញាបត្រ ធ្វើការបញ្ចប់ឆ្នាំសិក្សា។ ចំពោះសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចគឺមិនតម្រូវឱ្យនិស្សិតទាំងអស់សុទ្ធតែអាចសរសេរបាននោះទេ លុះត្រាតែនិស្សិតទទួលបានចំណាត់ថ្នាក់ល្អ ដែលជាលក្ខខណ្ឌកំណត់របស់សាកលវិទ្យាល័យ។ ជាភព្វសំណាង និងការខិតខំប្រឹងប្រែងចាប់តាំងពីពេលនៃការចូលរៀនដំបូង យើងខ្ញុំទាំងពីរនាក់ក៏អាចមានឱកាសក្នុងការសរសេរសារណាដើម្បីបញ្ចប់ឆ្នាំសិក្សាថ្នាក់បរិញ្ញាបត្រនេះផងដែរ។

ឆ្លងកាត់ពេលវេលាសិក្សាអស់រយៈពេល បួនឆ្នាំកន្លងមក យើងខ្ញុំទាំងពីនាក់បានទទួលចំណេះដឹងយ៉ាងទូលំទូលាយទាក់ទងជាមួយនឹងវិស័យច្បាប់ ក្រោមការបង្ហាត់បង្រៀនពីសំណាក់សាស្ត្រាចារ្យជាច្រើនរូបទៅតាមជំនាញនីមួយៗ។ ឆ្លើយតបជាមួយនឹងចំណេះដឹងដែលទទួលបាន យើងខ្ញុំទាំងពីរនាក់បានធ្វើការពិភាក្សាគ្នា ព្រមទាំងស្នើរសុំយោបល់ពីសាស្ត្រាចារ្យមួយចំនួនទៀតជាពិសេសគឺឯកឧត្តមសាស្ត្រាចារ្យ **លី ច័ន្ទតុលា** ដែលជាអ្នកដឹកនាំកិច្ចការសារណានេះ ដោយបានសម្រេចជ្រើសរើសប្រធានបទៈ **ដែនអនុវត្តន៍ក្នុងលំហនៃក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ២០០៩** ដើម្បីទុកជាស្នាដៃ និងឯកសារស្រាវជ្រាវសម្រាប់ប្អូនៗជំនាន់ក្រោយ និងអ្នកសិក្សាស្រាវជ្រាវអាចយកទៅធ្វើជាប្រភពឯកសារដើម្បីស្រាវជ្រាវបន្ត។

ចំពោះប្រធានបទនេះគឺមានឯកសារទាក់ទងជាច្រើនដែលយើងខ្ញុំទាំងពីរនាក់រកបាន ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ យើងខ្ញុំគិតថាឯកសារទាំងនោះអាចនឹងមិនគ្រប់គ្រាន់ចំពោះខ្លឹមសារនៃប្រធានបទបាននោះទេ ហេតុដូច្នេះហើយយើងខ្ញុំសូមធ្វើការអធ្យាស្រ័យទុកជាមុនចំពោះកង្វះខាតខ្លឹមសារ ឬកំហុសឆ្គងអក្ខរាវិរុទ្ធដោយអចេតនាណាមួយ។

យើងខ្ញុំមានសង្ឃឹមយ៉ាងមុតមាំថាសារណានេះនឹងក្លាយទៅជាវិភាគទានដ៏មានតម្លៃសម្រាប់មិត្តអ្នកអាន និងជាពិសេសប្អូនជំនាន់ក្រោយ ដើម្បីយកធ្វើជាប្រភពសម្រាប់ចងក្រងនូវប្រធានបទផ្សេងៗទៀតដែលទាក់ទងគ្នា៕

# មាតិកា

ទំព័រ

**សេចក្តីផ្តើម** ........ ១

**ជំពូកទី១៖ បទល្មើសដែលប្រព្រឹត្តនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា** ........ ៥

១.១ បទល្មើសដែលប្រព្រឹត្តនៅកម្ពុជា ........ ៥

១.១.១ ការអនុវត្តច្បាប់ព្រហ្មទណ្ឌចំពោះបទល្មើសដែលប្រព្រឹត្តនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ........ ៥

១.១.២ ការអនុវត្តច្បាប់ព្រហ្មទណ្ឌចំពោះទីតាំងទូត ឬកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជា . ៨

១.១.៣ ការមិនអនុវត្តច្បាប់ព្រហ្មទណ្ឌនៅលើដែនដីកម្ពុជាតាមកិច្ចព្រមព្រៀងអន្តរជាតិ ..... ៩

១.២ បទល្មើសដែលចាត់ទុកថាបានប្រព្រឹត្តនៅកម្ពុជា ........ ១១

១.២.១ បទល្មើសដែលប្រព្រឹត្តក្នុងនាវាសញ្ជាតិកម្ពុជា ........ ១២

១.២.២ បទល្មើសដែលប្រព្រឹត្តក្នុងអាកាសយានកម្ពុជា ........ ១៥

១.២.៣ បទល្មើសដែលប្រព្រឹត្តក្នុងនាវាបរទេស ........ ១៨

**ជំពូកទី២៖ បទល្មើសដែលប្រព្រឹត្តក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា** ........ ១៩

២.១ ការអនុវត្តច្បាប់ព្រហ្មទណ្ឌកម្ពុជាតាមគោលការណ៍សញ្ជាតិ ........ ២០

២.១.១ បទល្មើសដែលមានជនល្មើសជាពលរដ្ឋខ្មែរ ........ ២០

២.១.១.១ ករណីបទឧក្រិដ្ឋ ........ ២១

២.១.១.២ ករណីបទមជ្ឈិម ........ ២១

២.១.២ បទល្មើសដែលមានជនរងគ្រោះជាពលរដ្ឋខ្មែរ ........ ២២

២.១.២.១ ករណីបទឧក្រិដ្ឋ ........ ២២

២.១.៣ លក្ខខណ្ឌនៃការចោទប្រកាន់ ........ ២៣

២.២ បទល្មើសដែលប្រឆាំងនឹងកម្ពុជា ........ ២៣

២.២.១ បទល្មើសដែលប្រឆាំងនឹងសុវត្ថិភាពនៃព្រះរាជាណាចក្រកម្ពុជា ........ ២៣

២.២.២ បទល្មើសក្លែងត្រាផ្លូវការនៃព្រះរាជាណាចក្រកម្ពុជា ........................................ ២៤

២.២.៣ បទល្មើសក្លែងរូបិយវត្ថុ និងធនបត្រជាតិ ដែលមានតម្លៃស្របច្បាប់នៅកម្ពុជា ..... ២៥

២.២.៤ បទល្មើសប្រឆាំងភ្នាក់ងារទូត ឬកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជា ................. ២៧

២.២.៥ បទល្មើសប្រឆាំងនឹងទីតាំងទូត ឬកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជា................ ២៨

**សេចក្តីសន្និដ្ឋាន**............................................................................................................ ២៩

**អនុសាសន៍**.................................................................................................................. ៣១

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

## ១ លំនាំបញ្ហានៃការស្រាវជ្រាវ

ក្រមព្រហ្មទណ្ឌ គឺជាបណ្តុំរាល់បទប្បញ្ញត្តិព្រហ្មទណ្ឌទាំងឡាយ ក្នុងនោះបទប្បញ្ញត្តិមួយផ្នែកចែងអំពីគោលការណ៍គ្រឹះ និងវិធានរួមនៅក្នុងនីតិព្រហ្មទណ្ឌសម្រាប់ចៅក្រមយកទៅអនុវត្តក្នុងការផ្តល់យុត្តិធម៌ក្នុងរឿងព្រហ្មទណ្ឌ និងបទប្បញ្ញត្តិមួយផ្នែកទៀត ចែងអំពីបទល្មើសព្រហ្មទណ្ឌដែលត្រូវផ្តន្ទាទោស។

ក្រមព្រហ្មទណ្ឌមានចរិត និងគោលដៅចម្បងបម្រើឱ្យប្រយោជន៍សាធារណៈ តាមរយៈការធានារក្សាការពារសណ្តាប់ធ្នាប់សាធារណៈ សន្តិសុខសង្គម សិទ្ធិសេរីភាពបុគ្គល សេចក្តីថ្លៃថ្នូរ និងភាពសុខសាន្តជូនប្រជាជន។

ដោយឃើញពីសារៈសំខាន់នៃក្រមព្រហ្មទណ្ឌ និងដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការចាំបាច់ចំពោះមុខ ក្នុងការប្រយុទ្ធប្រឆាំងទម្រង់ថ្មីនៃបទល្មើស ព្រមទាំងឧក្រិដ្ឋសម័យទំនើបផ្សេងៗប្រកបដោយប្រសិទ្ធភាព និងមានលក្ខណៈគ្រប់ជ្រុងជ្រោយ ក្នុងគោលដៅធានាការពារឱ្យបាននូវសិទ្ធិសេរីភាព សេចក្តីថ្លៃថ្នូរ សន្តិសុខសង្គម និងសណ្តាប់ធ្នាប់សាធារណៈជូនប្រជាជន ទើបរាជរដ្ឋាភិបាលបានផ្តោតការយកចិត្តទុកដាក់ខ្ពស់លើកិច្ចការនេះ និងបានចាត់ទុកការជម្រុញអនុម័តក្រមព្រហ្មទណ្ឌ គឺជារបៀបវារៈអាទិភាពមួយនៃកម្មវិធីកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌របស់ខ្លួន។ រាជរដ្ឋាភិបាលតាមរយៈក្រសួងយុត្តិធម៌ ក៏បានស្នើសុំឱ្យមានកិច្ចសហប្រតិបត្តិការពីរដ្ឋាភិបាលនៃសាធារណរដ្ឋបារាំង ដើម្បីរៀបចំតាក់តែងសេចក្តីព្រាងច្បាប់ស្តីពី "**ក្រមព្រហ្មទណ្ឌ**" នេះឡើង។

នៅក្នុងឆ្នាំ២០០១ សេចក្តីព្រាងក្រមព្រហ្មទណ្ឌដើមដំបូង ជាភាសាខ្មែរត្រូវបានរៀបចំឡើង និងបានប្រគល់ដល់ក្រសួងយុត្តិធម៌ដើម្បីធ្វើការពិនិត្យ និងកែសម្រួលបន្ថែមដើម្បីឱ្យក្រមនេះមានលក្ខណៈសមស្រប និងអាចយកមកអនុវត្តបាន នៅក្នុងសង្គមកម្ពុជា ធានាបាននូវប្រសិទ្ធិភាព និងសង្គតិភាព ភាពរលូន និងស៊ីចង្វាក់គ្នាជាមួយនឹងប្រពៃណីច្បាប់កម្ពុជា និងបទដ្ឋានគតិយុត្តដែលមានស្រាប់។

ដើម្បីធានាសង្គតិភាព ភាពរលូន និងនិរន្តភាពរវាងច្បាប់ព្រហ្មទណ្ឌចាស់ និងច្បាប់ព្រហ្មទណ្ឌថ្មី ក្រមនេះក៏ត្រូវបានតាក់តែងដោយគោរពគំនិតសំខាន់ៗដែលមានចែងក្នុងក្រមព្រហ្មទណ្ឌចាស់ និងក្នុងប្រព័ន្ធច្បាប់រ៉ូម៉ាំង-អាល្លឺម៉ង់ ដែលជាប្រពៃណីនៃច្បាប់ព្រហ្មទណ្ឌកម្ពុជា។ ម្យ៉ាងទៀតដើម្បីបំពេញបន្ថែមចន្លោះខ្វះខាតនៃច្បាប់ និងបទប្បញ្ញត្តិព្រហ្មទណ្ឌដទៃទៀត ដែលកំពុងនៅជាធរមាននាពេលនោះ ក្រមព្រហ្មទណ្ឌក៏បានចែងអំពីបទល្មើសបន្ថែមផ្សេងទៀតដែលចាំបាច់ ដើម្បី

អនុញ្ញាតឱ្យប្រព័ន្ធបង្ក្រាបអាចប្រយុទ្ធប្រឆាំងប្រកបដោយប្រសិទ្ធិភាព និងគ្រប់ជ្រុងជ្រោយទៅនឹងទម្រង់ថ្មីៗនៃបទល្មើសក្នុងសង្គម និងឧក្រិដ្ឋកម្មសម័យទំនើបផ្សេងៗ។

ក្រោមកិច្ចខិតខំប្រឹងប្រែងចងក្រងអស់រយៈពេលជាង ១០ឆ្នាំរបស់ក្រសួងយុត្តិធម៌ និងដោយមានការជួយគាំទ្រពីភាគីបារាំងផងដែរនោះ ជាលទ្ធផលក្រមព្រហ្មទណ្ឌត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជាធ្វើការអនុម័ត នៅថ្ងៃទី ១២ ខែ តុលា ឆ្នាំ២០០៩ និងដោយព្រឹទ្ធសភា នៅថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ២០០៩ ហើយត្រូវបានប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/១១០៩/០២២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ២០០៩។ បន្ទាប់ពីចូលជាធរមាន ក្រមនេះគឺមិនទាន់ត្រូវបានដាក់ឱ្យអនុវត្តទាំងស្រុងនោះឡើយ មាត្រា ៦៧២ បានចែងថា "**លើកលែងតែបញ្ញត្តិទូទៅនៃគន្ថីទី១ (បទប្បញ្ញត្តិទូទៅ) នៃក្រមនេះ ដែលត្រូវយកទៅអនុវត្តភ្លាមក្រោយការចូលជាធរមាននៃក្រមនេះ បទប្បញ្ញត្តិដទៃទៀតត្រូវយកទៅអនុវត្តក្នុងរយៈពេលមួយឆ្នាំក្រោយការចូលជាធរមាននៃក្រមនេះ**"។ មានន័យថាបើទោះបីជាក្រមនេះបានចូលជាធរមាននៅក្នុងឆ្នាំ២០០៩ ក៏ដោយ ប៉ុន្តែការអនុវត្តគឺមិនទាន់បានពេញលេញនោះទេ គឺអនុវត្តន៍ត្រឹមតែបទប្បញ្ញត្តិទូទៅនៃគន្ថីទី១ តែប៉ុណ្ណោះ។ យើងរងចាំរហូតដល់ថ្ងៃទី ២០ ខែធ្នូ ឆ្នាំ២០១០ ទើបបទប្បញ្ញត្តិទាំងអស់នៅក្នុងក្រមនេះត្រូវបានដាក់ឱ្យអនុវត្ត។ ការធ្វើបែបនេះគឺដោយសារតែស្មារតីនៃអ្នកដែលបានតាក់តែងក្រមនេះយល់ឃើញថា ដើម្បីទុកពេលវេលាសម្រាប់ធ្វើការផ្សព្វផ្សាយទៅដល់ប្រជាពលរដ្ឋឱ្យមានការជ្រួតជ្រាប និងចូលរួមក្នុងការអនុវត្តឱ្យបានទាំងអស់គ្នា។

ដោយសារតែក្រមព្រហ្មទណ្ឌ ជាអត្ថបទច្បាប់ដែលប្រមូលផ្តុំនូវរាល់បទប្បញ្ញត្តិព្រហ្មទណ្ឌ ដោយមានការរៀបចំបែងចែកជារចនាសម្ព័ន្ធត្រឹមត្រូវ ព្រមទាំងបំពេញបន្ថែមនូវអ្វីដែលខ្វះចន្លោះនោះ បានធ្វើឱ្យក្រមនេះ ក្លាយជាឧបករណ៍គតិយុត្តមួយដ៏មានសារៈសំខាន់ ដែលមិនត្រឹមតែជួយឱ្យចៅក្រម ព្រះរាជអាជ្ញា និងមន្ត្រីអនុវត្តផ្សេងទៀត មានភាពងាយស្រួលក្នុងការប្រើប្រាស់ និងស្វែងយល់ឱ្យបានពេញលេញ និងគ្រប់ជ្រុងជ្រោងក្នុងវិស័យព្រហ្មទណ្ឌប៉ុណ្ណោះទេ ថែមទាំងអាចជួយអនុញ្ញាតឱ្យប្រជាជនយល់ដឹងរឹតតែច្បាស់អំពីសិទ្ធិ និងព្រំដែននៃការអនុវត្តសិទ្ធិរបស់ខ្លួនជាពិសេសយល់ដឹងអំពីអំពើដែលត្រូវបានហាមឃាត់ និងផ្តន្ទាទោសជាបទល្មើសព្រហ្មទណ្ឌ។

## ២ ចំណោទបញ្ហានៃការស្រាវជ្រាវ

ជាទូទៅបទដ្ឋានគតិយុត្តនីមួយៗសុទ្ធតែបានកំណត់នូវដែននៃការអនុវត្ត។ ក្រមព្រហ្មណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ ក៏មានវិសាលភាពអនុវត្តមិនខុសពីអត្ថបទច្បាប់ដែលព្រះរាជាណាចក្រកម្ពុជាមានពីមុន និងអត្ថបទច្បាប់របស់បណ្តារដ្ឋដទៃទៀតដែរ។ ចាប់ពីមាត្រា៩ ដល់មាត្រា ២៣ នៃក្រមនេះ គឺបានកំណត់អំពីដែនអនុវត្តន៍ ដោយក្នុងនោះគឺបានធ្វើការបែងចែកជាពីរផ្នែកគឺ **ការអនុវត្តច្បាប់ព្រហ្មទណ្ឌនៅក្នុងពេលវេលា** និង**ការអនុវត្តច្បាប់ព្រហ្មទណ្ឌនៅក្នុងលំហ**។ ទោះបីជា

មានបទប្បញ្ញត្តិចែងច្បាស់អំពីវិសាលភាពនៃការអនុវត្តក្រមនេះក៏ដោយ យើងនៅតែមើលឃើញអំពីបញ្ហាមួយចំនួន ដែលកើតមានឡើងចំពោះការអនុវត្តផ្ទាល់ផងដែរ។

ដោយសារតែបទប្បញ្ញត្តិដែលចែងអំពីវិសាលភាពនៃការអនុវត្តនៅក្នុងក្រមនេះ ចែងតែអំពីចំណុចគោលធំៗប៉ុណ្ណោះ ដែលជាហេតុនាំឱ្យអ្នកសិក្សា និងអ្នកអនុវត្តមួយចំនួននៅមិនទាន់មានភាពច្បាស់លាស់អំពីការអនុវត្ត ដោយចំណុចលម្អិតផ្សេងនៃការអនុវត្តគឺស្ថិតនៅក្នុងអត្ថបទច្បាប់ជាតិជាច្រើនដែលកំណត់អំពីការអនុវត្ត រួមទាំងកិច្ចព្រមព្រៀងអន្តរជាតិផ្សេងទៀត ដែលមានដូចជា សន្ធិសញ្ញា អនុសញ្ញា ឬកាតិកាសញ្ញាជាដើម។

ក្នុងនាមជាភាគីហត្ថលេខីនៅក្នុងកិច្ចព្រមព្រៀងអន្តរជាតិផ្សេងៗ ដែលចែងពាក់ព័ន្ធជាមួយនឹងការអនុវត្តច្បាប់ព្រហ្មទណ្ឌ យើងឃើញថានៅមានភាពស្មុគស្មាញនៅឡើយសម្រាប់ការយកក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ២០០៩ នេះ ទៅអនុវត្តណាស់ ជាពិសេសចំពោះបទល្មើសព្រហ្មទណ្ឌដែលមានការលាយបញ្ចូលគ្នាជាមួយធាតុផ្សំបរទេស។

ដោយសារតែមានភាពស្មុគស្មាញសម្រាប់ការអនុវត្តក្រមព្រហ្មទណ្ឌនេះហើយ ទើបបានជាលេចចេញសំនួរចោទឡើងថា៖ **តើច្បាប់ព្រហ្មទណ្ឌកម្ពុជាមានវិសាលភាពអនុវត្តចំពោះករណីទាំងអស់ដែលពាក់ព័ន្ធជាមួយនឹងកម្ពុជា ឬយ៉ាងណា?**

## ៣ គោលបំណងនៃការស្រាវជ្រាវ

ការស្រាវជ្រាវនេះគឺគោលបំណងដើម្បីរកអំពីចំណុចលម្អិតនីមួយៗ ចំពោះបទប្បញ្ញត្តិដែលចែងអំពីវិសាលភាពនៃដែនអនុវត្តក្រមព្រហ្មទណ្ឌកម្ពុជា និងជាពិសេសចំពោះបទល្មើសដែលបានកើតឡើងទាក់ទងជាមួយនឹងទីកន្លែងប្រព្រឹត្តបទល្មើស ឬក៏អ្នកដែលចូលរួមពាក់ព័ន្ធក្នុងបទល្មើស។

## ៤ ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

បទប្បញ្ញត្តិនៅក្នុងក្រមនេះបានធ្វើការបែងចែកវិសាលភាពនៃការអនុវត្តក្រមព្រហ្មទណ្ឌ ជាពីរដោយក្នុងនោះមានការអនុវត្តច្បាប់ព្រហ្មទណ្ឌក្នុងពេលវេលា និងការអនុវត្តច្បាប់ព្រហ្មទណ្ឌក្នុងលំហ ប៉ុន្តែទំហំនៃកិច្ចការស្រាវជ្រាវនេះ គឺលើកយកតែអំពីការអនុវត្តច្បាប់ព្រហ្មទណ្ឌក្នុងលំហាមកពន្យល់តែប៉ុណ្ណោះ មូលហេតុក៏ព្រោះតែការអនុវត្តច្បាប់ព្រហ្មទណ្ឌក្នុងពេលវេលាគឺមិនមែនជាបញ្ហាចោទសម្រាប់កម្ពុជាទៀតទេ ដោយសារតែក្រមនេះបានចូលជាធរមាន និងដាក់ឱ្យអនុវត្តជិត ១០ឆ្នាំកន្លងមកហើយ និងមូលហេតុមួយទៀត ដោយសារតែគោលការណ៍គ្រឹះនៃការអនុវត្តច្បាប់សម្រាប់ប្រទេសប្រជាធិបតេយ្យ គឺចាប់ផ្តើមនៅពេលដែលច្បាប់នោះបានចូលជាធរមានតែប៉ុណ្ណោះ។

## ៥ វិធីសាស្ត្រស្រាវជ្រាវ

សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រនេះ គឺធ្វើស្របទៅតាមគោលការណ៍ស្ដីពីការបណ្ដុះបណ្ដាល ដែលសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចកំណត់។ ការចងក្រងសារណានេះធ្វើឡើងតាមរយៈវិធីសាស្ត្របែបពិពណ៌នាផង និងបែបពន្យល់ផង ដែលអាចធ្វើឱ្យអ្នកអានមានភាពងាយស្រួលក្នុងការយល់ ហើយចំពោះឯកសារវិញទៀតសោត គឺមានការពាក់ព័ន្ធជាមួយនឹងបទដ្ឋានគតិយុត្តទាំងជាតិ និងអន្តរជាតិ ដែលមានទំនាក់ទំនងនឹងគ្នា ព្រមទាំងអត្ថបទសារព័ត៌មានដែលឆ្លុះបញ្ចាំងអំពីការអនុវត្តក្រមព្រហ្មទណ្ឌកម្ពុជាផ្ទាល់។

## ៦ សារប្រយោជន៍នៃការស្រាវជ្រាវ

ប្រធានបទស្ដីពី "**ដែនអនុវត្តន៍ក្នុងលំហនៃក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ២០០៩**" គឺមានសារៈសំខាន់សម្រាប់ជាប្រយោជន៍ក្នុងការស្វែងយល់ឱ្យបានកាន់តែលម្អិតពីវិសាលភាព នៃការអនុវត្តក្រមព្រហ្មទណ្ឌកម្ពុជា ចំពោះបទល្មើសដែលបានកើតឡើង ព្រមទាំងដោយមានការពាក់ព័ន្ធជាមួយនឹងប្រជាពលរដ្ឋកម្ពុជា ឬផលប្រយោជន៍របស់កម្ពុជា និងក៏ជាផ្នែកក្នុងការពង្រឹងនីតិរដ្ឋនៅកម្ពុជា។ លើសពីនេះ ការសិក្សាស្រាវជ្រាវក៏មានគោលបំណងឱ្យអ្នកអានបានយល់អំពីគោលការណ៍នានាដែលបានកំណត់ទាំងនៅក្នុងក្រមនេះក្ដី ឬក៏ច្បាប់ផ្សេងទៀតដែលមានទំនាក់ទំនងក្នុងការអនុវត្ត។

## ៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

សារណាបទនេះរៀបចំឡើងជាភាសាខ្មែរ ដែលចែកចេញជា ២ជំពូកធំៗ ហើយនៅក្នុងជំពូកនីមួយៗ បែងចែកជាចំណុចតូចៗជាច្រើនទៀត និងមានចំនួន ៣១ទំព័រ ព្រមជាមួយនឹងឯកសារឧបសម្ព័ន្ធមួយចំនួនទៀត។

ជំពូកទី១ គឺនិយាយអំពីបទល្មើសព្រហ្មទណ្ឌ ដែលកើតមានឡើងក្នុងវង្វង់ដែនដីកម្ពុជា ឬក៏ទីកន្លែងមួយចំនួនទៀតដែលចាត់ទុកថាជាដែនដីកម្ពុជា។ ជំពូកទី២ គឺនិយាយអំពីបទល្មើសព្រហ្មទណ្ឌទាំងឡាយដែលកើតឡើងនៅក្រៅដែនដីកម្ពុជា ប៉ុន្តែមានការពាក់ព័ន្ធជាមួយនឹងពលរដ្ឋកម្ពុជា ឬក៏ប៉ះពាល់ដល់ផលប្រយោជន៍កម្ពុជា។ ចំណុចចុងក្រោយគឺជាការសន្និដ្ឋានចំពោះខ្លឹមសារនៅក្នុងសារណានេះ ព្រមទាំងមានអនុសាសន៍មួយចំនួន ដើម្បីឱ្យការអនុវត្តច្បាប់ព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាកាន់តែមានមានប្រសិទ្ធភាព និងវិសាលភាពធំទូលាយ។ ជាជំនួយស្មារតីនៅក្នុងសារណានេះក៏មានការដាក់បញ្ចូលឯកសារ ក៏ដូចជាអត្ថបទព័ត៌មានមួយចំនួនដែលឆ្លុះបញ្ចាំងពីការអនុវត្តក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ នេះផ្ទាល់ផងដែរ៕

# ជំពូកទី១៖ បទល្មើសដែលប្រព្រឹត្តនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា

ការអនុវត្តច្បាប់ព្រហ្មទណ្ឌគឺមានដែនកម្រិត។ នៅពេលដែលគេចង់ដឹងថា តើគួរយកច្បាប់ព្រហ្មទណ្ឌណាមួយទៅអនុវត្តចំពោះបទល្មើសដែលបានកើតឡើង គឺគេត្រូវសិក្សាទៅលើករណីពីរ ទីមួយ គឺទីកន្លែងនៃបទល្មើសដែលបានកើតឡើង និងទីពីរ គឺសញ្ជាតិនៃអ្នកដែលបានចូលរួមពាក់ព័ន្ធក្នុងបទល្មើសនោះ។

## ១.១ បទល្មើសដែលប្រព្រឹត្តនៅកម្ពុជា

ក្នុងរឿងព្រហ្មទណ្ឌ ច្បាប់ព្រហ្មទណ្ឌកម្ពុជាត្រូវអនុវត្តទៅលើបទល្មើសទាំងឡាយដែលបានប្រព្រឹត្តនៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា។ ដែនដីនៃព្រះរាជាណាចក្រកម្ពុជា រួមបញ្ចូលទាំងលំហអាកាស និងសមុទ្រ ដែលមានចំណងភ្ជាប់នឹងដែនដីនៃព្រះរាជាណាចក្រកម្ពុជា[១]។

ដូចមានចែងក្នុងរដ្ឋធម្មនុញ្ញដែលជាច្បាប់កំពូល ទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានកំណត់ក្នុងផែនទីខ្នាត ១/១០០០០០ (មួយលើមួយរយពាន់) ធ្វើនៅចន្លោះឆ្នាំ១៩៣៣-១៩៥៣ ហើយដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិនៅចន្លោះឆ្នាំ១៩៦៣-១៩៦៩[២]។

### ១.១.១ ការអនុវត្តច្បាប់ព្រហ្មទណ្ឌចំពោះបទល្មើសដែលប្រព្រឹត្តនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា

គោលការណ៍ដែនដីនៃការអនុវត្តច្បាប់ព្រហ្មទណ្ឌ វាគឺជាគោលការណ៍គ្រឹះដែលគ្រប់បណ្ដារដ្ឋទាំងអស់ទូទាំងសកលលោក យកទៅអនុវត្តចំពោះច្បាប់របស់ខ្លួន។ សម្រាប់កម្ពុជា យោងតាមមាត្រា ១២ នៃក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ២០០៩ គឺបានផ្តល់សមត្ថកិច្ចទៅដល់តុលាការ មានសិទ្ធិអនុវត្តច្បាប់ព្រហ្មទណ្ឌចំពោះគ្រប់បទល្មើសទាំងអស់ ដែលបានប្រព្រឹត្តនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា។ ការអនុវត្តនេះគឺមិនសំដៅតែលើពលរដ្ឋកម្ពុជានោះទេ សូម្បីតែពលរដ្ឋបរទេសដែលបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ទៅលើពលរដ្ឋបរទេសដទៃទៀតនៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជាក៏យុត្តាធិការកម្ពុជាមានសមត្ថកិច្ចលើបទល្មើសនោះដែរ។ ឧទាហរណ៍៖ ពលរដ្ឋថៃម្នាក់បានប្រើអំពើហិង្សាលើពលរដ្ឋវៀតណាមណាម្នាក់ បណ្ដាលឱ្យរងរបួសនៅរាជធានីភ្នំពេញ ដូច្នេះសាលាដំបូងរាជធានីភ្នំពេញគឺមានសមត្ថកិច្ចជំនុំជម្រះលើករណីនេះ។

ដោយសារតែដែនដីនេះ គឺមិនសំដៅតែចំពោះតែដែនដីគោកប៉ុណ្ណោះទេ គឺរាប់បញ្ចូលទាំងដែនសមុទ្រ និងលំហអាកាស ដែលមានចំណងភ្ជាប់ជាមួយទៅនឹងដែនដីដែលបានកំណត់នៅក្នុង

(១) មាត្រា ១២ កថាខណ្ឌទី១ នៃក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ២០០៩
(២) មាត្រា ២ នៃរដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣

រដ្ឋធម្មនុញ្ញដែរ។ សម្រាប់កម្ពុជាគឺមិនទាន់មានច្បាប់ណាមួយដែលកំណត់អំពីដែនសមុទ្ររបស់ខ្លួននៅឡើយទេ គឺមានតែកិច្ចព្រមព្រៀងមួយចំនួនដែលធ្វើជាមួយប្រទេសមានដែនសមុទ្រជាប់គ្នាតែប៉ុណ្ណោះ ប៉ុន្តែកិច្ចព្រមព្រៀងនេះក៏ត្រូវអនុលោមទៅតាមអនុសញ្ញាស្តីពីនីតិសមុទ្រដែរ។

ចំពោះសមុទ្រ ដែលមានចំណងភ្ជាប់ជាមួយនឹងដែនដីនៃព្រះរាជាណាចក្រកម្ពុជា យោងតាមអនុសញ្ញារបស់អង្គការសហប្រជាជាតិ ឆ្នាំ១៩៨២ ស្តីពីនីតិសមុទ្រ បានបែងចែកដែនទឹកជាប្រភេទដូចជា៖

- **តំបន់សមុទ្រខាងក្នុង ឬតំបន់ផ្ទៃទឹកក្នុង**ដែលស្ថិតក្នុងខ្សែបន្ទាត់មូលដ្ឋាន[៣] ដែនទឹកផ្ទៃក្នុងមានឋានៈដូចដីគោកដែរ ដែលរដ្ឋឆ្នេរសមុទ្រមានសិទ្ធិ និងអធិបតេយ្យភាពទាំងស្រុងលើការគ្រប់គ្រងដែនទឹកនេះ។ នាវាបរទេសគឺមិនអាចធ្វើការឆ្លងកាត់ដែនទឹកផ្ទៃក្នុងនេះបានឡើយ ប្រសិនបើមិនមានការអនុញ្ញាតពីរដ្ឋឆ្នេរសមុទ្រ បន្ថែមពីនោះរដ្ឋឆ្នេរសមុទ្រ អាចប្រើប្រាស់យុត្តាធិការបានទាំងពីរ លើករណីរដ្ឋប្បវេណី និងព្រហ្មទណ្ឌ។ ឧទាហរណ៍៖ ករណីឃាតកម្មបានកើតឡើងលើនាវាបរទេសមួយ ដែលកំពុងចតនៅកំពង់ផែស្វយ័តខេត្តព្រះសីហនុរបស់កម្ពុជា។ ក្នុងករណីនេះ អាជ្ញាធរកម្ពុជាអាចឃាត់នាវា ឡើងលើនាវា ឃាត់មនុស្សលើនាវា និងនាំខ្លួនទៅតុលាការ។
- **សមុទ្រដែនដី** ជាតំបន់សមុទ្រមួយស្ថិតនៅជាប់ដីគោក និងដែនទឹកផ្ទៃក្នុង និងមានចម្ងាយ ១២ ម៉ៃល៍សមុទ្រ (២២ គ.ម) វាស់ចេញពីបន្ទាត់មូលដ្ឋាន។ នៅក្នុងតំបន់នេះ រដ្ឋឆ្នេរសមុទ្រមានអធិបតេយ្យភាពលើដែនទឹក លំហអាកាស បាតសមុទ្រ និងដីក្រោមបាតសមុទ្រ។ ការឆ្លងកាត់របស់នាវាបរទេសក្នុងតំបន់នេះមានកម្រិត ហើយការហោះហើរលើសមុទ្រដែនដីត្រូវសុំការអនុញ្ញាតពីរដ្ឋឆ្នេរសមុទ្រ[៤]។ យោងតាមមាត្រា ២៤ នៃអនុសញ្ញាស្តីពីនីតិសមុទ្រ[៥] ក៏បានកំណត់ថារដ្ឋឆ្នេរសមុទ្រ មិនអាចធ្វើការបដិសេធលើការឆ្លងកាត់របស់នាវាបរទេសក្នុងករណីការឆ្លងកាត់មិនបំពានបានឡើយ យោងតាមមាត្រានេះយើងអាចធ្វើការសន្និដ្ឋានបានថាច្បាប់ព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាមិនអាចយកទៅអនុវត្ត ចំពោះគ្រប់បទល្មើសដែលបានកើតឡើងនៅលើនាវាបរទេស ដែលឆ្លងកាត់រដ្ឋនេះបានឡើយ លើកលែងតែករណីដូចជាការឆ្លងកាត់នោះជាសកម្មភាព ដែលបង្ករជាគ្រោះថ្នាក់ និងត្រូវបានហាមឃាត់គឺ៖

(៣) មាត្រា ៨ នៃអនុសញ្ញាអន្តរជាតិស្តីពីនីតិសមុទ្រ

(៤) មាត្រា ២-៣ នៃអនុសញ្ញាអន្តរជាតិស្តីពីនីតិសមុទ្រ

(៥) មាត្រា ២៤ នៃអនុសញ្ញាអន្តរជាតិស្តីពីនីតិសមុទ្រ៖ រដ្ឋឆ្នេរសមុទ្រមិនត្រូវបដិសេធ ឬរារាំងការឆ្លងកាត់មិនបំពាននៃនាវាបរទេសក្នុងសមុទ្រដែនដី។ រដ្ឋឆ្នេរសមុទ្រត្រូវប្រកាសជាសាធារណៈឱ្យបានត្រឹមត្រូវ អំពីគ្រោះថ្នាក់ណាមួយដល់នាវាចរណ៍ ក្នុងសមុទ្រដែនដីរបស់ខ្លួន។

- ការគំរាមកំហែង និងការប្រើប្រាស់កម្លាំងដើម្បីប្រឆាំងនឹងអធិបតេយ្យភាព បូរណភាពទឹកដី ឯករាជ្យភាពនយោបាយរបស់រដ្ឋឆ្នេរសមុទ្រ ឬសកម្មភាពផ្សេងទៀត ដែលរំលោភគោលការណ៍ច្បាប់អន្តរជាតិ ចែងក្នុងរដ្ឋធម្មនុញ្ញអង្គការសហប្រជាជាតិ
- សមយុទ្ធយោធា ឬការប្រើប្រាស់សព្វាវុធគ្រប់ប្រភេទ
- សកម្មភាពឃោសនា ក្នុងគោលបំណងធ្វើឱ្យប៉ះពាល់ដល់វិស័យការពារជាតិ ឬអសន្តិសុខរបស់រដ្ឋឆ្នេរសមុទ្រ
- ការហោះឡើង ឬចុះចតលើនាវា រួមទាំងយោធយាន
- ផ្ទុក និងផ្ទេរទំនិញពាណិជ្ជកម្ម រូបិយវត្ថុ ឬមនុស្សដែលផ្ទុយពីច្បាប់ និងបទប្បញ្ញត្តិស្ដីពីពន្ធគយ ពន្ធដារ អន្តោប្រវេសន៍ ឬសុខាភិបាលរបស់រដ្ឋឆ្នេរសមុទ្រ
- សកម្មភាពបំពុលបរិស្ថានដោយចេតនា និងធ្ងន់ធ្ងរដែលផ្ទុយពីអនុសញ្ញានេះ
- ការនេសាទ
- ការស្រាវជ្រាវ ឬវាស់ស្ទង់
- សកម្មភាពធ្វើឱ្យអាក់ខានប្រព័ន្ធគមនាគមន៍ ឬឧបករណ៍ផ្សេងទៀត
- សកម្មភាពដទៃទៀតដែលប៉ះពាល់មិនផ្ទាល់នៅពេលឆ្លងកាត់[៦]។

- **តំបន់សមុទ្រតភ្ជាប់** គឺជាតំបន់សមុទ្រដែលបន្តពីសមុទ្រដែនដី ដែលមិនអនុញ្ញាតឱ្យពង្រីកលើស ២៤ម៉ែល៍សមុទ្រពីបន្ទាត់មូលដ្ឋាននោះឡើយ បើគិតវាស់ពីសមុទ្រដែនដីវិញគឺមានចម្ងាយ ១២ម៉ែល៍សមុទ្រ[៧]។ នៅក្នុងតំបន់នេះ នៅពេលមានបទល្មើសព្រហ្មទណ្ឌកើតឡើង យុត្តាធិការកម្ពុជាក៏មានវិសាលភាពអនុវត្តមិនខុសពីសមុទ្រដែនដីដែរ។
- **តំបន់សេដ្ឋកិច្ចផ្តាច់មុខ** គឺតំបន់មួយនៅហួស និងនៅជិតសមុទ្រដែនដី[៨]។ ទំហំតំបន់សេដ្ឋកិច្ច ផ្តាច់មុខ មិនត្រូវហួសចម្ងាយ ២០០ម៉ែល៍សមុទ្រ ពីបន្ទាត់មូលដ្ឋានវាស់ពីសមុទ្រដែនដី[៩]។ ចំពោះការអនុវត្តច្បាប់ព្រហ្មទណ្ឌ ក៏ជាសមត្ថកិច្ចរបស់រដ្ឋម្ចាស់ឆ្នេរដែលមិនខុសពីសមុទ្រដែនដី និងតំបន់តភ្ជាប់ដែរ។

សម្រាប់ដែនសមុទ្រកម្ពុជា គឺមានជាប់តែជាមួយនឹងប្រទេសវៀតណាម និងប្រទេសថៃតែប៉ុណ្ណោះ ហើយកម្ពុជាក៏បានធ្វើកិច្ចព្រមព្រៀងជាមួយនឹងប្រទេសទាំងពីរនោះរួមមកហើយផងដែរ។

---

(៦) មាត្រា ១៩ នៃអនុសញ្ញាអន្តរជាតិស្តីពីនីតិសមុទ្រ

(៧) មាត្រា ៣៣ នៃអនុសញ្ញាអន្តរជាតិស្តីពីនីតិសមុទ្រ៖ តំបន់មួយតភ្ជាប់សមុទ្រដែនដីរបស់ខ្លួន ដែលហៅថាតំបន់តភ្ជាប់ រដ្ឋឆ្នេរសមុទ្រអាចគ្រប់គ្រងជាចាំបាច់ដើម្បី៖ (ក) ការពារការបំពានច្បាប់ និងបទប្បញ្ញត្តិស្តីពីគយ, សារពើពន្ធ, អន្តោប្រវេសន៍ ឬសុខាភិបាល នៅក្នុងដែនដី ឬដែនសមុទ្ររបស់ខ្លួន (ខ) ដាក់ទោសលើការបំពានច្បាប់ និងបទប្បញ្ញត្តិដែលកើតឡើងក្នុងដែនដី ឬសមុទ្រដែនដីរបស់ខ្លួន។ តំបន់តភ្ជាប់មិនអាចពង្រីកលើស ២៤ ម៉ែល៍សមុទ្រ ពីបន្ទាត់មូលដ្ឋានបានឡើយ។

(៨) មាត្រា ៥៥ នៃអនុសញ្ញាស្តីពីនីតិសមុទ្រ

(៩) មាត្រា ៥៧ នៃអនុសញ្ញាស្តីពីនីតិសមុទ្រ

យោងតាមបញ្ជីរបស់សាធារណរដ្ឋខ្មែរ កម្ពុជាមានកោះចំនួនប្រហែល ៦៥ ប៉ុន្តែឯកសាររបស់កងទ័ពជើងទឹកនៃកងយោធពលខេមរភូមិន្ទ សម័យព្រះរាជាណាចក្រកម្ពុជាទី២ បញ្ជាក់ថាមានចំនួន ៦២។ កោះដែលសំខាន់ជាងគេសម្រាប់កំណត់បន្ទាត់មូលដ្ឋាន និងព្រំដែនសមុទ្ររបស់ព្រះរាជាណាចក្រកម្ពុជាគឺ កោះត្រល់ (ខាងវៀតណាម) និងកោះគុត (ខាងថៃ)។ កោះត្រល់មានបណ្តោយ ៥០ គ.ម ទទឹង ២៥ គ.ម កំពូលភ្នំកម្ពស់ ៦៤១ម៉ែត្រ មានចម្ងាយ ១០ គ.ម ពីឆ្នេរគោកទូទៅចម្ងាយ ២៥ គ.ម ពីក្រុងកែប។ កោះគុតមានបណ្តោយ ២០ គ.ម និងទទឹង ១០ គ.ម កំពូលភ្នំខ្ពស់កម្ពស់ ៣៥៦ ម៉ែត្រ និងមានចម្ងាយ ៣០ គ.ម ពីឆ្នេរគោក[១០]។

ចំពោះដែនអាកាសវិញ លំហអាកាសទៅលើទាំងអស់ ទាំងនៅលើដែនដី និងដែនសមុទ្រ គឺស្ថិតក្រោមអធិបតេយ្យភាពទាំងស្រុងរបស់រដ្ឋដែនដីនោះទាំងស្រុង។

មិនត្រឹមតែដែនដី ដែនសមុទ្រ និងដែនអាកាសដែលបានកំណត់ខាងលើ ថាជាដែនដីនៃព្រះរាជាណាចក្រកម្ពុជាប៉ុណ្ណោះទេ ក៏នៅមានទីកន្លែងមួយចំនួនទៀត ដែលកំណត់ថាជាដែនដីនៃព្រះរាជាណាចក្រកម្ពុជា ហើយច្បាប់ព្រហ្មទណ្ឌមានវិសាលភាពអនុវត្តផងដែរ ដែលទីកន្លែងទាំងនោះមានដូចជាស្ថានទូត ឬស្ថានកុងស៊ុលកម្ពុជាប្រចាំរដ្ឋបរទេស។

### ១.១.២ ការអនុវត្តច្បាប់ព្រហ្មទណ្ឌចំពោះទីតាំងទូត ឬកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជា

ទោះបីជាដែនដីកម្ពុជាត្រូវបានកំណត់ជាក់លាក់ ក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ត្រង់មាត្រា ២ ក៏ពិតមែន ប៉ុន្តែយោងតាមស្មារតីនៃកិច្ចព្រមព្រៀងអន្តរជាតិ ទីកន្លែងមួយចំនួនក៏បានកំណត់ថាជាទឹកដីនៃព្រះរាជាណាចក្រកម្ពុជាផងដែរ ដែលក្នុងនោះមានដូចជាទីតាំងស្ថានទូត ឬស្ថានកុងស៊ុលរបស់កម្ពុជានៅរដ្ឋបរទេសជាដើម។

ស្ថានបេសកកម្មការទូត គឺជាស្ថាប័នមួយដែលបង្កើតឡើងសម្រាប់ដាក់តាំងនៅក្នុងទឹកដីនៃរដ្ឋមួយផ្សេងទៀត ដើម្បីធ្វើទំនាក់ទំនងការទូតជាមួយរដ្ឋនោះ ឬមួយសម្រាប់ចរចារកិច្ចការផ្ទៃក្នុងជាមួយរដ្ឋនានា ដែលទាក់ទងទៅនឹងរឿងនយោបាយជាតិ ឬនយោបាយក្រៅប្រទេសផ្សេងៗជាដើម។ ទីស្ថានការទូតត្រូវបង្កើតឡើងតាមរយៈកិច្ចព្រមព្រៀងជាមួយគ្នាទៅវិញទៅមករវាងរដ្ឋ និងរដ្ឋ។ ការបង្កើតស្ថានបេសកកម្មការទូត ក្នុងគោលបំណងដើម្បីការពារផលប្រយោជន៍ប្រជាពលរដ្ឋដែលរស់នៅលើទឹកដីនៃរដ្ឋនោះ។ ស្ថានបេសកកម្មការទូតមានពីរប្រភេទគឺ ស្ថានទូតដែលដឹកនាំដោយឯកអគ្គរាជទូត ឬអ្នកដែលមានឋានៈស្មើ និងស្ថានអគ្គរដ្ឋទូត ឬអគ្គរាជទូតដែលដឹកនាំដោយប្រេសិត[១១]ឬភារធារី[១២]។

(១០) ដកស្រង់ចេញពីសៀវភៅនីតិសមុទ្រ ទំព័រ២៨៤ របស់សាស្ត្រាចារ្យ សំរ៉ង រិទ្ធីវឌ្ឍ

(១១) ប្រេសិត គឺជាជនដែលរាជរដ្ឋាភិបាលចាត់បញ្ជូនទៅកាន់ប្រទេសដទៃ ដើម្បីប្រាស្រ័យកិច្ចការផ្សេងៗ។

(១២) ភារធារី គឺជាមន្ត្រីជំទប់នៃឯកអគ្គរាជទូត ឬឯកអគ្គរដ្ឋទូតមាននាទីបំពេញមុខការក្នុងអង្គទូតជាជំនួសក្នុងករណីដែលអគ្គរាជទូត ឬឯកអគ្គរដ្ឋទូតមិននៅ។

ផ្អែកតាមប្រការ ២២ នៃអនុសញ្ញាទីក្រុងវីយ៉ែន ឆ្នាំ១៩៦១ ស្តីពីទំនាក់ទំនងការទូត ដែលកម្ពុជាបានផ្តល់សច្ចាប័ននាថ្ងៃទី ៣១ ខែសីហា ឆ្នាំ១៩៦៥ បានកំណត់ថា "**ទីស្ថានបេសកកម្មនេះពុំអាចត្រូវរដ្ឋម្ចាស់ផ្ទះបំពារបំពានបានឡើយ។ បណ្តាភ្នាក់ងាររបស់រដ្ឋម្ចាស់ផ្ទះ មិនអាចចូលទៅក្នុងទីស្ថានបេសកកម្មនោះ ដោយគ្មានការយល់ព្រមពីប្រមុខបេសកកម្មបានឡើយ។ រដ្ឋម្ចាស់ផ្ទះមានកាតព្វកិច្ចពិសេស ក្នុងការចាត់ការគ្រប់វិធានការណ៍សមស្រប ដើម្បីទប់ស្កាត់មិនឱ្យទីស្ថានបេសកកម្មត្រូវបំពារបំពាន ឬត្រូវខូចខាត និងរារាំងរាល់ការរំខានភាពស្ងប់ស្ងាត់របស់បេសកកម្ម ឬភាពថ្លៃថ្នូររបស់បេសកកម្ម**"។

ដូច្នេះគឺមានន័យថានៅពេលដែលមានបទល្មើសណាមួយបានកើតឡើងនៅក្នុងស្ថានទូត ឬស្ថានកុងស៊ុលរបស់ព្រះរាជាណាចក្រកម្ពុជាដែលស្ថិតនៅរដ្ឋបរទេស គឺត្រូវយកច្បាប់ព្រហ្មទណ្ឌរបស់ព្រះរាជាណាចក្រកម្ពុជាទៅអនុវត្ត។

### ១.១.៣ ការមិនអនុវត្តច្បាប់ព្រហ្មទណ្ឌនៅលើដែនដីកម្ពុជាតាមកិច្ចព្រមព្រៀងអន្តរជាតិ

ដូចទៅនឹងចំណុចការអនុវត្តច្បាប់ព្រហ្មទណ្ឌចំពោះទីតាំងទូត ឬស្ថានកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជានៅរដ្ឋបរទេសដែរ ទោះបីជាមានការកំណត់អំពីដែនដីនៃព្រះរាជាណាចក្រកម្ពុជាក៏ដោយ ក៏មានទីកន្លែងមួយចំនួននៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ដែលក្រមព្រហ្មទណ្ឌមិនអាចយកទៅអនុវត្តចំពោះបទល្មើសដែលបានកើតឡើងនៅទីតាំងនោះ។ ដោយសារតែកម្ពុជាបាន ផ្តល់សច្ចាប័នលើអនុសញ្ញាទីក្រុងវីយ៉ែន ចុះថ្ងៃទី ១៨ ខែ មេសា ឆ្នាំ១៩៦១ ស្តីអំពីទំនាក់ទំនងការទូត និងបានចូលជាធរមាននៅថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ១៩៦៥។ ដូច្នេះរាល់ល្មើសព្រហ្មទណ្ឌទាំងឡាយណាដែលបានប្រព្រឹត្តនៅក្នុងទីតាំងស្ថានទូត ឬស្ថានកុងស៊ុលរបស់រដ្ឋណាមួយក្នុងទឹកដីនៃព្រះរាជាណាចក្រកម្ពុជា តុលាការកម្ពុជាគឺមិនមានសមត្ថកិច្ចឡើយ[១៣] លើកលែងតែក្នុងករណីដែលបទល្មើសដែលបានប្រព្រឹត្តនោះមានពលរដ្ឋខ្មែរជាជនល្មើស ឬជាជនរងគ្រោះ។

ទីស្ថានបេសកកម្មគឺសំដៅដល់ដីធ្លី និងអគារដែលសម្រាប់បម្រើការដល់បេសកកម្មការទូតដោយរាប់បញ្ចូលទាំងនិវេសនដ្ឋានរបស់ប្រមុខការទូតនោះផងដែរ។

ជាគោលការណ៍ ភ្នាក់ងារអាជ្ញាធររបស់រដ្ឋម្ចាស់ផ្ទះត្រូវហាមឃាត់ មិនអាចឱ្យចូលទៅក្នុងទីស្ថានបេសកកម្មនេះបានទេ ប៉ុន្តែក្នុងករណីខ្លះភ្នាក់ងាររដ្ឋម្ចាស់ផ្ទះត្រូវបង្ខំចិត្ត រំលោភលើអភ័យឯកសិទ្ធិនៃស្ថានបេសកកម្មនេះ ដើម្បីដោះស្រាយស្ថានការណ៍ទាល់ច្រកណាមួយ ឧទាហរណ៍ដូចជាករណីវិបត្តិចំណាប់ខ្មាំងក្នុងស្ថានទូតជប៉ុន ប្រចាំនៅក្រុងលីម៉ា នៃប្រទេសប៉េរ៉ូ នៅថ្ងៃទី ១៧ ខែធ្នូ ឆ្នាំ១៩៩៦ ស្ថានទូតជប៉ុនប្រចាំក្រុងលីម៉ា នៃប្រទេសប៉េរ៉ូ បានរៀបចំពិធីជប់លៀងមួយ នៅក្នុង

(១៣) មាត្រា ២២ នៃសន្ធិសញ្ញាទីក្រុងវីយ៉ែន ឆ្នាំ១៩៦១ ស្តីពីទំនាក់ទំនងការទូត

និវេសនដ្ឋានលោកឯកអគ្គរាជទូតជប៉ុន Morihisa Aoki ដើម្បីអបអរសាទបុណ្យខួបកំណើតព្រះចៅអធិរាជជប៉ុន។ ស្ថានទូតបានអញ្ជើញឯកអគ្គរដ្ឋទូតនានា និងមន្ត្រីជាន់ខ្ពស់ជាច្រើនរូបទៀតរបស់ប៉េរូ ប្រមាណ ៦០០នាក់ មកចូលរួមក្នុងពិធីនោះដែរ។

ឆ្លៀតឱកាសក្នុងពិធីជប់លាងនោះ ពួកឧទ្ទាមចលនាបដិវត្ត Tupac Amuru បានបន្លំខ្លួនចូលធ្វើជាអ្នកបម្រើ ព្រមទាំងបានផ្ទុះអាវុធ និងចាប់អ្នកចូលរួមទាំងអស់ក្នុងកម្មវិធីនោះជាចំណាប់ខ្មាំង។ ក្រុមឧទ្ទាមបានទាមទារឱ្យដោះលែងមេដឹកនាំ របស់គេដែលកំពុងជាប់ពន្ធនាគារ ជាថ្នូរនឹងការដោះលែងចំណាប់ខ្មាំងទាំងនោះ។ ការចរចាររយៈពេល ៣ខែ រវាងក្រុមឧទ្ទាម និងរដ្ឋាភិបាលប៉េរូ ដើម្បីស្វែងរកដំណោះស្រាយ ប៉ុន្តែត្រូវបរាជ័យដោយរដ្ឋាភិបាលប៉េរូបដិសេធមិនអាចធ្វើតាមការទាមទាររបស់ពួកឧទ្ទាមនោះបាន។

ការចរចារដ៏វែងអន្លាយនេះ បានផ្តល់ឱកាសឱ្យកងទ័ពប៉េរូ ជីករូងសម្ងាត់ក្រោមដីមួយសម្រាប់ចូលទៅដល់ក្រោមអគារនិវេសនដ្ឋាននោះតែម្តង។ នៅថ្ងៃទី២២ ខែមេសា ឆ្នាំ១៩៩៧ យុទ្ធនាការរំដោះចំណាប់ខ្មាំងបានមកដល់ កងទ័ពពិសេសប៉េរូបានចូលតាមរូងក្រោមដី ទៅកំទេចក្រុមឧទ្ទាម ហើយបានរំដោះចំណាប់ខ្មាំងប្រកបដោយភាពជោគជ័យ។

ព្រឹត្តិការណ៍រំដោះចំណាប់ចំណាប់ខ្មាំង ដឹកនាំដោយប្រធានាធិបតីប៉េរូ Alberto Fujimuri នេះត្រូវបានសកលលោកជាពិសេសសាធារណមតិជប៉ុន អបអរសាទយ៉ាងខ្លាំង។ លោកនាយករដ្ឋមន្ត្រីជប៉ុន Ryutaro Hashimoto បានចេញដំណើរជាបន្ទាន់ពីទីក្រុងតូក្យូទៅកាន់ទីក្រុងលីម៉ា ដើម្បីសំដែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះប្រទេសប៉េរូ ក្នុងការបញ្ចប់វិបត្តិចំណាប់ខ្មាំងដ៏ស្មុគស្មាញនេះ ទោះបីជាការចូលទៅរំដោះចំណាប់ខ្មាំងបែបនេះ អាចចាត់ទុកជាការរំលោភអភ័យឯកសិទ្ធិ នៃស្ថានបេសកកម្មការទូតរបស់ជប៉ុនក៏ដោយ។ ព្រោះដើម្បីរក្សាការសំងាត់នៃផែនការរំដោះនេះ កុំឱ្យខូចខ្ទាយ ប្រទេសប៉េរូពុំបានផ្តល់ដំណឹងពីការជីករូងក្រោមដី ឬក៏បានសុំការអនុញ្ញាតពីភាគីជប៉ុនជាមុនដើម្បីចូលទៅរំដោះចំណាប់ខ្មាំងក្នុងនិវេសនដ្ឋាននោះឡើយ។

ក្រៅពីការហាមឃាត់ ពុំអនុញ្ញាតឱ្យភ្នាក់ងាររបស់រដ្ឋម្ចាស់ ចូលទៅក្នុងទីស្ថានទូតដោយគ្មានការយល់ព្រមពីស្ថានបេសកកម្មនោះ រដ្ឋម្ចាស់ផ្ទះមានកាតព្វកិច្ចពិសេសមួយទៀតគឺការពារទីស្ថានបេសកកម្មការទូតពីអំពើរុកគួនរំខានពីខាងក្រៅ ដូចជាការរាងរាំងមិនឱ្យបុគ្គលណាមួយចូលទៅក្នុងស្ថានបេសកកម្មដោយគ្មានការអនុញ្ញាត ឬការពារកុំឱ្យមានការចោលគ្រឿងផ្ទុះទៅក្នុងទីស្ថាននោះ។

ដើម្បីបំពេញកាតព្វកិច្ចខាងលើ រដ្ឋម្ចាស់ផ្ទះតែងបញ្ជូនភ្នាក់ងារនគរបាលខ្លួន ទៅយាមកាមជាប្រចាំនៅមុខ និងជុំវិញបរិវេណស្ថានទូតជានិច្ច។ នៅកម្ពុជា ក៏មានការអនុវត្តបែបនេះដូចគ្នាដែរ។

នៅក្នុងរាជធានីភ្នំពេញ យើងអាចពិនិត្យឃើញនគរបាលកម្ពុជាកំពុងព្យាយាមល្បាតជាប្រចាំនៅមុខស្ថានទូតនានាជាដើម។

## ១.២ បទល្មើសដែលចាត់ទុកថាបានប្រព្រឹត្តនៅកម្ពុជា

ដូចដែលបានដឹងហើយថាគោលការណ៍ដែនដីនៃការអនុវត្តច្បាប់ព្រហ្មទណ្ឌកម្ពុជា គឺសំដៅលើករណីដែលធាតុផ្សំទាំងអស់ មាននៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ប៉ុន្តែក៏មានករណីផ្សេងទៀតដែលច្បាប់ព្រហ្មទណ្ឌកម្ពុជាអាចយកទៅអនុវត្តបានផងដែរ បើទោះបីជាបទល្មើសនោះមិនមានធាតុផ្សំទាំងអស់ នៅក្នុងទឹកដីនៃព្រះរាជាណាចក្រកម្ពុជាក៏ដោយ។ មាត្រា ១៣ នៃក្រមព្រហ្មទណ្ឌកម្ពុជាបានបញ្ញត្តិថា "**បទល្មើសត្រូវបានចាត់ថាប្រព្រឹត្តនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា នៅពេលដែលអំពើណាមួយនៃបទល្មើសនោះ បានប្រព្រឹត្តនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា**" ដូចនេះមានន័យថា បើទោះបីជាមិនមានធាតុផ្សំទាំងអស់នៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជាក៏ដោយ ក៏ច្បាប់ព្រហ្មទណ្ឌកម្ពុជាអាចយកទៅអនុវត្តបានផងដែរ ប្រសិនបើមានធាតុផ្សំណាមួយកើតមាននៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា។ ឧទាហរណ៍៖ ករណីមានអំពើចាប់ជំរិតមួយបានកើតឡើងនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ប៉ុន្តែការប្រគល់ប្រាក់គឺបានធ្វើឡើងនៅលើដែនដីនៃរដ្ឋបរទេសណាមួយ ដូច្នេះបើទោះបីជាមិនមានធាតុផ្សំទាំងអស់នៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជាក៏ដោយ ក៏ច្បាប់ព្រហ្មទណ្ឌកម្ពុជានៅតែមានអនុភាពអនុវត្តបានដែរ។ ជាក់ស្តែងតាមការចុះផ្សាយរបស់កាសែតខេមបូឌាដេលីជាភាសាខ្មែរ[១៤] នៅក្នុងកំឡុងខែកក្កដា ឆ្នាំ២០១៤ នាយកដ្ឋានកណ្តាលសន្តិសុខនៃក្រសួងមហាផ្ទៃបានចាប់ខ្លួនជនជាតិចិន ៧៨នាក់ ពាក់ព័ន្ធនឹងបទល្មើសចាប់ជំរិតតាមប្រព័ន្ធអ៊ីនធឺណេត ដែលការចាប់ខ្លួននេះបន្ទាប់ពីមានបណ្តឹងពីស្ថានទូតចិនដែលជួសមុខឱ្យជនរងគ្រោះនៅក្នុងប្រទេសចិន ដែលបានរាយការណ៍ថាពួកគេត្រូវបានជំរិតទារប្រាក់ដោយមនុស្សមួយក្រុមដែលកំពុងធ្វើសកម្មភាព នៅក្នុងប្រទេសកម្ពុជា។

បទល្មើសដែលចាត់ទុកថាបានប្រព្រឹត្តនៅកម្ពុជា រួមបញ្ចូលទាំងអំពើផ្តើមគំនិត ឬសមគំនិតដែលត្រូវបានប្រព្រឹត្តនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា តាមបញ្ញត្តិនៃមាត្រា១៧ ក្នុងក្រមនេះ ប៉ុន្តែសម្រាប់អំពើទាំងពីរនេះ គឺអនុវត្តចំពោះតែបទល្មើសជាបទឧក្រិដ្ឋ និងមជ្ឈិមតែប៉ុណ្ណោះ ហើយក៏ត្រូវមានលក្ខខណ្ឌពីរដែលត្រូវបំពេញផងដែរ ដែលលក្ខខណ្ឌទាំងនោះមានដូចជា៖

- បទល្មើសត្រូវបានផ្តន្ទាទោសតាមច្បាប់កម្ពុជាផង និងច្បាប់បរទេសផង
- អត្ថិភាពនៃបទល្មើសត្រូវបានបញ្ជាក់ដោយសេចក្តីសម្រេចស្ថាពររបស់តុលាការបរទេស[១៥]។

(១៤) http://www.cambodiadailykhmer.com/16755

(១៥) មាត្រា ១៧ នៃក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ២០០៩

ឧទាហរណ៍៖ មានបុរសជាជនជាតិខ្មែរម្នាក់បានបញ្ជាបុរសដែលជាជនជាតិថៃម្នាក់ឱ្យទៅសម្លាប់បុរសជនជាតិថៃម្នាក់ទៀតនៅលើទឹកដីថៃ។ ជនដៃដល់ដែលជាជនជាតិថៃនោះ ត្រូវបានតុលាការថៃសម្រេចផ្តន្ទាទោសតាមច្បាប់ព្រហ្មទណ្ឌថៃ។ ប៉ុន្តែដោយហេតុថាបុរសជាជនជាតិខ្មែរគឺជាអ្នកដែលបានបញ្ជាឱ្យមានការប្រព្រឹត្តបទល្មើសនោះ ដូច្នេះយោងតាមការករណីខាងលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ក៏អាចយកអនុវត្តទៅលើអំពើដែលបុរសជនជាតិខ្មែរបានបញ្ជាឱ្យសម្លាប់ក្នុងនាមជាអ្នកផ្តើមគំនិត ព្រោះថាអំពើបញ្ជាដែលជាធាតុផ្សំនៃការផ្តើមឱ្យប្រព្រឹត្តបទល្មើសគឺនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ដែលពាក់ព័ន្ធនឹងបទល្មើសឃាតកម្មគិតទុកជាមុន[១៦] ជាបទល្មើសដែលច្បាប់របស់កម្ពុជាតម្រូវឱ្យផ្តន្ទាទោស ហើយច្បាប់របស់ប្រទេសថៃក៏បានចែងផ្តន្ទាទោសដូចគ្នាដែរម្យ៉ាងវិញទៀត បទល្មើសនេះបានកើតឡើងយ៉ាងពិតប្រាកដ តាមរយៈសេចក្តីសម្រេចរបស់តុលាការប្រទេសថៃ ដែលបានសម្រេចផ្តន្ទាទោសជនដៃដល់រួចហើយ។

ករណីមួយទៀត ក្រៅតែអំពីទំហំផ្ទៃដី ដែនសមុទ្រ ឬដែនអាកាសដែលច្បាប់ព្រហ្មទណ្ឌរបស់កម្ពុជាមានវិសាលភាពអនុវត្តលើហើយនោះ ក៏នៅមានទីកន្លែងមួយចំនួនត្រូវចាត់ទុកថាបានប្រព្រឹត្តនៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជាដែរ។

តាមក្រមព្រហ្មទណ្ឌ បទល្មើសដែលត្រូវបានចាត់ទុកថាប្រព្រឹត្តនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា កាលបើបទល្មើសនោះត្រូវបានប្រព្រឹត្ត៖

- នៅក្នុងនាវាដែលមានសញ្ជាតិកម្ពុជាទោះបីជានាវានោះស្ថិតនៅទីណាក៏ដោយ[១៧]
- នៅក្នុងអាកាសយានមានសញ្ជាតិកម្ពុជាទោះបីជានាវានោះស្ថិតនៅទីណាក៏ដោយ[១៨]

ក្រៅតែពីចំណុចទាំងពីរខាងលើនេះ ក្រមព្រហ្មទណ្ឌកម្ពុជាក៏បានប្រគល់សមត្ថកិច្ចឱ្យតុលាការ កម្ពុជាបន្ថែមទៀត ចំពោះបទល្មើសដែលបានកើតឡើងនៅក្នុងនាវាបរទេស ហើយដែលអាជ្ញាធរកម្ពុជាបានទទួលការអនុញ្ញាតឱ្យពិនិត្យមើល ឬចាប់តាមអំណាចនៃកិច្ចព្រមព្រៀងអន្តរជាតិ[១៩]។

## ១.២.១ បទល្មើសដែលប្រព្រឹត្តក្នុងនាវាសញ្ជាតិកម្ពុជា

រដ្ឋនីមួយៗត្រូវចាត់វិធានការណ៍ចាំបាច់ទាំងឡាយ ដើម្បីបង្កើតយុត្តាធិការរបស់ខ្លួនលើបទល្មើសនានាដែលមានចែងក្នុងមាត្រា៣នៃច្បាប់ស្តីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជា

(១៦) មាត្រា ២០០ នៃក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ២០០៩
(១៧) មាត្រា ១៤ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩
(១៨) មាត្រា ១៦ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩
(១៩) មាត្រា ១៥ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

ចូលជាសមាជិកនៃអនុសញ្ញាស្តីពីការបង្ក្រាបអំពើខុសច្បាប់ទៅលើសុវត្ថិភាព នៃការធ្វើនាវាចរណ៍តាមដែនសមុទ្រនៅពេលដែលបទល្មើសនោះត្រូវបានប្រព្រឹត្តៈ

- ប្រឆាំងទៅនឹង ឬនៅលើនាវាដែលមានដាក់ទង់ជាតិនៃរដ្ឋនោះ នៅពេលដែលបទល្មើសនោះត្រូវបានប្រព្រឹត្ត ឬ
- នៅក្នុងទឹកដីនៃរដ្ឋនោះ រួមបញ្ចូលទាំងសមុទ្រដែនដីនៃរដ្ឋនោះ ឬ
- ដោយជនជាតិណាម្នាក់នៃរដ្ឋនោះ

រដ្ឋភាគីមួយអាចបង្កើតនូវយុត្តាធិការរបស់ខ្លួន លើបទល្មើសបែបណាមួយនោះ នៅពេលដែលៈ

- បទល្មើសនោះត្រូវបានប្រព្រឹត្តដោយនិបេតកជន[២០]ដែលមាននិវេសនដ្ឋានជាទំលាប់របស់ខ្លួននៅក្នុងរដ្ឋនោះ ឬ
- ក្នុងកំឡុងពេលនៃការប្រព្រឹត្តបទល្មើសនោះ ជនជាតិណាម្នាក់នៃរដ្ឋនោះត្រូវបានឃាត់ខ្លួន ត្រូវបានគម្រាមកំហែង ត្រូវបានធ្វើឱ្យរងរបួស ឬត្រូវបានសម្លាប់ ឬ
- បទល្មើសត្រូវបានប្រព្រឹត្ត ក្នុងបំណងបង្ខិតបង្ខំរដ្ឋនោះឱ្យធ្វើ ឬមិនឱ្យធ្វើនូវអំពើណាមួយ។

រដ្ឋភាគីនីមួយៗ ដែលបានបង្កើតយុត្តាធិការរបស់ខ្លួនលើករណីទាំងឡាយ ដូចមានចែងនៅក្នុងកថាខ័ណ្ឌ ២ ត្រូវជូនដំណឹងដល់អគ្គលេខាធិការនៃអង្គការដែនសមុទ្រអន្តរជាតិ។ បន្ទាប់មកប្រសិនបើរដ្ឋភាគីនោះលុបចោលនូវយុត្តាធិការនេះ រដ្ឋភាគីនោះត្រូវជូនដំណឹងដល់អគ្គលេខាធិការអង្គការដែនសមុទ្រអន្តរជាតិ។

រដ្ឋភាគីនីមួយៗត្រូវចាត់វិធានការចាំបាច់ ដើម្បីបង្កើតនូវយុត្តាធិការរបស់ខ្លួនលើបទល្មើសនានា ដូចមានចែងក្នុងមាត្រា៣ និងមាត្រា៦ នៃ ״ច្បាប់ស្តីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាសមាជិកនៃអនុសញ្ញាស្តីពីការបង្ក្រាបអំពើខុសច្បាប់ទៅលើសុវត្ថិភាព នៃការធ្វើនាវាចរណ៍តាមដែនសមុទ្រ״ ក្នុងករណីទាំងឡាយដែលជនល្មើស ដោយសន្មតមានវត្តមាននៅក្នុងទឹកដីនៃរដ្ឋនោះ ហើយរដ្ឋនោះមិនធ្វើបត្យាប័នជនល្មើសនោះទៅឱ្យរដ្ឋភាគីណាមួយផ្សេងទៀតដែលបានបង្កើតយុត្តាធិការ ដោយអនុលោមតាមកថាខ័ណ្ឌទី១ និងទី២ មាត្រា ៦ នៃ ״ច្បាប់ស្តីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាសមាជិកនៃអនុសញ្ញាស្តីពី ការបង្ក្រាបអំពើខុសច្បាប់ទៅលើសុវត្ថិភាព នៃការធ្វើនាវាចរណ៍តាមដែនសមុទ្រ״។

(២០) និបេតកជនៈ ជនដែលគ្មានសញ្ជាតិ

អនុសញ្ញានេះ រាប់បញ្ចូលទាំងយុត្តាធិការព្រហ្មទណ្ឌ ដែលត្រូវបានអនុវត្តឱ្យស្របទៅតាមច្បាប់ជាតិ។

រាល់នាវាដែលកម្ពុជាបានផ្តល់ទង់ជាតិឱ្យគឺចាត់ទុកថាមានសញ្ជាតិកម្ពុជា ដែលមានទំនាក់ទំនងពិតប្រាកដជាមួយរាជរដ្ឋាភិបាល។

ជនណាម្នាក់ជាជនប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ប្រសិនបើជននោះប្រព្រឹត្តដោយខុសច្បាប់ និងដោយចេតនានូវអំពើដូចជាៈ

- រឹបអូស ឬធ្វើការត្រួតត្រាទៅលើនាវាដោយប្រើហិង្សា ឬការគម្រាមកំហែង ឬបំផិតបំភ័យតាមទ្រង់ទ្រាយណាមួយ
- ប្រព្រឹត្តអំពើហិង្សាទៅលើមនុស្សនៅលើនាវា ប្រសិនបើអំពើនោះអាចធ្វើឱ្យមានគ្រោះថ្នាក់ដល់សុវត្ថិភាពនៃការធ្វើនាវាចរណ៍របស់នាវានោះ
- បំផ្លាញនាវា ឬបង្ករការខូចខាតដល់នាវា ឬទំនិញរបស់នាវាដែលអាចធ្វើឱ្យគ្រោះថ្នាក់ដល់សុវត្ថិភាពនៃការធ្វើនាវាចរណ៍របស់នាវា
- ដាក់ឬធ្វើឱ្យមានការដាក់នៅលើនាវាដោយមធ្យោបាយណាក៏ដោយនូវឧបករណ៍ឬសារធាតុដែលអាចបំផ្លិចបំផ្លាញដល់នាវានោះ ឬដែលអាចបង្ករការខូចខាតដល់នាវា ឬទំនិញរបស់នាវានោះ ដែលធ្វើឱ្យគ្រោះថ្នាក់ ឬអាចធ្វើឱ្យគ្រោះថ្នាក់ដល់សុវត្ថិភាពនៃការធ្វើនាវាចរណ៍នៃនាវានោះ
- បំផ្លាញ ឬធ្វើឱ្យខូចខាតធ្ងន់ធ្ងរដល់ឧបករណ៍សម្រាប់ការធ្វើនាវាចរណ៍តាមសមុទ្រ ឬធ្វើឱ្យរំខានយ៉ាងខ្លាំងដល់ប្រតិបត្តិការរបស់នាវា ប្រសិនបើទង្វើរបែបនោះអាចធ្វើឱ្យគ្រោះថ្នាក់ដល់សុវត្ថិភាពនៃការធ្វើនាវាចរណ៍របស់នាវានោះ
- ផ្តល់ព័ត៌មានដែលខ្លួនដឹងថា "**មិនពិត**" ដែលជាហេតុធ្វើឱ្យគ្រោះថ្នាក់ដល់សុវត្ថិភាពនៃការធ្វើនាវាចរណ៍នៃនាវា
- បង្កររបួសស្នាម ឬឃាត់ជនណាម្នាក់បើអំពើទាំងនោះមានចំណងទាក់ទងជាមួយបទល្មើសណាមួយនៃបទល្មើសទាំងឡាយ នៅចំណុចខាងលើ ដែលបទល្មើសនោះត្រូវបានប្រព្រឹត្ត ឬប៉ុនប៉ងប្រព្រឹត្ត។

ត្រូវចាត់ទុកជាការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌមួយផងដែរ ប្រសិនបើជននោះៈ

- ប៉ុនប៉ងប្រព្រឹត្តបទល្មើសទាំងឡាយដែលបានកំណត់ខាងលើ ឬ
- ជម្រុញជនណាម្នាក់ផ្សេងទៀត ឱ្យប្រព្រឹត្តបទល្មើសណាមួយ ក្នុងចំណោមបទល្មើសទាំងឡាយ ដូចបានកំណត់នៅផ្នែកខាងលើដូចគ្នា ឬសមគំនិតជាមួយនឹងជនណាម្នាក់ដែលប្រព្រឹត្តបទល្មើសបែបណាមួយ ឬ

- គម្រាមកំហែង ដោយមាន ឬគ្មានលក្ខខណ្ឌដូចមានចែងក្នុងច្បាប់ជាតិ ក្នុងគោលបំណងបង្ខិតបង្ខំរូបវន្តបុគ្គល ឬនីតិបុគ្គលឱ្យធ្វើ ឬមិនឱ្យធ្វើអំពើណាមួយ ឱ្យប្រព្រឹត្តបទល្មើសដូចមានកំណត់នៅចំណុចខាងលើ និងប្រសិនបើការគម្រាមកំហែងនោះ អាចធ្វើឱ្យគ្រោះថ្នាក់ដល់សុវត្ថិភាពនៃការធ្វើនាវាចរណ៍នៃនាវានោះ[២១]។

នាវាដែលបានចុះបញ្ជីសញ្ជាតិកម្ពុជាហើយ ទោះបីជានាវានោះបានធ្វើដំណើរដល់ទីណាក៏ដោយ ក៏ស្ថិតនៅក្រោមយុត្តាធិការច្បាប់ព្រហ្មទណ្ឌរបស់កម្ពុជាដែរ លើកលែងមានករណីមួយចំនួនដែលបានចែងច្បាស់នៅក្នុងសន្ធិសញ្ញាអន្តរជាតិផ្សេង ឬអនុញ្ញាស្តីពីច្បាប់សមុទ្រ។

មូលដ្ឋាននៃការថែរក្សាសណ្តាប់ធ្នាប់សមុទ្រអន្តរជាតិ បានដាក់ទៅលើទស្សនៈសញ្ជាតិនៃនាវា និងយុត្តាធិការរបស់រដ្ឋដាក់ទង់ជាតិនៅលើនាវា។ រដ្ឋដាក់ទង់ជាតិថានឹងធ្វើឱ្យមានប្រសិទ្ធិភាពលើវិធាននានា និងបទដ្ឋានសម្រាប់តែប្រទេសផ្ទាល់ខ្លួន និងទៅច្បាប់អន្តរជាតិផងដែរ។ នាវាគ្មានទង់ជាតិនឹងដកចេញនូវផលប្រយោជន៍ជាច្រើន និងសិទ្ធិនានាដែលស្ថិតនៅក្រោមរបបផ្លូវច្បាប់នៃសមុទ្រអន្តរជាតិ។

រដ្ឋនីមួយៗ តម្រូវបញ្ជាក់ពីលក្ខខណ្ឌចាំបាច់សម្រាប់ការផ្តល់សញ្ជាតិសម្រាប់នាវា សម្រាប់ការចុះបញ្ជីនៃនាវានៅក្នុងទឹកដី និងសិទ្ធិសម្រាប់ដាក់ទង់ជាតិ។ សញ្ជាតិរបស់នាវា និងអាស្រ័យទៅលើទង់ជាតិដែលបានដាក់ ប៉ុន្តែមាត្រា ៥ នៃអនុសញ្ញាអន្តរជាតិ បានចែងថា នឹងមានជាទំនាក់ទំនងច្បាស់លាស់រវាងរដ្ឋ និងនាវា និងជាពិសេសរដ្ឋត្រូវអនុវត្តយ៉ាងមានប្រសិទ្ធិភាពនូវយុត្តាធិការរបស់គេ និងត្រួតពិនិត្យទៅលើបញ្ហាសង្គម បច្ចេកទេស និងរដ្ឋបាលនាវាចរដោយទង់ជាតិរបស់រដ្ឋនោះ។

សន្និសីទរបស់អង្គការសហប្រជាជាតិស្តីពីលក្ខខណ្ឌនៃការចុះបញ្ជីនាវា បានប្រជុំនៅក្នុងខែកក្កដា ឆ្នាំ១៩៨៤ និងកិច្ចព្រមព្រៀងបានចុះហត្ថលេខាក្នុងឆ្នាំ១៩៨៦ បានកំណត់ថា រដ្ឋដាក់ទង់ជាតិត្រូវមានច្បាប់ និងបទដ្ឋានសម្រាប់កម្មសិទ្ធិនៃនាវា ដែលចរាចរទង់ជាតិរបស់គេ និងច្បាប់ទាំងនោះត្រូវរាប់បញ្ចូលបទប្បញ្ញត្តិសម្រាប់ការចូលរួមដោយជនជាតិដែលជាម្ចាស់នាវា និងត្រូវអនុញ្ញាតឱ្យរដ្ឋដាក់ទង់ជាតិដើម្បីអនុវត្តយ៉ាងមានប្រសិទ្ធិភាពលើយុត្តាធិការរបស់គេ និងត្រួតពិនិត្យលើនាវាដែលចរាចរដាក់ទង់ជាតិ។

## ១.២.២ បទល្មើសដែលប្រព្រឹត្តក្នុងអាកាសយានកម្ពុជា

អនុសញ្ញាទីក្រុងប៉ារីសឆ្នាំ១៩១៩ សម្រាប់បទដ្ឋានចរាចរអាកាសចរ (Aerial Navigation) ដែលបានទទួលស្គាល់អធិបតេយ្យពេញលេញ (Full Sovereignty) របស់រដ្ឋនានា លើលំហអាកាសនៅដែនដី និងដែនសមុទ្រ។

មានបញ្ហានានាទៅលើការពិភាក្សាថា យន្តហោះអាចឆ្លងកាត់លំហរអាកាសរបស់រដ្ឋនានាជាមួយនឹងកិច្ចព្រមព្រៀងរបស់រដ្ឋទាំងនោះ មិនអាចចូលលំហអាកាសបានទេ។

(២១) មាត្រា ៣ នៃអនុសញ្ញាស្តីពីការបង្ក្រាបអំពើខុសច្បាប់ទៅនឹងសុវត្ថិភាពនៃការធ្វើនាវាចរណ៍តាមដែនសមុទ្រ ឆ្នាំ១៩៨៨

អាកាសយានដែលបានចុះបញ្ជីនៅព្រះរាជាណាចក្រកម្ពុជា និងមានសញ្ជាតិខ្មែរ ហើយក្នុងរយៈពេលដែលការចុះបញ្ជីនោះនៅមានសុពលភាព អាកាសយាននោះពុំមានសិទ្ធិចុះបញ្ជីនៅរដ្ឋណាមួយផ្សេងទៀតបានទេ។

អាកាសយានដែលបានចុះបញ្ជីនៅក្នុងរដ្ឋណាមួយរួចហើយ ពុំមានសិទ្ធិចុះបញ្ជីនៅក្នុងព្រះរាជាណាចក្រកម្ពុជាទៀតទេ ក្នុងរយៈពេលដែលការចុះបញ្ជីនៅក្នុងរដ្ឋផ្សេងនោះនៅមានសុពលភាពនៅឡើយ[២២]។

ការចុះបញ្ជីសញ្ជាតិអាកាសយាននៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវគោរពទៅតាមបែបបទទាំងឡាយ ដែលកំណត់ដោយរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល។

រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលចេញឱ្យប្រើ ឬផ្អាកបណ្តោះអាសន្ន ឬបញ្ឈប់ការផ្ទេរចុះបញ្ជីអាកាសយាននៅក្នុងព្រះរាជាណាចក្រកម្ពុជា។

រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល នឹងរក្សាទុកឯកសារទាំងឡាយរបស់អាកាសយានទាំងអស់ ដែលបានចុះបញ្ជីនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

វិញ្ញាបនបត្រនៃការចុះបញ្ជីអស់សុពលភាព ក្នុងករណីណាមួយដូចខាងក្រោម៖

១ ការផុតកំណត់សុពលនៃវិញ្ញាបនបត្រណាមួយរបស់អាកាសយាន។

២ អាកាសយានបាត់បង់ ឬខូចខាតដែលមិនអាចជួសជុលបាន។

៣ អាកាសយានត្រូវបានដោះចេញជាផ្នែកៗ ឬបោះបង់ចោល។

៤ អាកាសយានត្រូវបានដកការចុះបញ្ជី ពីព្រះរាជាណាចក្រកម្ពុជារួចហើយ[២៣]។

ត្រូវចាត់ទុកថាជាអ្នកប្រព្រឹត្តឧក្រិដ្ឋកម្ម ជនណាដែលស្ថិតនៅលើអាកាសយានដែលកំពុងហោះហើរ បានប្រព្រឹត្តអំពើណាមួយដូចខាងក្រោម៖

- ការចាប់ពង្រត់អាកាសយានដោយប្រើកម្លាំង
- ការគម្រាមកំហែង ការបំភិតបំភ័យ ការដណ្តើមកាន់កាប់ត្រួតត្រាអាកាសយាន ឬការរឹបអូស ឬ
- ប៉ុនប៉ងប្រព្រឹត្តអំពើខាងលើ

(២២) មាត្រា ៦ នៃច្បាប់ស្តីពីអាកាសចរស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
(២៣) មាត្រា ៧ នៃច្បាប់ស្តីពីអាកាសចរស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា

អ្នកចូលរួមប្រព្រឹត្ត និងសមគំនិតជាមួយដើម្បីប្រព្រឹត្តអំពើខាងលើ ត្រូវចាត់ទុកជាអ្នកប្រព្រឹត្តបទឧក្រិដ្ឋដែរ[២៤]។

ជនណាដែលមានចេតនាប្រព្រឹត្តអំពើណាមួយដូចខាងក្រោម នឹងត្រូវចាត់ទុកថាជាអ្នកប្រព្រឹត្តឧក្រិដ្ឋកម្ម ឬធ្វើសកម្មភាពខុសច្បាប់ប្រឆាំងនឹងអាកាសចរស៊ីវិលៈ

- ប្រព្រឹត្តអំពើរំលោភបំពានលើបុគ្គលិកណាម្នាក់ នៅលើអាកាសយានកំពុងហោះហើរ ដែលបង្ករឱ្យមានការប៉ះពាល់ដល់សុវត្ថិភាពអាកាសយាន
- បំផ្លាញអាកាសយានក្នុងពេលធ្វើសេវា ឬបង្ករឱ្យមានការខូចខាតដល់អាកាសយាន ឬនាំឱ្យមានគ្រោះថ្នាក់ដល់សុវត្ថិភាពអាកាសយានក្នុងពេលហោះហើរ
- ដាក់ ឬលាក់ឧបករណ៍ ឬសារធាតុនៅលើអាកាសយានដែលកំពុងធ្វើសេវា ហើយបណ្តាលឱ្យខូចអាកាសយាន ឬនាំឱ្យមានគ្រោះថ្នាក់ដល់សុវត្ថិភាពអាកាសយានក្នុងពេលហោះហើរ
- បំផ្លាញ ឬធ្វើឱ្យខូចខាតដល់ប្រព័ន្ធឧបករណ៍នាំផ្លូវអាកាស ឬជ្រៀតជ្រែកដល់ដំណើរការឧបករណ៍នោះ បណ្តាលឱ្យមានគ្រោះថ្នាក់ដល់សុវត្ថិភាពអាកាសយានក្នុងពេលហោះហើយ
- ផ្សព្វផ្សាយព័ត៌មានមិនពិត បណ្តាលឱ្យមានគ្រោះថ្នាក់ដល់សុវត្ថិភាពអាកាសយានក្នុងពេលហោះហើរ
- ប្រើប្រាស់ឧបករណ៍ សារធាតុ ឬអាវុធជាតិផ្ទុះគ្រប់ប្រភេទ ដើម្បីប្រព្រឹត្តសកម្មភាពរំលោភប្រឆាំងទៅនឹងបុគ្គលិកណាម្នាក់នៅលើអាកាសយាន ដែលបម្រើការងារឱ្យអាកាសចរស៊ីវិល ហើយនឹងបង្ករឱ្យមានគ្រោះថ្នាក់យ៉ាងធ្ងន់ធ្ងរ ឬបាត់បង់ជីវិត និងមានគ្រោះថ្នាក់ដល់សុវត្ថិភាពនៅលើអាកាសយាននោះ
- ប្រើប្រាស់ឧបករណ៍ សារធាតុ ឬអាវុធជាតិផ្ទុះគ្រប់ប្រភេទ ដែលអាចបំផ្លាញ ឬនាំឱ្យខូចខាតយ៉ាងធ្ងន់ធ្ងរ ដល់ឧបករណ៍នៅលើអាកាសយាន ដែលបម្រើការងារឱ្យអាកាសចរស៊ីវិល ឬអាកាសយានមិនទាន់ធ្វើសេវានៅទីនោះ ឬធ្វើឱ្យមានការរអាក់រអួលការងារ និងនាំឱ្យមានគ្រោះថ្នាក់ដ៏ធ្ងន់ធ្ងរដល់អាកាសយានដ្ឋាន។
- ប៉ុនប៉ងប្រព្រឹត្តអំពើណាមួយដែលមានចែងក្នុងចំណុចខាងលើ
- សមគំនិតជាមួយជនដែលប្រព្រឹត្ត ឬប៉ុនប៉ងសកម្មភាពណាមួយដូចខាងលើ[២៥]។

---

(២៤) មាត្រា ៩៧ នៃច្បាប់ស្តីពីអាកាសចរស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
(២៥) មាត្រា ៩៨ នៃច្បាប់ស្តីពីអាកាសចរស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា

ទោសកម្មដែលមានចែងដូចខាងក្រោមនេះ ត្រូវស្ថិតនៅក្រោមដែនសមត្ថកិច្ចនៃតុលាការនៃព្រះរាជាណាចក្រកម្ពុជា៖

- ទោសសកម្ម ឬអំពើណាមួយផ្សេងទៀត ដែលបានប្រព្រឹត្តនៅលើអាកាសយានណាមួយ ដែលចុះបញ្ជីនៅក្នុងព្រះរាជាណាចក្រកម្ពុជា ទោះនៅទីណាក៏ដោយ
- ទោសកម្មណាមួយ ឬអំពើផ្សេងទៀត ក្នុងបូរណភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ដោយមិនគិតពីសញ្ជាតិនៃអាកាសយាន
- ទោសកម្មណាមួយ ឬអំពើផ្សេងទៀត ដែលបានប្រព្រឹត្តនៅលើអាកាសយាន ដែលចុះចតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ព្រមទាំងជនល្មើសនៅលើអាកាសយាននោះ
- ទោសសកម្មណាមួយ ឬអំពើផ្សេងទៀត ដែលបានប្រព្រឹត្តនៅលើអាកាសយាន ដែលជួលដោយគ្មានក្រុមហ៊ុនអាកាសយានិកទៅឱ្យអ្នកជួល ដែលអ្នកជួលអាកាសយាននោះមានមូលដ្ឋានធ្វើអាជីវកម្ម ដែលមានលំនៅឋានជាអចិន្ត្រៃយ៍របស់ខ្លួន នៅក្នុងព្រះរាជាណាចក្រកម្ពុជា។
- ទោសកម្មណាមួយ ឬអំពើផ្សេងទៀត ដែលបានចែងក្នុងអនុសញ្ញានានាស្តីពីសន្តិសុខ ដែលជនល្មើសស្ថិតនៅក្នុងទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ហើយពុំទាន់បានប្រគល់ខ្លួនស្របតាមមាត្រា ៨ នៃអនុសញ្ញាឡាអេ ឬអនុសញ្ញាម៉ុងរ៉េអាល់ ឬប្រគល់ខ្លួនទៅប្រទេសផ្សេងណាមួយ ដែលបានរៀបតាប់ក្នុងមាត្រា៨ ចំណុចទី១ នៃអនុសញ្ញាឡាអេ ឬមាត្រា ៥ ចំណុចទី១ នៃអនុសញ្ញាម៉ុងរ៉េអាល់។

ព្រះរាជាណាចក្រកម្ពុជាអាចអនុវត្តយុត្តាធិការបន្ថែមស្របតាមអនុសញ្ញាស្តីពីសន្តិសុខ[២៦]។

## ១.២.៣ បទល្មើសដែលប្រព្រឹត្តក្នុងនាវាបរទេស

រដ្ឋឆ្នេរសមុទ្រ មិនអាចចាត់វិធានការណ៍លើនាវាបរទេសកំពុងឆ្លងកាត់ តាមសមុទ្រដែនដី ដើម្បីចាប់ខ្លួនជនណាម្នាក់ ឬស៊ើបអង្កេតឧក្រិដ្ឋកម្មណាមួយ ដែលបានប្រព្រឹត្តមុនពេលនាវានោះចូលក្នុង សមុទ្រដែនដី ប្រសិនបើនាវានោះបន្តដំណើរមកពីកំពង់ផែបរទេស ដោយគ្រាន់តែឆ្លងកាត់សមុទ្រដែនដី និងមិនចូលដែនទឹកផ្ទៃក្នុង។ ប៉ុន្តែសម្រាប់ក្រមព្រហ្មទណ្ឌកម្ពុជាត្រង់មាត្រា ១៥ គឺបានផ្តល់យុត្តាធិការឱ្យច្បាប់កម្ពុជាអាចមានវិសាលភាពអនុវត្តបាន។ **ដូច្នេះតើការកំណត់ទាំងពីរខាងលើនេះ មានភាពផ្ទុយគ្នាដែរឬទេ?**

ក្នុងមាត្រា២៧ នៃអនុសញ្ញានីតិសមុទ្រ រដ្ឋឆ្នេរសមុទ្រគឺមិនអាចប្រើប្រាស់នូវយុត្តាធិការព្រហ្មទណ្ឌលើនាវាបរទេសដែលកំពុងឆ្លងកាត់សមុទ្រដែនដីបានឡើយ។ ដូច្នេះមិនអាចចាប់ជន

(២៦) មាត្រា ៩៩ នៃច្បាប់ស្តីពីអាកាសចរស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា

ណាម្នាក់ ឬស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌណាមួយ លើនាវាអំឡុងពេលឆ្លងកាត់បានឡើយ។ ប៉ុន្តែអាចប្រើប្រាស់យុត្តាធិការព្រហ្មទណ្ឌបានក្នុងករណីៈ

- ប្រសិនបើផលវិបាកនៃឧក្រិដ្ឋកម្មនោះ រាលដាលដល់រដ្ឋឆ្នេរសមុទ្រ
- ប្រសិនបើឧក្រិដ្ឋកម្មនោះរំខានដល់សន្តិភាពប្រទេសឬសណ្តាប់ធ្នាប់ល្អនៃសមុទ្រដែនដី
- ប្រសិនបើម្ចាស់នាវា ភ្នាក់ងារការទូត ឬមន្ត្រីកុងស៊ុល របស់រដ្ឋផ្តល់ទង់ជាតិ ស្នើសុំជំនួយពីអាជ្ញាធរមូលដ្ឋាន
- ប្រសិនបើចាំបាច់ក្នុងការបង្ក្រាបចរាចរណ៍គ្រឿងញៀនខុសច្បាប់។ មុនពេលចាប់វិធានការណ៍តាមការស្នើសុំ រដ្ឋឆ្នេរសមុទ្រត្រូវជូនដំណឹងដល់មន្ត្រីការទូត ឬមន្ត្រីកុងស៊ុលរបស់រដ្ឋផ្តល់ទង់ជាតិ ហើយត្រូវសម្របសម្រួលទំនាក់ទំនងរវាងមន្ត្រីនោះ និងបុគ្គលិករបស់នាវា។ ក្នុងករណីបន្ទាន់អាចជូនដំណឹងខណៈពេលកំពុងចាត់វិធានការណ៍តែម្តង។

នាវាយោធា និងនាវារបស់រាជរដ្ឋាភិបាល ដែលបានប្រតិបត្តិការណ៍មិនមែនជាគោលដៅពាណិជ្ជកម្ម មានអភ័យឯកសិទ្ធិពីយុត្តាធិការនៃរដ្ឋជាប់ឆ្នេរសមុទ្រ ទោះបីជាមានការទាមទារឱ្យចាកចេញពីដែនដីសមុទ្របន្ទាន់ក្តី សម្រាប់រំលោភទៅនឹងបទដ្ឋានឆ្លងកាត់ដោយសន្តិភាព និងរដ្ឋមានទង់ជាតិ និងទទួលខុសត្រូវនៅក្នុងករណីការខាតបង់ដែលបានបង្ក។

## ជំពូកទី២ៈ បទល្មើសដែលប្រព្រឹត្តក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា

ប្រសិនបើបទល្មើសព្រហ្មទណ្ឌមួយត្រូវបានប្រព្រឹត្តនៅលើដែនដីនៃប្រទេសកម្ពុជា ដោយជនមានសញ្ជាតិកម្ពុជាម្នាក់ ទៅលើជនកម្ពុជាណាម្នាក់ទៀត ជាការពិតឥតមន្ទិលដែលថាតុលាការព្រហ្មទណ្ឌកម្ពុជាមានសមត្ថកិច្ចលើករណីបទល្មើសដែលបានប្រព្រឹត្តនោះ។

ឧទាហរណ៍ បើអំពើចាប់ជំរិតមួយត្រូវបានប្រព្រឹត្តដោយជនដែលមានសញ្ជាតិកម្ពុជាម្នាក់នៅប្រទេសបារាំង ហើយការប្រគល់ប្រាក់ដែលជាថ្នូរនៃការចាប់ជំរិតនោះត្រូវបានធ្វើឡើង នៅប្រទេសថៃ ដូច្នេះសំនួរត្រូវបានចោទសួរថា **តើច្បាប់ព្រហ្មទណ្ឌនៃប្រទេសណាមួយដែលនឹងត្រូវយកទៅអនុវត្តលើករណីបទល្មើសនេះ? ហើយតុលាការណាដែលមានសមត្ថកិច្ច?**

នៅក្នុងនីតិវិធីព្រហ្មទណ្ឌ ដំណោះស្រាយវិវាទច្បាប់នៅក្នុងលំហ គឺត្រូវគោរពទៅតាមគោលការណ៍ដែនដី។

ដើម្បីការពារផលប្រយោជន៍ពលរដ្ឋកម្ពុជា និងផលប្រយោជន៍កម្ពុជាទាំងមូល ក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ បានកំណត់អំពីការពង្រីកវិសាលភាពការអនុវត្ត ចំពោះបទល្មើសដែលបានប្រព្រឹត្តនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា។ ការពង្រីកវិសាលភាពនេះគឺសំដៅទៅលើករណីដែល

មានជនល្មើស ឬជនរងគ្រោះមានសញ្ជាតិខ្មែរ ដែលបទល្មើសបានប្រព្រឹត្តនៅឯបរទេសដែលនេះគេហៅថា**គោលការណ៍សញ្ជាតិនៃការអនុវត្តច្បាប់ព្រហ្មទណ្ឌកម្ពុជា** និងករណីមួយទៀតគឺចំពោះបទល្មើសទាំងឡាយណាដែលប៉ះពាល់ដល់ផលប្រយោជន៍នៃព្រះរាជាណាចក្រកម្ពុជា។

## ២.១ ការអនុវត្តច្បាប់ព្រហ្មទណ្ឌកម្ពុជាតាមគោលការណ៍សញ្ជាតិ

យោងតាមគោលការណ៍បុគ្គលភាពសកម្ម ច្បាប់ព្រហ្មទណ្ឌអាចមានអានុភាពអនុវត្តចំពោះគ្រប់បទល្មើសដែលមានការពាក់ព័ន្ធជាមួយនឹងជនដែលមានសញ្ជាតិខ្មែរ។ ច្បាប់ព្រហ្មទណ្ឌកម្ពុជាដែលអនុវត្តន៍តាមគោលការណ៍សញ្ជាតិនេះ គឺសំដៅទៅលើបទល្មើសដែលមានជនល្មើសមានសញ្ជាតិខ្មែរ ឬជនរងគ្រោះមានសញ្ជាតិខ្មែរ ដែលរងគ្រោះពីការបំពាបំពានពីជនបរទេសដទៃទៀត។

### ២.១.១ បទល្មើសដែលមានជនល្មើសជាពលរដ្ឋខ្មែរ

ក្នុងករណីដែលជនល្មើសជាពលរដ្ឋខ្មែរ ច្បាប់កម្ពុជាត្រូវអនុវត្ត លើគ្រប់បទឧក្រិដ្ឋទាំងអស់ដែលប្រព្រឹត្តដោយជននោះ។ ប្រសិនបើបទល្មើសមជ្ឈិមវិញ ច្បាប់កម្ពុជាត្រូវយកទៅអនុវត្តបានលុះត្រាតែអំពើនោះត្រូវបានផ្តន្ទាទោសតាមច្បាប់នៃប្រទេសដែលបទល្មើសនោះបានកើតឡើងផងដែរ[២៧]។

ករណីបទល្មើសដែលមានជនល្មើសជាពលរដ្ឋខ្មែរ តែងតែកើតមានឡើងជាពិសេសនៅប្រទេសថៃ ដែលជាប្រទេសក្បែរខាងរបស់កម្ពុជា ហើយចំពោះនីតិវិធីវិញ នៅពេលដែលមានពលរដ្ឋកម្ពុជាណាមួយបានប្រព្រឹត្តបទល្មើសនៅក្នុងទឹកដីថៃ ជាទូទៅកម្ពុជាតែងតែយកសន្ធិសញ្ញាស្តីពីបត្យាប័នដែលកម្ពុជាបានយកមកអនុវត្តន៍ ដើម្បីសុំយកពលរដ្ឋខ្មែរដែលបានប្រព្រឹត្តបទល្មើសមកទឹកដីកម្ពុជាវិញ។ បទល្មើសដែលប្រព្រឹត្តដោយពលរដ្ឋខ្មែរជាទូទៅគឺការឆ្លងដែនខុសច្បាប់ដើម្បីទៅធ្វើការ ឬទៅកាប់ឈើខុសច្បាប់ជាដើម។

កាលពីពេលកន្លងទៅពលរដ្ឋខ្មែរ ១០នាក់ ក្នុងចំណោម ១៩នាក់ ត្រូវបានអាជ្ញាធរថៃចាប់ខ្លួននៅថ្ងៃទី ១៤ ខែឧសភា ឆ្នាំ២០១៧ ពេលដែលពួកគេឆ្លងដែនទៅកាប់ឈើគ្រញូង នៅឧទ្យានជាតិប៉ាងស៊ីដា ស្ថិតនៅភូមិណយ ឃុំថាយែក ស្រុកមឿងសាកែវ ខេត្តសាកែវ ប្រទេសថៃ។ ក្រោយការសម្របសម្រួលពីមន្ត្រីនៅស្ថានអគ្គកុងស៊ុលខ្មែរនៅខេត្តស្រះកែវ អាជ្ញាធរថៃ ក៏បានដោះលែងពួកគេវិញនៅថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៧ ដោយទាមទារឱ្យបង់ការផាកពិន័យក្នុងម្នាក់ៗ ២៥០០ (ពីរពាន់ប្រាំរយ) បាត ពីបទឆ្លងដែនខុសច្បាប់។ នៅពេលបញ្ជូនមកដល់ទឹកដីកម្ពុជាវិញ ដោយមានការយោគយល់ពីអំពីកម្រិតចំណេះដឹង និងជីវភាព អាជ្ញាធរដែលជាមន្ត្រីជំនាញ បានធ្វើការអប់រំ

(២៧) មាត្រា ១៩ នៃក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ២០០៩

ដល់ពលរដ្ឋខ្មែរទាំង ១០នាក់នោះ ឱ្យបញ្ឈប់ការលួចឆ្លងដែនខុសច្បាប់ទៅកាប់ឈើបែបនេះបន្តទៀត[២៨]។

ករណីស្រដៀងគ្នានេះដែរ ពលករខ្មែរ១៧នាក់ ត្រូវបាននគរបាលសមុទ្រវៀតណាមឃាត់ខ្លួន ពេលកំពុងធ្វើសកម្មភាពដឹកជញ្ជូន និងជួញដូរ ប្រេងខុសច្បាប់លើនាវារបស់ថៃ និងវៀតណាម នៅក្នុងដែនសមុទ្រវៀតណាម។ នៅពេលចាប់ខ្លួន ពួកគេត្រូវបានអាជ្ញាធរវៀតណាមធ្វើការឃុំខ្លួនបណ្តោះអាសន្ននៅលើកោះ ភូគុក (កោះត្រល់) ខេត្ត កៀងយ៉ាង ប្រទេសវៀតណាម។ ក្រោយពេលទទួលបានដំណឹងពីការឃាត់ខ្លួននេះ ស្ថានអគ្គកុងស៊ុលកម្ពុជាប្រចាំទីក្រុងហូជីមិញ បានចុះទៅសម្របសម្រួលជាមួយអាជ្ញាធរវៀតណាម ដើម្បីជួយឱ្យពួកគេបានត្រលប់មកកម្ពុជាវិញ[២៩]។

មិនមែនគ្រប់អំពើល្មើស ដែលមានជនល្មើសជាពលរដ្ឋខ្មែរ សុទ្ធតែត្រូវយកច្បាប់ព្រហ្មទណ្ឌកម្ពុជា ឆ្នាំ២០០៩ យកទៅអនុវត្តនោះទេ។ យោងតាមមាត្រា ១៩ នៃក្រមនេះបានអនុញ្ញាតឱ្យយកច្បាប់ព្រហ្មទណ្ឌទៅអនុវត្តលើជនល្មើសជាពលរដ្ឋខ្មែរ ក្នុងករណីដែលអំពើល្មើសនេះ គឺជាបទឧក្រិដ្ឋ ឬមជ្ឈិមតែប៉ុណ្ណោះ។

### ២.១.១.១ ករណីបទឧក្រិដ្ឋ

នៅក្នុងករណីនេះ គឺមានន័យថានៅពេលដែលពលរដ្ឋខ្មែរណាម្នាក់បានប្រព្រឹត្តអំពើណាមួយនៅលើទឹកដីនៃរដ្ឋបរទេស ហើយអំពើនោះត្រូវបានច្បាប់ព្រហ្មទណ្ឌកម្ពុជាបានចាត់ទុកថាជាបទឧក្រិដ្ឋ ដូច្នេះច្បាប់ព្រហ្មទណ្ឌកម្ពុជាគឺមានអានុភាពអនុវត្តទៅលើជនល្មើសដែលជាពលរដ្ឋខ្មែរ ទោះបីជាអំពើនោះពុំត្រូវបានច្បាប់ព្រហ្មទណ្ឌបរទេសកំណត់ថាជាបទល្មើសក៏ដោយ។

### ២.១.១.២ ករណីបទមជ្ឈិម

នៅក្នុងករណីដែលពលរដ្ឋខ្មែរណាម្នាក់បានប្រព្រឹត្តអំពើល្មើសណាមួយជាបទមជ្ឈិមនៅលើទឹកដីនៃរដ្ឋបរទេស ច្បាប់ព្រហ្មទណ្ឌកម្ពុជាក៏មានអានុភាពអនុវត្តទៅលើជនល្មើសជាពលរដ្ឋខ្មែរនោះបានដែរ ប៉ុន្តែករណីដែលអំពើនោះក៏ត្រូវបានច្បាប់ព្រហ្មទណ្ឌបរទេសកំណត់ថាជាបទល្មើសហើយត្រូវបានផ្តន្ទាទោសដែរ។ ឧទាហរណ៍៖ ករណីបទល្មើសរួមភេទជាមួយនឹងញាតិលោហិត ឬញាតិពន្ធ[៣០]ដែលច្បាប់ព្រហ្មទណ្ឌកម្ពុជាកំណត់ថាជាបទល្មើសមជ្ឈិមនឹងត្រូវផ្តន្ទាទោសពី ១ (មួយ) ខែ ទៅ១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ២.០០០.០០០ (ពីរលាន) រៀល។ ប្រសិនបើពលរដ្ឋខ្មែរណាម្នាក់បានប្រព្រឹត្តបទល្មើសនេះ លើទឹកដីនៃរដ្ឋបរទេសណាមួយ

(២៨) http://www.freshnewsasia.com/index.php/en/localnews/55301-2017-05-19-02-40-07.html

(២៩) http://www.freshnewsasia.com/index.php/en/localnews/56373-2017-05-31-11-32-05.html

(៣០) មាត្រា ៣៥១ នៃក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ២០០៩

ហើយរដ្ឋបរទេសនោះមិនបានកំណត់អំពើរួមភេទជាមួយញាតិលោហិត ឬញាតិពន្ធថាជាបទល្មើស នោះទេ ដូច្នេះច្បាប់ព្រហ្មទណ្ឌកម្ពុជាក៏គ្មានអានុភាពអនុវត្តទៅលើជនប្រព្រឹត្ត ដែលជាពលរដ្ឋខ្មែរ នោះបានដែរ ប៉ុន្តែក្នុងករណីដែលច្បាប់នៃរដ្ឋដែលអំពើនោះបានកើតឡើង កំណត់ថាជាបទល្មើស និងត្រូវផ្តន្ទាទោសដែរនោះ ដូច្នេះច្បាប់ព្រហ្មទណ្ឌកម្ពុជាគឺមានអានុភាពអនុវត្តលើជនដែលបាន ប្រព្រឹត្តអំពើនោះ។

សូមបញ្ជាក់ថានៅក្នុងករណីទាំងពីរខាងលើនេះ (បទល្មើសដែលប្រព្រឹត្តដោយពលរដ្ឋខ្មែរ ក្នុងករណីបទឧក្រិដ្ឋ និងបទល្មើសដែលប្រព្រឹត្តដោយពលរដ្ឋខ្មែរក្នុងករណីបទមជ្ឈិម) បទប្បញ្ញត្តិ នៃមាត្រា១៩[៣១] នៃក្រមព្រហ្មទណ្ឌកម្ពុជា ក៏យកអនុវត្តបានដែរ បើទោះបីជាជនជាប់ចោទបានទទួល សញ្ជាតិខ្មែរក្រោយអំពើដែលបានចោទប្រកាន់នោះក៏ដោយ។

## ២.១.២ បទល្មើសដែលមានជនរងគ្រោះជាពលរដ្ឋខ្មែរ

ក្នុងករណីដែលជនរងគ្រោះជាពលរដ្ឋខ្មែរ ច្បាប់កម្ពុជាត្រូវយកទៅអនុវត្តលើគ្រប់បទឧក្រិដ្ឋ ដែលប្រព្រឹត្តនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា ទោះបីជាជនល្មើសជាជនបរទេស ឬជា ពលរដ្ឋខ្មែរក៏ដោយ[៣២]។ ឧទាហរណ៍៖ មាននារីខ្មែរម្នាក់រងគ្រោះដោយសារអំពើរំលោភបំពានផ្លូវភេទ ពីបុរសជនជាតិខ្មែរម្នាក់ និងបុរសជាជាតិថៃម្នាក់ នៅប្រទេសថៃ ក្នុងករណីនេះនារីរងគ្រោះដែលជា ជនជាតិខ្មែរអាចធ្វើការដាក់ពាក្យប្តឹងនៅអយ្យការអមសាលាដំបូងនៃព្រះរាជាណាចក្រកម្ពុជា ហើយ ត្រូវយកច្បាប់ព្រហ្មទណ្ឌកម្ពុជាអនុវត្តផងដែរ។ ក្នុងករណីដែលមានជនរងគ្រោះជាពលរដ្ឋខ្មែរនេះ ច្បាប់ព្រហ្មទណ្ឌអាចយកទៅអនុវត្តបានចំពោះតែអំពើដែលជាបទឧក្រិដ្ឋតែប៉ុណ្ណោះ។

### ២.១.២.១ ករណីបទឧក្រិដ្ឋ

តាមមាត្រា ២០ នៃក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ២០០៩ បានបញ្ញត្តិថា "**ក្នុងរឿងព្រហ្មទណ្ឌ ច្បាប់ កម្ពុជាត្រូវបានអនុវត្តទៅលើគ្រប់បទឧក្រិដ្ឋ ដែលប្រព្រឹត្តនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា ដោយពលរដ្ឋខ្មែរ ឬដោយជនបរទេស ទៅលើជនរងគ្រោះដែលមានសញ្ជាតិខ្មែរ នៅក្នុងពេលដែល បទល្មើសត្រូវបានប្រព្រឹត្ត**" នៅក្នុងករណីនេះ គឺច្បាប់ព្រហ្មទណ្ឌមានចែងសម្រាប់តែបទឧក្រិដ្ឋដែល មានពលរដ្ឋខ្មែរជាជនរងគ្រោះតែប៉ុណ្ណោះ ចំពោះបទមជ្ឈិម និងលហុគឺមិនអាចអនុវត្តបានទេ។

(៣១) មាត្រា ១៩ បទឧក្រិដ្ឋ ឬបទមជ្ឈិមដែលប្រព្រឹត្តដោយពលរដ្ឋខ្មែរ
(៣២) មាត្រា ២០ នៃក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ២០០៩

### ២.១.៣ លក្ខខណ្ឌនៃការចោទប្រកាន់

ចំពោះលក្ខខណ្ឌនៃការចោទប្រកាន់ចំពោះករណីទាំងពីរខាងលើ **(បទល្មើសដែលមានជនល្មើសជាពលរដ្ឋខ្មែរ និងបទល្មើសដែលមានជនរងគ្រោះជាពលរដ្ឋខ្មែរ)** អាចធ្វើទៅបានលុះត្រាតែមានបណ្ដឹងពីជនរងគ្រោះ ឬពីសិទ្ធិវន្ត[៣៣] ឬក៏បណ្ដឹងបរិហារ[៣៤]ជាផ្លូវការរបស់អាជ្ញាធរនៃប្រទេសដែលជាទីកន្លែងដែលអំពើនោះបានប្រព្រឹត្ត។ ការចោទប្រកាន់អាចប្រព្រឹត្តទៅបានតាមបណ្ដឹងរបស់អង្គការអយ្យការតែប៉ុណ្ណោះ។

## ២.២ បទល្មើសដែលប្រឆាំងនឹងកម្ពុជា

នៅក្នុងវិទ្យាសាស្ត្រព្រហ្មទណ្ឌ បទល្មើសប្រឆាំងនឹងជាតិគឺជាសកម្មភាពដែលប្រឆាំងទៅលើរដ្ឋាភិបាល ឬក៏ប្រទេសណាមួយ ដូចជាការទម្លាយការសម្ងាត់របស់រដ្ឋ ការធ្វើសកម្មភាពដែលប៉ះពាល់ដល់សុវត្ថិភាពរដ្ឋ បូរណភាពទឹកដី សន្តិសុខ និងអត្តសញ្ញាណរបស់រដ្ឋជាដើម។

ដោយសារតែកម្ពុជាជារដ្ឋមានអធិបតេយ្យ និងឯករាជ្យពេញលេញ ព្រមទាំងមានសិទ្ធិ និងស្វ័យភាពគ្រប់គ្រាន់ដើម្បីការពារខ្លួនស្របច្បាប់ នៅពេលដែលមានអំពើណាមួយធ្វើឱ្យប៉ះពាល់ដល់ផលប្រយោជន៍កម្ពុជា គឺច្បាប់ព្រហ្មទណ្ឌកម្ពុជានឹងមានអានុភាពអនុវត្តទៅលើជន ឬក្រុមដែលប្រព្រឹត្តអំពើនោះ។

នៅត្រង់មាត្រា ២២ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩ បានកំណត់នូវសកម្មភាពមួយចំនួនដែលចាត់ទុកថាជាបទល្មើសដែលច្បាប់ព្រហ្មទណ្ឌកម្ពុជាអាចនឹងមានវិសាលភាពអនុវត្តបានដែរ ដែលក្នុងនោះមានដូចជា៖

១ បទល្មើសប្រឆាំងនឹងសុវត្ថិភាពនៃព្រះរាជាណាចក្រកម្ពុជា។
២ បទល្មើសក្លែងត្រាផ្លូវការនៃព្រះរាជាណាចក្រកម្ពុជា។
៣ បទល្មើសក្លែងរូបិយវត្ថុ និងធនបត្រជាតិ ដែលមានតម្លៃស្របច្បាប់នៅព្រះរាជាណាចក្រកម្ពុជា។
៤ បទល្មើសប្រឆាំងនឹងភ្នាក់ងារទូត ឬកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជា។
៥ បទល្មើសប្រឆាំងនឹងទីតាំងទូត ឬកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជា។

### ២.២.១ បទល្មើសដែលប្រឆាំងនឹងសុវត្ថិភាពនៃព្រះរាជាណាចក្រកម្ពុជា

ក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ២០០៩ ត្រង់គន្ថីទី៤ បានកំណត់នូវអំពើជាច្រើនដែលជាបទល្មើសប្រឆាំងនឹងសុវត្ថិភាពនៃព្រះរាជាណាចក្រកម្ពុជា ដោយក្នុងនោះរួមមានដូចជាអំពើបំពានដល់អង្គ

(៣៣) សិទ្ធិវន្ត គឺជាអ្នកមានសិទ្ធិណាមួយ អ្នកមានឧបនិស្ស័យនឹងអនុវត្តសិទ្ធិណាមួយ។
(៣៤) បណ្ដឹងបរិហារ គឺជាបណ្ដឹងដែលមានគោលបំណងលាតត្រដាងអំពីអត្ថិភាពនៃបទល្មើសណាមួយ។

ព្រះមហាក្សត្រ អំពើក្បត់ជាតិ ចារកម្ម ឧបឃាត ការរួមគំនិតក្បត់ កុបកម្ម ការដណ្តើមអំណាចបញ្ជា និងការបង្កើតកងកម្លាំងប្រដាប់អាវុធ ការប៉ះពាល់ដល់សន្តិសុខកងយោធពលខេមរភូមិន្ទ ការប៉ះពាល់ដល់ការសម្ងាត់នៃការការពារជាតិ ការប៉ះពាល់ដល់សន្តិសុខសាធារណៈ ការប៉ះពាល់ដល់អាជ្ញាធររបស់រដ្ឋ ការប៉ះពាល់ដល់សាសនារបស់រដ្ឋ ការប៉ះពាល់ដល់វិស័យយុត្តិធម៌ បទល្មើសទាក់ទងដល់ការឃុំឃាំង ការប៉ះពាល់ដល់ដំណើរការរដ្ឋបាលសាធារណៈដោយបុគ្គលសាធារណៈ និងបុគ្គល ឯកជន ការបំលាស់ទីបង្គោលព្រំដែន ការប៉ះពាល់ទំនុកចិត្តសាធារណៈ ការក្លែងបន្លំឯកសារ រូបិយវត្ថុ ឬរូបិយប័ណ្ណ ការក្លែងឯកសាររបស់អាជ្ញាធរសាធារណៈ ដែលមានដូចជាមូលបត្ររដ្ឋ ឬតែមប្រៃប្រៃសណីយ៍ ការក្លែងបន្លំសញ្ញាសម្គាល់របស់អាជ្ញាធរជាដើម។

កាលពីឆ្នាំ២០១៤ កន្លងទៅ មានករណីមួយបានកើតឡើង គឺក្រុមរណសិរ្សរំដោះជាតិខ្មែរ មានមូលដ្ឋាននៅប្រទេសដាណឺម៉ាក ដែលដឹកនាំដោយលោក សម សេរី បានព្យាយាមក្នុងការបង្កើតរដ្ឋាភិបាលខ្មែរនិរទេសមួយនៅបរទេស ដើម្បីប្រឆាំងជាមួយនឹងរដ្ឋាភិបាលស្របច្បាប់នៅក្នុងប្រទេសកម្ពុជា សកម្មភាពដែលក្រុមនេះធ្វើ ហើយដែលចាត់ទុកថាជាអំពោះប្រឆាំងនឹងកម្ពុជា ក៏ដូចជាប្រឆាំងនឹងរាជរដ្ឋាភិបាលនោះគឺការធ្វើសេចក្តីព្រាងរដ្ឋធម្មនុញ្ញារបស់ខ្លួន និងការបង្ហោះវីដេអូតាមប្រព័ន្ធអ៊ីនធឺណេត និងបានអំពាវនាវឱ្យពលរដ្ឋខ្មែរនៅក្រៅប្រទេសទាំងអស់ ចូលរួមជាមួយនឹងរដ្ឋាភិបាលនិរទេសរបស់ខ្លួន[៣៥]។ នៅក្នុងឆ្នាំ២០១៤ ដដែល មនុស្ស ១១នាក់ត្រូវបានចាប់ខ្លួន ដោយសង្ស័យថាមានជាប់ពាក់ព័ន្ធជាមួយនឹងចលនាបង្កើតរដ្ឋាភិបាលនិរទេសនេះ នៅក្នុងខែធ្នូ សមាជិក ១១នាក់របស់ក្រុមនេះត្រូវបានសាលាដំបូងរាជធានីភ្នំពេញផ្តន្ទាទោសឱ្យជាប់ពន្ធនាគារចាប់ពី ៥ឆ្នាំ ដល់ ៩ឆ្នាំពីបទរៀបចំផែនការក្បត់[៣៦]។

## ២.២.២ បទល្មើសក្លែងត្រាផ្លូវការនៃព្រះរាជាណាចក្រកម្ពុជា

ត្រាផ្លូវការរបស់ព្រះរាជាណាចក្រកម្ពុជាត្រូវបានកំណត់ក្នុងសាររាចរណ៍ស្តីពី នាមប្រទេស ទង់ជាតិ ភ្លេងជាតិ និងព្រះឆាយាលក្ខណ៍ ចុះថ្ងៃទី២ ខែកក្កដា ឆ្នាំ១៩៩៣ និងសេចក្តីសម្រេចលេខ ១២ សសរ ស្តីពីការឆ្លាក់ និងប្រើប្រាស់ត្រា របស់ក្រសួង ស្ថាប័ន រដ្ឋអំណាច គ្រប់ជាន់ថ្នាក់ ចុះថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ១៩៩៣។ ត្រាផ្លូវការរបស់ក្រសួង ស្ថាប័ននីមួយត្រូវមានរូបភាពប្រាសាទកំពូលបីជុំវិញរង្វង់ ដែលសរសេរអក្សរឈ្មោះកម្ពុជានៅខាងលើ និងឈ្មោះអង្គភាពនៅខាងក្រោម[៣៧]។

ត្រង់ផ្នែកទី២ ជំពូកទី២ នៃក្រមព្រហ្មទណ្ឌកម្ពុជា គឺបានកំណត់អំពីទណ្ឌកម្មចំពោះបទល្មើសទាក់ទងជាមួយនឹងការក្លែងត្រាផ្លូវការនៃព្រះរាជាណាចក្រកម្ពុជា និងក្រដាសដែលមានក្បាលលិខិតផ្លូវការ ដោយនៅក្នុងនោះ **បទក្លែងត្រាផ្លូវការរបស់ព្រះរាជាណាចក្រកម្ពុជា** ត្រង់មាត្រា ៦៦១ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ចាប់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល។ សម្រាប់**បទប្រើប្រាស់ត្រាក្លែង** ត្រង់មាត្រា

(៣៥) http://www.freshnewsasia.com/index.php/en/1363-2015-01-26-04-59-39

(៣៦) http://www.cambodiadailykhmer.com/37463

(៣៧) ប្រការ១ សេចក្តីសម្រេចលេខ ១២ សសរ ស្តីពីការឆ្លាក់ និងប្រើប្រាស់ត្រា របស់ក្រសួង ស្ថាប័ន រដ្ឋអំណាច គ្រប់ជាន់ថ្នាក់

៦៦២ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ហើយក៏មានទោសបន្ថែម[៣៨]ចំពោះបទល្មើសទាំងពីរនេះទៀតដែរ ដែលមានដូចជា ការដកសិទ្ធិជាពលរដ្ឋខ្មែរជាស្ថាពរ ឬរយៈពេលកំណត់ណាមួយ ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ ការហាមឃាត់ចំពោះការស្នាក់នៅ ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុណាមួយ ដែលប្រើសម្រាប់ប្រព្រឹត្តបទល្មើស និងទោសបន្ថែមមួយចំនួនផ្សេងទៀត។ ចំពោះការប៉ុនប៉ងទាក់ទងជាមួយនឹងបទល្មើសទាំងពីរនេះ **(បទក្លែងត្រាផ្លូវការរបស់ព្រះរាជាណាចក្រកម្ពុជា) (បទប្រើប្រាស់ត្រាក្លែង)** ក៏ត្រូវកំណត់ថាជាបទល្មើសដែរ នេះដោយផ្អែកតាមមាត្រា ៦៦៦ នៃក្រមព្រហ្មទណ្ឌ។

### ២.២.៣ បទល្មើសក្លែងរូបិយវត្ថុ និងធនបត្រជាតិ ដែលមានតម្លៃស្របច្បាប់នៅកម្ពុជា

រូបិយវត្ថុគឺជាឧបករណ៍សម្រាប់ជួញដូរ រដ្ឋនីមួយៗគឺមានរូបិយវត្ថុរបស់ខ្លួន សម្រាប់កម្ពុជាក៏មានរូបិយវត្ថុផ្ទាល់ខ្លួនដែរគឺ "រៀល"។ បច្ចុប្បន្នរូបិយវត្ថុកម្ពុជាមានចំនួនដប់ប្រភេទនៅក្នុងចរាចរណ៍គឺប្រភេទក្រដាស ១០០.០០០ (មួយរយពាន់) រៀល ៥០.០០០ (ហាសិបពាន់) ២០.០០០ (ម្ភៃពាន់) ១០.០០០ (ដប់ពាន់) ៥.០០០ (ប្រាំពាន់) ២.០០០ (ពីរពាន់) ១.០០០ (មួយពាន់) ៥០០ (ប្រាំរយ) និង ១០០ (មួយរយ) រៀល[៣៩]។ អាជ្ញាធរដែលមានសិទ្ធិផ្តាច់មុខក្នុងការបោះពុម្ពរូបិយវត្ថុរបស់កម្ពុជាគឺធនាគារជាតិ បន្ទាប់ពីមានការអនុញ្ញាតពីរាជរដ្ឋាភិបាលតាមរយៈអនុក្រឹត្យ។ ចំពោះអ្នកដែលក្លែងបន្លំរូបិយវត្ថុ និងធនបត្រជាតិដែលមានតម្លៃនីត្យានុកូលនៃព្រះរាជានឹងត្រូវបានផ្តន្ទាទោស ដែលមានកំណត់ក្នុងក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ២០០៩ ចាប់ពីមាត្រា ៦៥៤ ដល់មាត្រា៦៦០។

មាត្រា ៦៤៥ បានបញ្ញត្តិថា "**ការក្លែងបន្លំក្រដាសប្រាក់ ឬកាសដែលជារូបិយវត្ថុដែលមានតម្លៃនីត្យានុកូលនៅព្រះរាជាណាចក្រកម្ពុជា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១៥ (ដប់ប្រាំ) ឆ្នាំទៅ ៣០ (សាមសិប) ឆ្នាំឬអស់មួយជីវិត**"។

មាត្រា ៦៤៦ "**ការបន្លំរូបិយបណ្ណដែលមានតម្លៃនីត្យានុកូល ដែលបោះពុម្ពផ្សាយដោយស្ថាប័នបរទេស ឬអន្តរជាតិ ដែលមាននីតិសម្បទា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់) ឆ្នាំទៅ ២០ (ម្ភៃ) ឆ្នាំ**"។

មាត្រា ៦៤៧ "**ការដាក់ឱ្យធ្វើចរាចរណ៍រូបិយវត្ថុ ឬរូបិយបណ្ណក្លែងដែលមានចែងក្នុងមាត្រា ៦៤៥ (បទក្លែងបន្លំរូបិយវត្ថុដែលមានតម្លៃនីត្យានុកូល) និងមាត្រា ៦៤៦ (បទក្លែងបន្លំរូបិយបណ្ណដែលមានតម្លៃនីត្យានុកូល) នៃក្រមព្រហ្មទណ្ឌត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំទៅ ១០ (ដប់) ឆ្នាំ**"។

(៣៨) មាត្រា ៦៦៧ នៃក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ២០០៩

(៣៩) https://www.nbc.org.kh/payment_systems/cash_and_checks.php

មាត្រា ៦៤៨ "**អំពើដឹកជញ្ជូន ឬ សន្និធិរូបិយវត្ថុ ឬ រូបិយបណ្ណក្លែងដែលមានចែងក្នុងមាត្រា ៦៤៥ (បទក្លែងបន្លំរូបិយបណ្ណដែលមានតម្លៃនីត្យានុកូល) និងមាត្រា ៦៤៦ (បទក្លែងបន្លំរូបិយបណ្ណដែលមានតម្លៃនីត្យានុកូល) ដើម្បីយកទៅដាក់ឱ្យចរាចរណ៍ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំទៅ ១០ (ដប់) ឆ្នាំ។ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់) ឆ្នាំទៅ ២០ (ម្ភៃ) ឆ្នាំ កាលបើបទល្មើសនេះបានប្រព្រឹត្តជាក្រុមមានការចាត់តាំង**"។

មាត្រា ៦៤៩ "**ការក្លែងរូបិយវត្ថុ និងរូបិយបណ្ណដែលអស់តម្លៃនីត្យានុកូលនោះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំទៅ ៣ (បី) ឆ្នាំនិងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៦.០០០.០០០ (ប្រាំមួយលាន) រៀល**"។

មាត្រា ៦៥០ "**ការកាន់កាប់ដោយគ្មានការអនុញ្ញាតនូវឧបករណ៍ និងសម្ភារៈដែលជាពិសេសសម្រាប់ធ្វើរូបិយវត្ថុ ឬរូបិយបណ្ណ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំទៅ ១០ (ដប់) ឆ្នាំ**"។

មាត្រា ៦៥១ "**អំពើរបស់បុគ្គលណាដែលទទួលរូបិយវត្ថុ ឬ រូបិយបណ្ណក្លែងដែលមានចែងក្នុងមាត្រា ៦៤៥ (បទក្លែងរូបិយវត្ថុដែលមានតម្លៃនីត្យានុកូល) និងមាត្រា ៦៤៦ (បទក្លែងបន្លំរូបិយបណ្ណដែលមានតម្លៃនីត្យានុកូល) នៃក្រមព្រហ្មទណ្ឌនេះ ដោយគិតថាជារូបិយវត្ថុ ឬ រូបិយបណ្ណពិត ហើយយកទៅដាក់ឱ្យធ្វើចរាចរណ៍ជាថ្មី ក្រោយពីបានដឹងថាជារបស់ក្លែងនោះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ថ្ងៃ ទៅ ៦ (ប្រាំមួយ) ថ្ងៃ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល**"។

ក្រៅពីទោសដែលបានកំណត់ខាងលើនេះក៏មានទោសបន្ថែមផងដែរ ដែលមានចែងក្នុងមាត្រា ៦៥២ ដែលមានដូចជា៖

- ការដកសិទ្ធិពលរដ្ឋ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំយ៉ាងច្រើន។
- ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈ កាលបើបទល្មើសនោះបានប្រព្រឹត្តនៅក្នុងការប្រកបវិជ្ជាជីវៈ ឬ នៅក្នុងឱកាសនៃការប្រកបវិជ្ជាជីវៈនេះជាស្ថាពរ ឬសម្រាប់រយៈពេល៥ (ប្រាំ) ឆ្នាំយ៉ាងច្រើន។
- ហាមឃាត់ចំពោះការស្នាក់នៅ សម្រាប់រយៈពេល ១០ (ដប់) ឆ្នាំយ៉ាងច្រើនចំពោះបទឧក្រិដ្ឋ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំយ៉ាងច្រើនចំពោះបទមជ្ឈិម។
- ការរឹបអូសឧបករណ៍ សម្ភារៈ ឬ វត្ថុណាមួយ ដែលប្រើសម្រាប់ប្រព្រឹត្តបទល្មើស ឬ ដែលមានគោលដៅប្រព្រឹត្តបទល្មើស។
- ការរឹបអូសវត្ថុ ឬ មូលនីធិដែលជាកម្មវត្ថុនៃបទល្មើស។
- ការរឹបអូសផលទុន ឬ ទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស។

- ការរឹបអូសយានជំនិះរបស់ទណ្ឌិតមួយគ្រឿង ឬ ច្រើនគ្រឿង។
- ការហាមឃាត់ចំពោះការកាន់កាប់ ឬ ការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ ជាស្ថាពរ ឬ សម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំយ៉ាងច្រើន។
- ការបិទផ្សាយសេចក្តីផ្តន្ទាទោស សម្រាប់រយៈពេល ២ (ពីរ) ខែយ៉ាងច្រើន។
- ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន។
- ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃយ៉ាងច្រើន។

នៅក្នុងបទល្មើសខាងលើនេះ ក៏មានលក្ខខណ្ឌដែលអាចលើកលែងឱ្យរួចផុតពីទោសដែរ ដែលមានចែងក្នុងមាត្រា ៦៥២ ដែលបានបញ្ញត្តិថា "**បុគ្គលណាដែលបានប៉ុនប៉ងប្រព្រឹត្តបទល្មើសណាមួយ ក្នុងចំណោមបទល្មើសដែលមានចែងក្នុងផ្នែកនេះ នឹងត្រូវបានលើកលែងឱ្យរួចផុតពីទោស ប្រសិនបើបុគ្គលនោះ បានធ្វើឱ្យបទល្មើសនោះមិនបានសម្រេច និងនាំឱ្យដឹងពីអត្តសញ្ញាណជាយថាហេតុរបស់ជនល្មើសផ្សេងទៀត ដោយបានឱ្យដំណឹងដល់អាជ្ញាធររដ្ឋបាល ឬតុលាការ**"។

## ២.២.៤ បទល្មើសប្រឆាំងភ្នាក់ងារទូត ឬកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជា

រដ្ឋអធិបតេយ្យមានសិទ្ធិសកម្ម និងអកម្ម នៃការទូត គឺអាស្រ័យទៅលើការមានសិទ្ធិ ដើម្បីបញ្ជូលភ្នាក់ងារការទូតទៅរដ្ឋផ្សេងទៀត និងទទួលតំណាងរដ្ឋនានា នៅក្នុងប្រទេសរៀងៗខ្លួន។ អនុសញ្ញាទីក្រុងវីយ៉ែន ស្តីពីទំនាក់ទំនងការទូត ឆ្នាំ១៩៦១ បានដោះស្រាយបញ្ហាជាក់ស្តែងនៅក្នុងប្រការ ២ ដែលបានចែងថា "**ការបង្កើតទំនាក់ទំនងការទូតរវាងរដ្ឋ និងបេសកម្មការទូតអចិន្ត្រៃយ៍ កើតឡើងដោយសារការយល់ព្រមទៅវិញទៅមក**"។ ភ្នាក់ងារទូតគឺជាអ្នកតំណាងឱ្យប្រទេស ដូច្នេះនៅពេលដែលមានបញ្ហាអ្វីកើតឡើងចំពោះភ្នាក់ងារនោះ ក៏ដូចជាប៉ះពាល់ជាមួយនឹងរដ្ឋដែលជាអ្នកបញ្ជូនភ្នាក់ងារនោះដែរ។ ប្រការ ២៩ នៃអនុសញ្ញាក្រុងវីយ៉ែន បានចែងថា "**បុគ្គលភ្នាក់ងារទូតមិនអាចត្រូវបំពារបំពានបានទេ។ ភ្នាក់ងារទូតមិនអាចត្រូវចាប់ឬឃុំខ្លួនតាមបែបណាមួយបានឡើយ។ រដ្ឋម្ចាស់ផ្ទះរាប់អានភ្នាក់ងារទូតដោយការគោរព និងត្រូវចាត់គ្រប់វិធានការសមស្រប ដើម្បីរារាំងមិនឱ្យមានការបំពារបំពានណាមួយលើរូបកាយ សេរីភាព និងភាពថ្លៃថ្នូររបស់គេ**"។ នៅក្នុងប្រការនេះ គឺចង់ឆ្លុះបញ្ចាំងពីការហាមឃាត់រដ្ឋម្ចាស់ផ្ទះមិនឲ្យចាប់ខ្លួន ឬឃុំខ្លួនភ្នាក់ងារទូត ហើយក៏ចង់បង្ហាញពីកាតព្វកិច្ចរបស់រដ្ឋម្ចាស់ផ្ទះក្នុងការការពារភ្នាក់ងារទូតកុំឱ្យមានការបំពារបំពាន។

### ២.២.៥ បទល្មើសប្រឆាំងនឹងទីតាំងទូត ឬកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជា

ទីស្ថានបេសកកម្មគឺជាដីធ្លី និងអគារដែលសម្រាប់បម្រើការដល់បេសកកម្មការទូត ដោយរាប់បញ្ចូលទាំងនិវេសដ្ឋានរបស់ប្រមុខបេសកកម្មការទូតនោះផងដែរ។ ប្រការ ២២ នៃអនុសញ្ញាទីក្រុងវីយែន ស្តីពីទំនាក់ទំនងការទូត ឆ្នាំ១៩៦១បានកំណត់ថា ទីស្ថានបេសកកម្មនេះពុំអាចត្រូវរដ្ឋម្ចាស់ផ្ទះបំពារបំពានបានឡើយ។ បណ្តាភ្នាក់ងាររបស់រដ្ឋម្ចាស់ផ្ទះ មិនអាចចូលទៅក្នុងទីស្ថានបេសកកម្មនោះ ដោយគ្មានការយល់ព្រមពីប្រមុខបេសកកម្មការទូតបានឡើយ។

# សេចក្តីសន្និដ្ឋាន

អស់រយៈពេលជិត ១០ឆ្នាំកន្លងមកនេះ ក្រមព្រហ្មទណ្ឌត្រូវបានយកទៅអនុវត្តយ៉ាងទូលំទូលាយ និងមានប្រសិទ្ធិភាពគួរឱ្យកត់សម្គាល់ ជាពិសេសការអនុវត្តក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា ដោយអំពើល្មើសជាច្រើនត្រូវបានទប់ស្កាត់ និងកាត់បន្ថយតាមរយៈការចាប់ជនល្មើសយកមកផ្តន្ទាទោស។ ទោះបីជាច្បាប់ព្រហ្មទណ្ឌកម្ពុជាបានកំណត់អំពីដែនអនុវត្តន៍ច្បាស់លាស់ក៏ដោយ ចំពោះការអនុវត្តនៅតែមានការខ្វះចន្លោះ ជាពិសេសទាក់ទងជាមួយនឹងវិស័យមួយចំនួនដែលព្រះរាជាណាចក្រកម្ពុជាមិនទាន់មានច្បាប់ជាតិផ្ទាល់ខ្លួនកំណត់ជាបទល្មើស និងទណ្ឌកម្ម ហើយបែរជាពឹងផ្អែកទៅលើការអនុវត្តតាមលិខិតបទដ្ឋានគតិយុត្តអន្តរជាតិនានា ដែលកម្ពុជាបានផ្តល់សច្ចាប័ន ក្នុងនោះមានបទល្មើសទាក់ទងជាមួយនឹងដែនសមុទ្រ និងដែនអាកាសជាដើម។

ច្បាប់ព្រហ្មទណ្ឌរបស់បណ្តារដ្ឋមួយចំនួន បានបើកទូលាយអំពីដែនអនុវត្តរបស់ខ្លួន ដោយក្នុងនោះមានដូចជា ដែនដី ដែនសមុទ្រ ដែនអាកាស នាវា អាកាសយាន និងករណីជាច្រើនទៀត។

ចំពោះច្បាប់ព្រហ្មទណ្ឌកម្ពុជា ពុំទាន់បានបញ្ញត្តិ អំពីបញ្ហាថាតើត្រូវអនុវត្តច្បាប់ព្រហ្មទណ្ឌកម្ពុជាណាមួយដើម្បីវិនិច្ឆ័យទៅលើបទល្មើសណាមួយដែលកើតមាន៖

- នៅលើនាវា ឬយន្តហោះបរទេសដែលកំពុងបើកបរ ហោះហើរ ក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា។
- បទល្មើសដែលកើតមាននៅលើអាកាសយាន ឬនាវាអន្តរជាតិ (បរទេស) ដែលកំពុងចតនៅកំពង់ផែ ឬអាកាសយានដ្ឋាន ក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា។
- បទល្មើសដែលកើតមានលើនាវា ឬអាកាសយានរបស់ព្រះរាជាណាចក្រកម្ពុជា ដែលកំពុងបើកបរ ឬហោះហើរនៅសមុទ្រអន្តរជាតិ ឬនៅពេលកំពុងចតនៅកំពង់ផែ ឬអាកាសយានដ្ឋានរបស់រដ្ឋបរទេស។
- បទល្មើសដែលកើតមាននៅក្នុងស្ថានទូត ឬស្ថានកុងស៊ុល នៃព្រះរាជាណាចក្រកម្ពុជា ដែលតាំងនៅរដ្ឋបរទេស ដោយឡែកច្បាប់ព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ក៏ពុំបានបញ្ញត្តិថាតើច្បាប់នេះមានឥទ្ធិពល អនុវត្តទៅលើករណីបទល្មើសដែលចាប់ផ្តើមប្រព្រឹត្តនៅក្នុងទឹកដីនៃព្រះរាជាណាចក្រកម្ពុជា តែបានបញ្ចប់នៅក្រៅដែនដីកម្ពុជា ឬចាប់ផ្តើមលើដែនដីបរទេស តែបានបញ្ចប់នៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា ឬបានចាប់ផ្តើម និងបញ្ចប់នៅបរទេស តែមានធាតុផ្សំខ្លះនៅកម្ពុជា លើកលែងតែច្បាប់ស្តីពីការបង្ក្រាបអំពើពង្រត់ និងលក់ដូរមនុស្ស និងអំពើអាជីវកម្មលើមនុស្ស ដែលជាច្បាប់មួយក្នុងចំណោមច្បាប់ព្រហ្មទណ្ឌកម្ពុជា បានបញ្ញត្តិក្នុងមាត្រា ២ ថា "**ត្រូវហាមឃាត់ដាច់ខាតអំពើ ពង្រត់មនុស្សយកទៅលក់**

**ដូរ ឬយកទៅធ្វើពេស្យាចារ និងអំពើធ្វើអាជីវកម្មលើមនុស្សនៅក្នុង ឬក្រៅទឹកដីនៃព្រះរាជាណាចក្រកម្ពុជា**”។

ជាទូទៅច្បាប់ព្រហ្មទណ្ឌរបស់បណ្តាប្រទេសជាច្រើនបានបញ្ញត្តិថា បទល្មើសដែលកើតមានឡើងនៅទីកន្លែងខាងលើត្រូវបានដោះស្រាយដោយច្បាប់ព្រហ្មទណ្ឌ របស់ប្រទេសដែលនាវា ឬអាកាសយានមានសញ្ជាតិ។

ជាគោលការណ៍ច្បាប់ព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា មានអានុភាពអនុវត្តទៅលើរាល់បទល្មើស ដែលកើតមានឡើងនៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា។ ជនល្មើសអាចជាពលរដ្ឋខ្មែរ ជនបរទេស ឬជនគ្មានសញ្ជាតិ ត្រូវទទួលការជំនុំជម្រះវិនិច្ឆ័យទោសដោយតុលាការ និងតាមច្បាប់ព្រហ្មទណ្ឌរបស់កម្ពុជា។ ដោយឡែកចំពោះជនបរទេសដែលមានអភ័យឯកសិទ្ធិ ឬមានសិទ្ធិផ្នែកការទូត ការអនុវត្តច្បាប់ព្រហ្មទណ្ឌកម្ពុជាមានការរារាំងដោយសន្ធិសញ្ញាអន្តរជាតិដែលទទួលស្គាល់អភ័យឯកសិទ្ធិនេះ។

បញ្ហាចោទចំពោះការអនុវត្តជាក់ស្តែងគឺថានៅមានភាពលំបាកចំពោះការអនុវត្ត ជាពិសេសបទល្មើសដែលមានធាតុផ្សំបរទេសចូលរួម ហេតុដូច្នេះហើយនាំឱ្យមានវិវាទនៃការអនុវត្តច្បាប់ព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាជាមួយនឹងច្បាប់ព្រហ្មទណ្ឌរបស់រដ្ឋដទៃទៀតកើតមានឡើង ព្រោះភាគីនីមួយៗសុទ្ធតែចង់ការពារផលប្រយោជន៍ពលរដ្ឋ ឬក៏ជាតិរបស់ខ្លួន៕

# អនុសាសន៍

ដើម្បីបង្ក្រាប និងទប់ស្កាត់បទល្មើសឱ្យកាន់តែមានប្រសិទ្ធិភាព ព្រមទាំងការពារសិទ្ធិដល់ពលរដ្ឋកម្ពុជាទាំងមូល រដ្ឋាភិបាលគួរតែធ្វើសេចក្ដីព្រាងច្បាប់ ឬក៏ស្នើច្បាប់ចំពោះបទល្មើសព្រហ្មទណ្ឌក្នុងវិស័យមួយចំនួនដែលកម្ពុជាមិនទាន់មាននៅឡើយ ព្រមទាំងធ្វើការផ្សព្វផ្សាយអំពីច្បាប់ទាំងនោះទៅកាន់ប្រជាពលរដ្ឋ ជាពិសេសគឺអ្នកអនុវត្តឱ្យបានយល់ដឹងច្បាស់អំពីការអនុវត្ត ជៀសវាងនៅពេលដែលមានច្បាប់ហើយ ប៉ុន្តែអ្នកអនុវត្តមិនមានការយល់ដឹង នោះនឹងធ្វើឱប៉ះពាល់ដល់ការអនុវត្តដដែល។

រដ្ឋាភិបាលគួរតែបង្កើតជាវិធានឱ្យបានច្បាស់លាស់ និងល្អិតល្អន់ ជាពិសេសទាក់ទងជាមួយនឹងការចុះបញ្ជី ក៏ដូចជាការផ្ដល់សញ្ជាតិដល់នាវា ឬក៏អាកាសយាន ដែលចង់មានសញ្ជាតិកម្ពុជា។

ការចុះកិច្ចព្រមព្រៀងជាមួយនឹងបណ្ដារដ្ឋដទៃក៏ជារឿងសំខាន់ ដើម្បីកំណត់ឱ្យបានច្បាស់លាស់ស្ដីពីការអនុវត្តច្បាប់ព្រហ្មទណ្ឌ។ ឧទាហរណ៍ដូចអ្វីដែលព្រះរាជាណាចក្រកម្ពុជាធ្លាប់ធ្វើគឺការចុះសន្ធិសញ្ញាស្ដីពីបត្យាប័នរវាងកម្ពុជាជាមួយនឹងព្រះរាជាណាចក្រថៃ ឆ្នាំ១៩៩៩ ជាមួយនឹងសាធារណរដ្ឋប្រជាមានិតចិន ឆ្នាំ២០០០ ជាមួយនឹងសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ឆ្នាំ២០០៥ ជាមួយនឹងសាធារណរដ្ឋកូរ៉េឆ្នាំ២០១០ និងជាមួយសាធារណរដ្ឋសង្គមនិយមវៀតណាម ឆ្នាំ២០១៤ និងអនុម័តយល់ព្រមលើសន្ធិសញ្ញាស្ដីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌជាដើម៕

# ឯកសារយោង

- **ច្បាប់ជាតិ**
  - រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
  - ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩
  - ច្បាប់ស្តីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាសមាជិកនៃអនុសញ្ញាស្តីពីការបង្ក្រាបអំពើខុសច្បាប់ទៅនឹងសុវត្ថិភាពនៃការធ្វើនាវាចរណ៍តាមដែនសមុទ្រ ឆ្នាំ២០០៥
  - ច្បាប់ស្តីពី ការអនុម័តយល់ព្រមលើសន្ធិសញ្ញា ស្តីពីបត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជានិងព្រះរាជាណាចក្រថៃ ឆ្នាំ១៩៩៩ សាធារណរដ្ឋប្រជាមានិតចិន ឆ្នាំ២០០០ សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវស្តីពីបត្យាប័ន ឆ្នាំ២០០៥
    សាធាណរដ្ឋកូរ៉េ ឆ្នាំ២០១០ សាធារណរដ្ឋសង្គមនិយមវៀតណាម ឆ្នាំ២០១៤
  - ច្បាប់ស្តីពីអាកាសចរណ៍ស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- **ច្បាប់អន្តរជាតិ**
  - សន្ធិសញ្ញាស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ
  - អនុសញ្ញាទីក្រុងវីយែន ឆ្នាំ១៩៦១ ស្តីពីទំនាក់ទំនងការទូត
  - អនុសញ្ញាអង្គការសហប្រជាតិស្តីពីនីតិសមុទ្រ
  - អនុសញ្ញាស្តីពីការបង្ក្រាបអំពើខុសច្បាប់ទៅនឹងសុវត្ថិភាពនៃការធ្វើនាវាចរណ៍តាមដែនសមុទ្រ
- **ឯកសារផ្សេងៗ**
  - សេចក្តីថ្លែងហេតុនៃសេចក្តីព្រាងច្បាប់ ស្តីពី "ក្រមព្រហ្មទណ្ឌ" ឆ្នាំ២០០៩
  - សៀវភៅនីតិព្រហ្មទណ្ឌខ្មែរ សាស្ត្រាចារ្យ **រុន ពណ្ណារិទ្ធ** និងសាស្ត្រាចារ្យ **ចាំង ស៊ីណាត** ឆ្នាំ២០១២
  - កម្មវិធីផ្សព្វផ្សាយច្បាប់ស្តីពី "ក្រមព្រហ្មទណ្ឌ" នៃព្រះរាជាណាចក្រកម្ពុជា របស់ទូរទស្សន៍ជាតិកម្ពុជា
  - សៀវភៅនីតិសមុទ្រ សាស្ត្រាចារ្យ **សំរ៉ង រិទ្ធីវង្ក**
  - សៀវភៅទំនាក់ទំនងអន្តរជាតិ និងច្បាប់ការទូត សាស្ត្រាចារ្យបណ្ឌិត **វ៉ាន់ ច័ន្ទមករា** បោះពុម្ពឆ្នាំ២០១៣
  - សៀវភៅមេរៀន នីតិព្រហ្មទណ្ឌខ្មែរ របស់រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ឆ្នាំ២០០៨
  - សៀវភៅនីតិអន្តរជាតិសាធារណៈ សាស្ត្រាចារ្យបណ្ឌិត **វ៉ាន់ ច័ន្ទតារា** ឆ្នាំ២០១៤

# ឧបសម្ព័ន្ធ

| |
|---|
| • ច្បាប់ស្តីពីការអនុម័តយល់ព្រមលើសន្ធិសញ្ញាស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ |
| • ព្រះរាជក្រមស្តីពីការប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រម ឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាសមាជិកនៃអនុសញ្ញាស្តីពីការបង្ក្រាបអំពើខុសច្បាប់ទៅនឹងសុវត្ថិភាពនៃការធ្វើនាវាចរណ៍តាមដែនសមុទ្រ |
| • ប្រការមួយចំនួនក្នុងអនុសញ្ញាទីក្រុងវីយែនឆ្នាំ១៩៦១ ស្តីពីទំនាក់ទំនងការទូត |
| • សេចក្តីសម្រេចលេខ ១២ សសរ ស្តីពីការឆ្លាក់ និងប្រើប្រាស់ត្រារបស់ក្រសួង ស្ថាប័ន រដ្ឋអំណាចគ្រប់ជាប់ថ្នាក់ |
| • សារាចរស្តីពីនាមប្រទេស ទង់ជាតិ ភ្លេងជាតិ និងព្រះឆាយាលក្ខណ៍ |
| • ព័ត៌មានស្តីពីព្រះរាជអាជ្ញាចោទប្រកាន់សមាជិករណសិរ្សរំដោះជាតិខ្មែរពីបទរៀបចំផែនការផ្តួលរំលំរដ្ឋាភិបាល (http://www.cambodiadailykhmer.com/14614) |
| • ព័ត៌មានស្តីពីការចាប់ខ្លួនមេខ្លោងក្នុងករណីឃាតកម្មនៅប្រទេសថៃ (http://www.cambodiadailykhmer.com/36542) |
| • អត្ថបទព័ត៌ស្តីពីព្រះរាជអាជ្ញាចោទប្រកាន់ជនបរទេសធ្វើចារកម្មនៅកម្ពុជា តាមមាត្រា៤៤៦ នៃក្រមព្រហ្មទណ្ឌ<br>• (http://www.freshnewsasia.com/index.php/en/localnews/57001-2017-06-09-08-21-22.html) |
| • អត្ថបទព័ត៌មានស្តីពីការឃុំខ្លួនជនជាតិវៀតណាមដែលបានមកកាប់ឈើខុសច្បាប់ក្នុងទឹកដីកម្ពុជា (http://ann.com.kh/blog/detail/825071052143452172323222448/index.html) |
| • អត្ថបទព័ត៌មានស្តីពីការចោទប្រកាន់អ្នកនេសាទវៀតណាម ១៦នាក់ ដែលមកនេសាទក្នុងទឹកដីកម្ពុជា |
| • សេចក្តីប្រកាសព័ត៌មានរបស់ក្រសួងការបរទេសស្តីពីពលរដ្ឋខ្មែរ ១៧នាក់ ដែលត្រូវបានអាជ្ញាធរវៀតណាមដោះលែងក្រោយពេលពួកគេដឹកជញ្ជូន និងជួញដូរប្រេងខុសច្បាប់នៅដែនសមុទ្រវៀតណាម |

ព្រះរាជក្រម

នស/រកម/០១១០/០០១

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរាជរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌

ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីការអនុម័តយល់ព្រមលើសន្ធិសញ្ញា ស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០៩ នាសម័យប្រជុំរដ្ឋសភាលើកទី៣ នីតិកាលទី៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី១៤ ខែមករា ឆ្នាំ២០១០ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភា លើកទី៦ នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុង ដូចតទៅនេះ:

ច្បាប់

ស្តីពី

## ការអនុម័តយល់ព្រមលើសន្ធិសញ្ញា
## ស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ

**មាត្រា ១.-**

អនុម័តយល់ព្រមលើសន្ធិសញ្ញាស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ ដែលបានចុះហត្ថលេខានៅកូឡាឡាំពួរ ប្រទេសម៉ាឡេស៊ី នាថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

**មាត្រា ២.-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្ទុករាល់នីតិវិធី ដើម្បីអនុវត្តសន្ធិសញ្ញានេះ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១០

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

៣/ល: ១០០១.០៧៣

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
**នាយករដ្ឋមន្ត្រី**
**ហត្ថលេខា**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
រដ្ឋមន្ត្រីក្រសួងយុត្តិធម៌
**ហត្ថលេខា**
**អង្គ វង្ស វឌ្ឍនា**

**លេខ: ៦៩ ច.ល**
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ខែ មករា ឆ្នាំ២០១០
**អគ្គលេខាធិការរាជរដ្ឋាភិបាល**
**ស៊ុន ជិនអេន**

# សន្ធិសញ្ញា
# ស្តីពី
# ការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់
# ក្នុងវិស័យព្រហ្មទណ្ឌ

# សន្ធិសញ្ញា
# ស្តីពី
# ការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ

រដ្ឋាភិបាលនៃបណ្តាប្រទេស ប្រ៊ុយណេដារ៉ូសាឡឹម ព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋឥណ្ឌូណេស៊ី សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ម៉ាឡេស៊ី សហភាពមីយ៉ាន់ម៉ា សាធារណរដ្ឋហ្វីលីពីន សាធារណរដ្ឋសិង្ហបុរី ព្រះរាជាណាចក្រថៃឡង់ដ៍ និងសាធារណរដ្ឋសង្គមនិយមវៀតណាម (ដែលចាប់ពីពេលនេះទៅហៅជាឯកវចនៈថា "ភាគី" និងជាពហុវចនៈ "បណ្តាភាគី") :

**មានបំណង** ដើម្បីកែលំអប្រសិទ្ធភាពរបស់អាជ្ញាធរអនុវត្តច្បាប់នៃបណ្តាភាគី ក្នុងការទប់ស្កាត់ ការស៊ើបអង្កេត និង ការចោទប្រកាន់បទល្មើស តាមរយៈកិច្ចសហប្រតិបត្តិការ និងការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ ។

**បានព្រមព្រៀង** ដូចតទៅ :

## មាត្រា ១
## វិសាលភាពនៃការជួយគ្នាទៅវិញទៅមក

១. ដោយយោងទៅតាមសន្ធិសញ្ញានេះ និង អនុលោមទៅតាមច្បាប់ក្នុងស្រុករបស់ភាគីរៀងៗខ្លួន បណ្តាភាគីនៅក្នុងទ្រង់ទ្រាយដ៏ធំបំផុតដែលអាចធ្វើបាន ត្រូវផ្តល់នូវវិធាននៃការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ ដូចជា ការស៊ើបអង្កេត ការចោទប្រកាន់ និង ដំណើរការរឿងក្តី ។

២. យោងតាមសន្ធិសញ្ញានេះ ជំនួយទៅវិញទៅមក ដែលត្រូវផ្តល់រួមមាន :

(ក). ការទទួលយកភស្តុតាង ឬ កំណត់ហេតុយកចម្លើយដោយស្ម័គ្រចិត្តពីជនណាមួយ

(ខ). ការរៀបចំឱ្យជនណាមួយ ផ្តល់ភស្តុតាង ឬ ជួយនៅក្នុងវិស័យព្រហ្មទណ្ឌ

(គ). ការចាត់ចែងសេវាឯកសារតុលាការ

(ឃ). ការអនុវត្តការឆែកឆេរ និង ការរឹបអូស

(ង). ការពិនិត្យលើវត្ថុ និងទីកន្លែង

(ច). ការផ្តល់ឯកសារ របាយការណ៍ ច្បាប់ដើម ឬ ច្បាប់ចម្លងដែលមានបញ្ជាក់ថាត្រឹមត្រូវ និងវត្ថុតាងពាក់ព័ន្ធ

(ឆ). ការកំណត់អត្តសញ្ញាណ ឬ តាមដានទ្រព្យសម្បត្តិទទួលបានមកពីការប្រព្រឹត្តបទល្មើស និងមធ្យោបាយនៃបទល្មើស

(ជ). ការរឹតត្បិតលើ ការលក់ដូរទ្រព្យសម្បត្តិ ឬការបង្កកថ្មីបទុកទ្រព្យសម្បត្តិ ដែលទទួលបានមកពីការប្រព្រឹត្តបទល្មើស ដែលអាចត្រូវយកមកវិញ រឹបអូស ឬ ដកហូត

(ឈ). ការយកមកវិញ ការរឹបអូស ឬ ការដកហូតទ្រព្យសម្បត្តិដែលទទួលបានមកពី ការប្រព្រឹត្តបទល្មើស

(ញ). កំណត់ទីតាំង និង កំណត់អត្តសញ្ញាណសាក្សី និង ជនសង្ស័យ និង

(ដ). ការផ្តល់ជំនួយបែបនេះផ្សេងដទៃទៀត បើមានការព្រមព្រៀងគ្នា និងស្របទៅនឹងវត្ថុបំណងរបស់ សន្ធិសញ្ញានេះ និង ច្បាប់របស់ភាគីទទួលសំណើ ។

៣. សន្ធិសញ្ញានេះ អនុវត្តចំពោះតែការផ្តល់ជំនួយទៅវិញទៅមក នៅក្នុងចំណោមបណ្តាភាគីតែប៉ុណ្ណោះ ។ បទប្បញ្ញត្តិនៃសន្ធិសញ្ញានេះ មិនបង្កើតសិទ្ធិណាមួយដល់បុគ្គលឯកជន ដើម្បីទទួលបាន រារាំង ឬ ទាត់ចោល នូវភស្តុតាង ឬ ដើម្បីបង្អាក់ដល់ការអនុវត្តសំណើសុំជំនួយឡើយ ។

៤. គោលបំណងនៃសន្ធិសញ្ញានេះ ឃ្លា "មធ្យោបាយបទល្មើស" មានន័យថា ទ្រព្យសម្បត្តិ ដែ លប្រើជាប់ ទាក់ទិននឹង ការប្រព្រឹត្តបទល្មើស ឬ មានតម្លៃសមមូលទៅនឹងទ្រព្យសម្បត្តិនេះ ។

## មាត្រា ២
## ការមិនអនុវត្ត

១. សន្ធិសញ្ញានេះមិនអនុវត្តចំពោះ :

(ក). ការចាប់ខ្លួន ឬ ការឃុំខ្លួនជនណាម្នាក់ ក្នុងគោលបំណងដើម្បីធ្វើបត្យាប័នជននោះ

(ខ). ការអនុវត្តសាលក្រមព្រហ្មទណ្ឌនៅក្នុងភាគីទទួលសំណើ ដែលការអនុវត្តសាលក្រមនេះ ត្រូវឱ្យធ្វើឡើងនៅក្នុងភាគីដាក់សំណើ លើកលែងតែមានការអនុញ្ញាតិដោយច្បាប់របស់ភាគីទទួល សំណើ ។

(គ). ការផ្ទេរជនដែលកំពុងជាប់ឃុំខ្លួន ឱ្យមកអនុវត្តសាលក្រមជាប់ពន្ធនាគារ ។

(ឃ). ការផ្ទេរនីតិវិធីរឿងក្តី នៅក្នុងរឿងព្រហ្មទណ្ឌ ។

២. នៅក្នុងសន្ធិសញ្ញានេះពុំបានផ្តល់សិទ្ធិឱ្យភាគីណាមួយ ដើ ម្បីអនុវត្តយុត្តាធិការ និង បំពេញមុខងារនៅក្នុង ដែនដីរបស់ភាគីផ្សេងទៀតទេ ការអនុវត្តនេះគឺជាសិទ្ធិផ្តាច់មុខសំរាប់តែ អាជ្ញាធររបស់ភាគីផ្សេងទៀត តាមច្បាប់ក្នុងស្រុករបស់ខ្លួន ។

## មាត្រា ៣
## ការកំរិតលើជំនួយ

១. ភាគីទទួលសំណើត្រូវបដិសេធការសុំជំនួយ ប្រសិនបើខ្លួនយល់ឃើញថា :

ក. សំណើនោះទាក់ទងទៅនឹងការស៊ើបអង្កេត ការចោទប្រកាន់ ឬ ការផ្តន្ទាទោស ជនណាម្នាក់ពីបទល្មើសដែលមានលក្ខណៈនយោបាយ ឬ ដោយមានសំអាងលើហេតុផល នៃការសេះទេសៈក្នុងការចោទប្រកាន់ថា ជននោះកំពុងបានប្រព្រឹត្ត ឬ បានប្រព្រឹត្តរួចហើយ នូវបទល្មើសណាមួយដែលមានលក្ខណៈនយោបាយ ។

ខ. សំណើនោះទាក់ទងទៅនឹងការស៊ើបអង្កេត ការចោទប្រកាន់ ឬ ការផ្តន្ទាទោស ជនណាម្នាក់ទាក់ទងដល់អំពើប្រព្រឹត្តបទល្មើស ឬ ការខកខានណាមួយ ដែលគួរចាត់ទុកថាជា បទល្មើសយោធា ប្រសិនបើវាបានកើតឡើងនៅក្នុងភាគីទទួលសំណើ យោងតាមច្បាប់របស់ភាគីទទួលសំណើ អំពើប្រព្រឹត្ត ឬការខកខាននោះមិនមែនជាបទល្មើសផងដែរ ស្ថិតនៅក្រោមច្បាប់ព្រហ្មទណ្ឌធម្មតារបស់ភាគីទទួលសំណើ ។

គ. មានហេតុផលដ៏ធ្ងន់ដែលគួរឱ្យជឿបានថា សំណើត្រូវបានធ្វើឡើងសំរាប់គោលបំណង ស៊ើបអង្កេត ចោទប្រកាន់ ផ្តន្ទាទោស ឬ បើមិនដូច្នោះទេ បង្កឱ្យមានភាពលំអៀងចំពោះជនណាមួយដោយសារតែ ជាតិសាសន៍ សាសនា ភេទ ដើមកំណើត ជនជាតិ សញ្ជាតិ ឬ ទស្សនៈនយោបាយរបស់ជននោះ ។

ឃ. សំណើនោះទាក់ទងទៅនឹងការស៊ើបអង្កេត ការចោទប្រកាន់ ការផ្តន្ទាទោស លើជនហោមួយពីបទល្មើសនៅក្នុងករណីដែលជននោះ :

(១) ត្រូវបានកាត់ឱ្យជាប់ទោស សំរេចឱ្យរួចខ្លួន ឬលើកលែងទោស ដោយតុលាការ ឬ អាជ្ញាធរមានសមត្ថកិច្ចដទៃទៀត នៅក្នុងភាគីដាក់សំណើ ឬ ភាគីទទួលសំណើ។

(២) បានទទួលការផ្តន្ទាទោសដែលចែងដោយច្បាប់ របស់ភាគីដាក់សំណើ ឬ ភាគីទទួលសំណើទាក់ទងនឹងបទល្មើសនោះ ឬ បទល្មើសផ្សេងទៀត ដែលផ្សំឡើងដោយអំពើ ឬ ការខកខានដូចបទល្មើសដែលបានលើកឡើងពីដំបូង ។

ង. សំណើទាក់ទងនឹងការស៊ើបអង្កេត ការចោទប្រកាន់ ឬ ការផ្តន្ទាទោស ទៅលើជនណាមួយពាក់ព័ន្ធនឹងអំពើប្រព្រឹត្ត ឬ ការខកខាន មិនគួរចាត់ទុកថាជា បទល្មើសប្រឆាំងនឹងច្បាប់របស់ភាគីទទួលសំណើនោះទេ ប្រសិនបើវាបានកើតឡើងនៅក្នុងភាគីទទួលសំណើ លើកលែងតែភាគីទទួលសំណើនោះ អាចផ្តល់ជំនួយ ទោះបីអវត្តមាននៃគោលការណ៍តំរូវឱ្យកំណត់ អំពើប្រព្រឹត្ត ឬ ការខកខាននោះថាជា បទល្មើសនៅក្នុងភាគីទាំងពីរ ប្រសិនបើការផ្តល់ជំនួយ

បែបនេះ អនុញ្ញាតដោយច្បាប់ក្នុងស្រុករបស់ខ្លួន ។

ច. ការផ្តល់ជំនួយនឹងប៉ះពាល់ដល់ អធិបតេយ្យភាព សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ផលប្រយោជន៍សាធារណៈ ឬ ផលប្រយោជន៍ជាសារវន្តរបស់ភាគីទទួលសំណើ ។

ឆ. ភាគីដាក់សំណើមិនអាចធានាបានថា ខ្លួននឹងអាចប្រតិបត្តិតាមសំណើនាពេលអនាគត នូវជំនួយផ្នែកព្រហ្មទណ្ឌ ដែលមានលក្ខណៈស្រដៀងគ្នានឹងភាគីទទួលសំណើបានឡើយ ។

ជ. ភាគីដាក់សំណើមិនអាចធានាបានថា កម្មវត្ថុដែលខ្លួនបានស្នើសុំនោះ នឹងមិនយកទៅប្រើប្រាស់ក្រៅពីរឿងក្តីព្រហ្មទណ្ឌទាក់ទងទៅនឹងសំណើដែលបានធ្វើឡើងឡើយ ហើយភាគីទទួលសំណើមិនបានយល់ព្រមបោះបង់ចោលនូវការធានាបែបនេះ ។

ឈ. ភាគីដាក់សំណើមិនអាចធានា ក្នុងការប្រគល់ជូនភាគីទទួលសំណើវិញនូវវត្ថុតាងណាមួយ ដែលបានទទួលតាមសំណើរបស់ខ្លួន អនុលោមទៅតាមសំណើ នៅពេលបញ្ចប់រឿងក្តីព្រហ្មទណ្ឌទាក់ទងទៅនឹងការធ្វើសំណើនេះ ។

ញ. ការផ្តល់ជំនួយនោះ អាចធ្វើឱ្យប៉ះពាល់ដល់រឿងក្តីព្រហ្មទណ្ឌ នៅក្នុងភាគីទទួលសំណើ ឬ

ដ. ការផ្តល់ជំនួយនោះ តំរូវឱ្យធ្វើជាជំហ៊ាន១ ដែលផ្ទុយនឹងច្បាប់របស់ភាគីទទួលសំណើ

២. ភាគីទទួលសំណើ អាចបដិសេធក្នុងការផ្តល់ជំនួយ ប្រសិនបើខ្លួនយល់ឃើញថា :

ក. ភាគីដាក់សំណើមិនបានប្រតិបត្តិទៅតាមខ្លឹមសារណាមួយនៃសន្ធិសញ្ញានេះ ឬ ការរៀបចំដទៃទៀតទាក់ទងទៅនឹងសំណើនោះ

ខ. ការផ្តល់ជំនួយនោះ នឹង ឬ ទំនងជានឹងធ្វើឱ្យប៉ះពាល់ដល់សុវត្ថិភាពរបស់ជនណាម្នាក់ ទោះបីជននោះ ស្ថិតនៅក្នុង ឬ ក្រៅដែនដីរបស់ភាគីទទួលសំណើក៏ដោយ ឬ

គ. ការផ្តល់ជំនួយនោះ នឹងដាក់បន្ទុកហួសប្រមាណទៅលើធនធានរបស់ភាគីទទួលសំណើ ។

៣. ជាគោលបំណងរបស់អនុកថាខណ្ឌ ១ (ក) បណ្តាបទល្មើសខាងក្រោមនេះ មិនត្រូវចាត់ទុកថាជាបទល្មើសមានលក្ខណៈនយោបាយឡើយ :

ក. បទល្មើសប្រឆាំងនឹងជីវិត ឬ បុគ្គលដែលជាប្រមុខរដ្ឋ ឬសមាជិកក្រុមគ្រួសាររបស់ប្រមុខរដ្ឋផ្ទាល់

ខ. បទល្មើសប្រឆាំងនឹងជីវិត ឬ បុគ្គលដែលជាប្រមុខនៃរដ្ឋាភិបាលថ្នាក់កណ្តាល ឬ រដ្ឋមន្ត្រីរបស់រដ្ឋាភិបាលថ្នាក់កណ្តាល ។

គ. បទល្មើសស្ថិតទៅក្នុងវិសាលភាពនៃសន្ធិសញ្ញាអន្តរជាតិ ដែលទាំងភាគីដាក់សំណើ និងភាគីទទួលសំណើ សុទ្ធតែជាភាគីរបស់អនុសញ្ញានោះ ហើយអនុសញ្ញានោះ ដាក់កាតព្វកិច្ចមកលើភាគីឱ្យធ្វើបត្យាប័ន ឬ កាត់ទោសជនជាប់ចោទពីបទល្មើសដែលបានប្រព្រឹត្ត ។

ឃ. រាល់ការប៉ុនប៉ង ការញុះញង់ ឬ ការសមគំនិត ដើម្បីប្រព្រឹត្តបទល្មើសណាមួយ ដែលបានលើកឡើងនៅក្នុងអនុកថាខណ្ឌ (ក) ដល់ (គ) ។

៤. ភាគីទទួលសំណើ អាចដាក់កំរិតលើការអនុវត្តបទប្បញ្ញត្តិណាមួយមានចែងនៅក្រោមកថាខ័ណ្ឌ ៣ ដោយយោងទៅតាមថាតើ ច្បាប់ក្នុងស្រុករបស់ភាគីដាក់សំណើ មានចែងបទប្បញ្ញត្តិស្រដៀងគ្នាដែរឬទេ ។

៥. ការផ្តល់ជំនួយ មិនត្រូវបដិសេធ ដោយគ្រាន់តែមានមូលហេតុភាពសំងាត់របស់ធនាគារ និង ស្ថាប័នហិរញ្ញវត្ថុ ប្រហាក់ប្រហែល ឬ ដោយហេតុផលថា បទល្មើសនោះ ត្រូវបានចាត់ទុកផងដែរថាមានពាក់ព័ន្ធដល់បញ្ហាសារពើពន្ធ ។

៦. ភាគីទទួលសំណើអាចផ្អាកប្រតិបត្តិសំណើ ប្រសិនបើការប្រតិបត្តិភ្លាម១របស់ខ្លួន អាចជ្រៀតជ្រែកដល់ដំណើរការណាមួយនៃរឿងក្តីព្រហ្មទណ្ឌ នៅក្នុងភាគីទទួលសំណើ ។

៧. មុនពេលបដិសេធសំណើ ឬ ផ្អាកប្រតិបត្តិសំណើរបស់ខ្លួន ដោយអនុលោមទៅតាមមាត្រានេះ ភាគីទទួលសំណើ ត្រូវពិចារណាថាតើ ជំនួយអាចផ្តល់ឱ្យ ដោយអាស្រ័យលើលក្ខខណ្ឌជាក់លាក់ដែរឬទេ ។

៨. ប្រសិនបើភាគីដាក់សំណើ ទទួលយកជំនួយស្ថិតនៅក្រោមលក្ខខណ្ឌ ដែលបានដាក់ក្រោមកថាខ័ណ្ឌ ៧ នោះភាគីដាក់សំណើ ត្រូវប្រតិបត្តិតាមលក្ខខណ្ឌបែបនេះ ។

៩. ប្រសិនបើភាគីទទួលសំណើ បដិសេធ ឬ ផ្អាកផ្តល់ជំនួយ នោះភាគីទទួលសំណើត្រូវជូនដំណឹងដល់ភាគីម្ចាស់សំណើភ្លាម អំពីមូលហេតុនៃការបដិសេធ ឬ ការផ្អាកនោះ ។

១០. អាស្រ័យតាមច្បាប់ក្នុងស្រុករបស់ភាគីរៀង១ខ្លួន ភាគីទាំងអស់ ត្រូវផ្តល់ជំនួយទៅវិញទៅមក *(បដិការ)* ទាក់ទងទៅ នឹងបទល្មើសប្រហាក់ប្រហែល ដោយមិនគិតដល់ទោសបញ្ញត្តិ ដែលត្រូវអនុវត្តឡើយ ។

## មាត្រា ៤
## ការតែងតាំងអាជ្ញាធរកណ្តាល

១. ភាគីនីមួយ១ ត្រូវតែងតាំងអាជ្ញាធរកណ្តាលមួយ ដើម្បីរៀបចំនិងទទួលសំណើ អនុលោមតាមសន្ធិសញ្ញានេះ ។

២. ការតែងតាំងអាជ្ញាធរកណ្តាល ត្រូវធ្វើឡើងនៅពេលតំកល់លិខិតតុបករណ៍ នៃការផ្តល់សច្ចាប័ន ទទួលយកអនុម័ត ឬ ចូលជាសមាជិកនៃសន្ធិសញ្ញានេះ ។

៣. ភាគីនីមួយ១ ត្រូវជូនដំណឹងភាគីផ្សេង១ទៀតឱ្យបានរួសរាន់ អំពីការផ្លាស់ប្តូរនៅក្នុងការតែងតាំងអាជ្ញាធរកណ្តាលរបស់ខ្លួន ។

៤. អាជ្ញាធរកណ្តាល ត្រូវទំនាក់ទំនងគ្នាដោយផ្ទាល់ ប៉ុន្តែភាគីអាចទំនាក់ទំនងគ្នាតាមបណ្តាញការទូតប្រសិនបើភាគីជ្រើសរើសដូចនេះ ។

## មាត្រា ៥
## ទម្រង់សំណើ

១. រាល់សំណើសុំជំនួយ ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ឬ ប្រសិនបើធ្វើទៅបាន តាមរយៈមធ្យោបាយណាមួយ ដែលអាចបង្កើតជាកំណត់ហេតុលាយលក្ខណ៍អក្សរក្រោមលក្ខខណ្ឌអនុញ្ញាតឱ្យ ភាគីទទួលសំណើធ្វើកំណត់ហេតុជាយថាភូត ។ នៅក្នុងស្ថានភាពបន្ទាន់ និង បើច្បាប់របស់ភាគីទទួលសំណើអនុញ្ញាតឱ្យនោះ សំណើអាចធ្វើឡើងដោយផ្ទាល់មាត់បាន ប៉ុន្តែនៅក្នុងករណីបែបនេះ រាល់សំណើត្រូវមានការបញ្ជាក់ជាលាយលក្ខណ៍អក្សរក្នុងរយៈពេលប្រាំថ្ងៃ ។

២. អាជ្ញាធរកណ្តាល ត្រូវចាត់ចែងក្នុងការបញ្ជូនសំណើ ឬ ការទំនាក់ទំនងពាក់ព័ន្ធ។ នៅក្នុងស្ថានភាពបន្ទាន់ និង បើច្បាប់របស់ភាគីទទួលសំណើអនុញ្ញាតឱ្យ រាល់សំណើ និងការទំនាក់ទំនងពាក់ព័ន្ធ អាចត្រូវបានបញ្ជូនតាមរយៈ អង្គការនគរបាលព្រហ្មទណ្ឌអន្តរជាតិ (INTERPOL) ឬ អង្គការនគរបាលអាស៊ីអាគ្នេយ៍ (ASEANAPOL) ។

## មាត្រា ៦
## ខ្លឹមសារសំណើ

១. សំណើសុំជំនួយក្នុងរឿងក្តីព្រហ្មទណ្ឌ ត្រូវមានព័ត៌មានបែបនេះ ដូចដែលភាគីទទួលសំណើតម្រូវឱ្យប្រតិបត្តិសំណើ រួមមាន :

ក. ឈ្មោះការិយាល័យភាគីដាក់សំណើ និងអាជ្ញាធរមានសមត្ថកិច្ចស៊ើបអង្កេត ឬ ដំណើរការរឿងក្តីព្រហ្មទណ្ឌ ដែលទាក់ទងទៅនឹងសំណើនោះ ។

ខ. គោលបំណងរបស់សំណើ និង ប្រភេទជំនួយស្នើសុំ

គ. ការអធិប្បាយពីប្រភេទរឿងក្តីព្រហ្មទណ្ឌ និង ស្ថានភាពបច្ចុប្បន្នរបស់វា និង របាយការណ៍បង្ហាញពីសេចក្តីសង្ខេបនៃអង្គហេតុ និង អង្គច្បាប់ពាក់ព័ន្ធ ។

ឃ. ការអធិប្បាយពីបទល្មើសទាក់ទងនឹងសំណើ រួមទាំងទោសបញ្ញត្តិជាអតិបរមា។

ង. ការអធិប្បាយពីអង្គហេតុ សំអាងដល់ការបង្កើតបានជាបទល្មើស និង របាយការណ៍ ឬ អត្ថបទច្បាប់ពាក់ព័ន្ធ ។

ច. ការអធិប្បាយពីអំពើប្រព្រឹត្ត ឬ ការខកខាន ឬ បញ្ហានៃបណ្តឹងបរិហា ឬការស្វែងរកដែលបញ្ជាក់ថាពិតប្រាកដ ។

ឆ. ការអធិប្បាយពីភស្តុតាង ព័ត៌មាន ឬ ជំនួយផ្សេងៗដែលត្រូវស្នើសុំ ។

ជ. មូលហេតុ និង សេចក្តីលំអិតនៃនីតិវិធី ឬសេចក្តីតម្រូវពិសេសណាមួយ ដែលភាគីដាក់សំណើប្រាថ្នាចង់ឱ្យអនុវត្តតាម ។

ឈ. ការបញ្ជាក់ច្បាស់លាស់ពីពេលវេលាកំណត់ ដែលចង់ឱ្យការអនុវត្តតាមសំណើធ្វើឡើងនៅក្នុងរយៈពេលកំណត់នេះ ។

ញ. សេចក្តីតម្រូវពិសេសណាមួយ ទាក់ទងការរក្សាភាពសំងាត់ និង មូលហេតុនៃការរក្សាភាពសំងាត់ និង

ដ. ព័ត៌មាន និង ការអនុវត្តដទៃទៀតបែបនេះ ដែលអាចតម្រូវតាមច្បាប់ក្នុងស្រុករបស់ភាគីទទួលសំណើ ឬបើមិនដូច្នោះទេ ព័ត៌មាននោះគឺជាការចាំបាច់សំរាប់ការប្រតិបត្តិសំណើឱ្យបានសមស្រប ។

២. អាស្រ័យលើវិសាលភាពនៃភាពចាំបាច់ រាល់សំណើសុំជំនួយអាចមានព័ត៌មានដូចខាងក្រោម :

ក. អត្តសញ្ញាណ សញ្ជាតិ និងទីតាំង របស់ជនណា ឬ បណ្តាបុគ្គលណាដែលជាកម្មវត្ថុ នៃការស៊ើបអង្កេត ឬ ដំណើរការរឿងក្តីព្រហ្មទណ្ឌ ។

ខ. អត្តសញ្ញាណ និង ទីតាំងរបស់ជនដែលត្រូវស្វែងរកភស្តុតាងពីជននោះ ។

គ. អត្តសញ្ញាណ និង ទីតាំងរបស់ជនដែលត្រូវស្វែងរក ការទំនាក់ទំនងរបស់ជននោះទៅនឹងដំណើរការរឿងក្តីព្រហ្មទណ្ឌ និង របៀបតម្រូវឱ្យជននោះផ្តល់សេវា ។

ឃ. ព័ត៌មានស្តីពីអត្តសញ្ញាណ និង ទីតាំងរបស់ជនដែលត្រូវស្វែងរក ។

ង. ការអធិប្បាយអំពីរបៀបយក ឬ ធ្វើកំណត់ហេតុ ពីការផ្តល់ចំលើយ និង សក្ខីភាព ។

ច. បញ្ជីសំណួរដែលត្រូវសួរចំពោះសាក្សី ។

ឆ. ការអធិប្បាយអំពី ឯកសារ កំណត់ហេតុ ឬ វត្ថុតាងដែលត្រូវបង្កើត ព្រមទាំងការអធិប្បាយពីជនសមស្របដែលត្រូវសួរចំពោះ ដើម្បីបង្កើតឯកសារនិងវត្ថុតាងទាំងអស់នេះ និងតាមវិសាលភាពដែលមិនត្រូវផ្តល់ឱ្យ គឺធ្វើការអធិប្បាយពី ទំរង់ឯកសារ និង វត្ថុតាងដែលត្រូវបង្កើតឡើងវិញ និង បញ្ជាក់យថាភូត ។

ជ. របាយការណ៍បញ្ជាក់ថាតើ មានតម្រូវការ ឱ្យ ធ្វើសម្បថ ឬ អះអាងទៅលើភស្តុតាង ឬ ទៅលើការផ្តល់ចំលើយដែរ ឬទេ ។

ឈ. ការអធិប្បាយអំពីទ្រព្យសម្បត្តិ ទ្រព្យសកម្ម ឬ វត្ថុដែលទាក់ទងនឹងសំណើ រួមទាំងអត្តសញ្ញាណ និង ទីតាំងរបស់វា និង

ញ. ដីកាបង្គាប់តុលាការទាក់ទងនឹងសំណើសុំជំនួយ និង របាយការណ៍ទាក់ទងនឹងអង្គហេតុចុងក្រោយនៃដីកាបង្គាប់នោះ ។

៣. បណ្តាសំណើ ឯកសារគាំទ្រ និង ការប្រាស្រ័យទាក់ទងផ្សេងៗ ដែលបានធ្វើឡើង ដោយអនុលោមទៅតាមសន្ធិសញ្ញានេះ ត្រូវធ្វើជាភាសាអង់គ្លេស និងប្រសិនបើចាំបាច់ ត្រូវអមមកជាមួយនូវការបកប្រែជាភាសារបស់ប្រទេសទទួលសំណើ ឬ ភាសាផ្សេងទៀតដែលភាគីទទួលសំណើ អាចទទួលយកបាន ។

៤. ប្រសិនបើភាគីទទួលសំណើពិចារណាឃើញថា ព័ត៌មាននៅក្នុងសំណើមិនទាន់គ្រប់គ្រាន់ ដើម្បីឱ្យសំណើអាចអនុវត្តតាមបាន នោះភាគីទទួលសំណើ អាចស្នើសុំព័ត៌មានបន្ថែម ។ ភាគីដាក់សំណើ ត្រូវផ្តល់ព័ត៌មានបន្ថែមបែបនេះ ដែលភាគីទទួលសំណើពិចារណាឃើញថា មានការចាំបាច់ដើម្បីអនុវត្តបំពេញតាមសំណើ ។

## មាត្រា ៧
## ការអនុវត្តសំណើ

១. សំណើសុំជំនួយ ត្រូវអនុវត្តយ៉ាងរួសរាន់ ទៅតាមរបៀបចែងដោយច្បាប់ និងការអនុវត្តនានារបស់ភាគីទទួលសំណើ ។ ដោយអនុលោមទៅតាមច្បាប់ និង ការអនុវត្តនៅក្នុងស្រុករបស់ខ្លួន ភាគីទទួលសំណើ ត្រូវអនុវត្តសំណើតាមរបៀបបញ្ជាក់ជូនដោយភាគីដាក់សំណើ ។

២. ប្រសិនបើមានការស្នើសុំឱ្យធ្វើដូច្នេះ និង អនុលោមទៅតាមច្បាប់ និង ការអនុវត្តក្នុងស្រុករបស់ខ្លួន នោះភាគីទទួលសំណើ តំណាងឱ្យភាគីដាក់សំណើ នៅក្នុងភាគីម្ចាស់សំណើ ត្រូវរៀបចំនិងធានាការចាំបាច់ទាំងអស់នៅក្នុងដំណើរការរឿងក្តីព្រហ្មទណ្ឌណាមួយ ដែលកើតចេញពីសំណើសុំជំនួយ ហើយបើមិនដូច្នេះទេ គឺត្រូវតំណាងឱ្យអត្ថប្រយោជន៍របស់ភាគីដាក់សំណើ ។

៣. ភាគីទទួលសំណើ ត្រូវឆ្លើយតបឱ្យបានឆាប់តាមដែលអាចធ្វើបាន ទៅនឹងសំណើសុំការស៊ើបអង្កេត ដែលមានលក្ខណៈសមហេតុផល របស់ភាគីដាក់សំណើ ស្តីអំពីការរីកចំរើនក្នុងការអនុវត្តសំណើ ។

៤. ភាគីទទួលសំណើអាចសុំឱ្យភាគីដាក់សំណើផ្តល់ ព័ត៌មាននៅក្នុងទម្រង់ដែលអាចជាការចាំបាច់ ដើម្បីឱ្យខ្លួនអាចអនុវត្តសំណើ ឬ ធានានីតិវិធានការនានាដែលអាចចាំបាច់ យោងទៅតាមច្បាប់ និង ការអនុវត្តរបស់ភាគីទទួលសំណើ ដើម្បីអនុវត្តឱ្យមានប្រសិទ្ធិភាពដល់សំណើ ដែលទទួលបានពីភាគីដាក់សំណើ ។

## មាត្រា ៨
## ការកំរិតលើការប្រើប្រាស់ភស្តុតាងដែលទទួលបាន

១. ដោយគ្មានការយល់ព្រមពីភាគីទទួលសំណើ និង អនុលោមទៅតាមលក្ខខណ្ឌដែលភាគីទទួលសំណើចាត់ទុកថាចាំបាច់ នោះភាគីដាក់សំណើមិនត្រូវប្រើប្រាស់ ឬ បង្ហាញ ឬ ផ្ទេរព័ត៌មាន ឬភស្តុតាង ដែលផ្តល់

ដោយភាគីទទួលសំណើ សំរាប់គោលបំណងផ្សេងពីគោលបំណង ដែលបានបញ្ជាក់នៅក្នុងសំណើឡើយ ។

២. ទោះជាមានចែងនៅក្នុងកថាខ័ណ្ឌ១ក្តី បើមានការកែប្រែបទចោទប្រកាន់នៅក្នុងរឿងក្តី និង ដោយមានការយល់ព្រមជាមុនពីភាគីទទួលសំណើ និងនៅក្នុងទំហំបទល្មើសដែលបានចោទ នោះព័ត៌មាន ឬភស្តុតាងដែលបានផ្តល់ឱ្យ អាចយកមកប្រើនៅក្នុងបទល្មើស ដែលអាចមានចែងនៅក្នុងជំនួយផ្នែកច្បាប់ទៅវិញទៅមក ដោយយោងទៅតាមសន្ធិសញ្ញានេះ ហើយបទល្មើសបង្កើតឡើងដោយផ្អែកលើអង្គហេតុនៃការធ្វើសំណើនេះ ។

## មាត្រា ៩
## កិច្ចការពារការសំងាត់

១. ដោយអនុលោមទៅតាមច្បាប់ក្នុងស្រុករបស់ខ្លួន ភាគីទទួលសំណើ ត្រូវចាត់វិធានការសមស្របទាំងអស់ដើម្បីរក្សាការសំងាត់ចំពោះសំណើសុំជំនួយ ខ្លឹមសារនិងឯកសារគាំទ្ររបស់សំណើ ហេតុការណ៍នៃការផ្តល់ជំនួយ និង ចំណាត់ការណាមួយដែលអនុវត្តទៅតាមសំណើ ។ ប្រសិនបើ សំណើមិនអាចអនុវត្តបានដោយគ្មានបំពានលើតំរូវការរក្សាការសំងាត់ នោះភាគីទទួលសំណើ ត្រូវជូនដំណឹងឱ្យភាគីដាក់សំណើជ្រាបពីបញ្ហានេះ ហើយបន្ទាប់មក ភាគីដាក់សំណើត្រូវកំណត់ថាតើ គួរនៅតែឱ្យអនុវត្តសំណើទៀត ឬយ៉ាងម៉េច ។

២. អនុលោមតាមច្បាប់ក្នុងស្រុករបស់ខ្លួន ភាគីដាក់សំណើត្រូវចាត់វិធានការសមស្របទាំងអស់ ដើម្បី :

ក. រក្សាការសំងាត់នូវ ព័ត៌មាននិងភស្តុតាងដែលផ្តល់ឱ្យដោយភាគីទទួលសំណើ លើកលែងតែតាមវិសាលភាពថា ភស្តុតាងនិងព័ត៌មាននោះ ចាំបាច់សំរាប់គោលបំណងដែលបានរៀបរាប់នៅក្នុងសំណើ និង

ខ. ធានាថា ព័ត៌មាននិងភស្តុតាងត្រូវបានការពារមិនឱ្យបាត់បង់ និងការទទួលបាន ការប្រើប្រាស់ ការកែប្រែ ការបង្ហាញដោយគ្មានការអនុញ្ញាត ឬ ការប្រើប្រាស់មិនត្រឹមត្រូវផ្សេងៗ ។

## មាត្រា ១០
## ការទទួលយកចម្លើយដោយស្ម័គ្រចិត្ត

បើមានសំណើសុំឱ្យយកចម្លើយពីជនណាម្នាក់ សំរាប់គោលបំណងនៃរឿងក្តីព្រហ្មទណ្ឌរបស់ភាគីដាក់សំណើ នោះភាគីទទួលសំណើ ដោយមានការយល់ព្រមពីជននោះ ត្រូវខិតខំខ្នះខ្នែងដើម្បីទទួលយកចម្លើយនោះ ។

## មាត្រា ១១
## ការទទួលយកភស្តុតាង

១. យោងទៅតាមច្បាប់ក្នុងស្រុករបស់ខ្លួន ភាគីទទួលសំណើត្រូវរៀបចំទទួលយកភស្តុតាង រួមមាន សក្ខីភាព ឯកសារ ឬ របាយការណ៍ដែលមានសម្បថ ឬ បញ្ជាក់ថាពិត ទទួលពីសាក្សីសំរាប់គោលបំណងនៃរឿងក្តីព្រហ្មទណ្ឌ ដើម្បីបញ្ជូនទៅឱ្យភាគីដាក់សំណើ ។

២. បើការផ្តល់ចម្លើយមានសម្បថ ឬ បញ្ជាក់ថាពិត យោងតាមមាត្រានេះ បណ្តាភាគីពាក់ព័ន្ធនឹងដំណើររឿងក្តីព្រហ្មទណ្ឌ នៅក្នុងភាគីដាក់សំណើ ឬ តំណាងស្របច្បាប់របស់គេ អាចបង្ហាញខ្លួន និងចោទសួរ ជនដែលផ្តល់ភស្តុតាងនោះ ដោយអនុលោមទៅតាមច្បាប់ក្នុងស្រុករបស់ភាគីទទួលសំណើ ។

៣. នៅក្នុងមាត្រានេះ មិនបានរាំងការប្រើប្រាស់ ការតភ្ជាប់វីដេអូ ឬ ទូរទស្សន៍ដែលបញ្ជាំងផ្ទាល់ ឬ ឧបករណ៍សំរួលដល់ការប្រាស្រ័យទាក់ទងសមស្របដទៃទៀត ដោយអនុលោមតាមច្បាប់ និង ការអនុវត្តរបស់ភាគីទទួលសំណើ ក្នុងគោលបំណងអនុវត្តមាត្រានេះ ប្រសិនបើការប្រើប្រាស់ឧបករណ៍ទាំងអស់នេះបំរើដល់ផលប្រយោជន៍យុត្តិធម៌ ។

## មាត្រា ១២
## សិទ្ធិបដិសេធក្នុងការផ្តល់ភស្តុតាង

១. ជនដែលតំរូវឱ្យផ្តល់សក្ខីភាព ឬ បង្កើតឯកសារ ឬ របាយការណ៍ ឬ ភស្តុតាងផ្សេងៗ ដោយមានសម្បថ ឬ បញ្ជាក់ថាត្រឹមត្រូវ យោងតាមមាត្រាទី១១នៃសន្ធិសញ្ញានេះ នៅក្នុងភាគីទទួលសំណើ ដោយអនុលោមទៅតាមសំណើសុំជំនួយ អាចបដិសេធមិនធ្វើ បើ :

   ក. ច្បាប់របស់ភាគីដាក់សំណើ អនុញ្ញាត ឬ តំរូវឱ្យជននោះ បដិសេធក្នុងការធ្វើយ៉ាងដូច្នេះ នៅក្នុងកាលៈទេសៈដូចគ្នា នៅក្នុងដំណើរការរឿងក្តីធ្វើឡើងនៅក្នុងភាគីទទួលសំណើ ឬ

   ខ. ច្បាប់របស់ភាគីដាក់សំណើអនុញ្ញាត ឬ តំរូវឱ្យជននោះ បដិសេធក្នុងការធ្វើដូច្នេះ នៅក្នុងកាលៈទេសៈដូចគ្នានៅក្នុងដំណើរការរឿងក្តីធ្វើឡើងនៅក្នុងភាគីដាក់សំណើ ។

២. ប្រសិនបើជននោះ អះអាងថាមានសិទ្ធិបដិសេធក្នុងការផ្តល់សក្ខីភាព ឬ បង្កើតឯកសារ របាយការណ៍ ឬ ភស្តុតាងផ្សេងៗ ដោយមានសម្បថ ឬ បញ្ជាក់ថាត្រឹមត្រូវ យោងតាមមាត្រាទី១១នៃសន្ធិសញ្ញានេះ នៅក្រោមច្បាប់របស់ភាគីដាក់សំណើ ប្រសិនបើមានការស្នើសុំដូចនេះ ភាគីដាក់សំណើត្រូវផ្តល់លិខិតបញ្ជាក់ដល់ភាគីទទួលសំណើពីវត្តមាននៃសិទ្ធិនោះ ឬ ពីអវត្តមានសិទ្ធិនោះ ។

## មាត្រា ១៣
## ការផ្តល់ឯកសារ និង របាយការណ៍ផ្សេងៗដែលមានជាសាធារណៈ

១. ភាគីទទួលសំណើ ត្រូវផ្តល់ឱ្យភាគីដាក់សំណើនូវច្បាប់ចំលងនៃឯកសារ ឬ របាយការណ៍ដែលមានជាសាធារណៈ ជាកម្មសិទ្ធិ របស់ក្រសួង និង ស្ថាប័នរដ្ឋាភិបាល ។

២. អនុលោមតាមច្បាប់ និង ការអនុវត្តក្នុងស្រុករបស់ខ្លួន ភាគីទទួលសំណើអាចផ្តល់ឱ្យភាគីដាក់សំណើនូវច្បាប់ចំលងនៃឯកសារ ឬ របាយការណ៍ណាមួយ ដែលជាកម្មសិទ្ធិរបស់ក្រសួង និង ស្ថាប័នរដ្ឋាភិបាល តែមិនមានសំរាប់ជាសាធារណៈនោះទេ ។ ភាគីទទួលសំណើ អាចប្រើឆន្ទានុសិទ្ធិរបស់ខ្លួនដើម្បីបដិសេធទាំងស្រុង ឬ ដោយផ្នែកខ្លះចំពោះសំណើ ដោយអនុលោមតាមកថាខ័ណ្ឌនេះ ។

## មាត្រា ១៤
## ការបញ្ជូនជនណាមួយទៅភាគីដាក់សំណើ

១. អនុលោមទៅតាមច្បាប់ និង ការអនុវត្តនៅក្នុងស្រុករបស់ខ្លួន ភាគីទទួលសំណើអាចជួយរៀបចំឱ្យជនណាមួយដែលមានវត្តមាននៅក្នុងភាគីទទួលសំណើ ចូលទៅក្នុងភាគីដាក់សំណើ ដោយយោងតាមការយល់ព្រមពីជននោះ :

   ក. ជួយក្នុងការស៊ើបអង្កេត ទាក់ទងនឹងរឿងក្តីព្រហ្មទណ្ឌ នៅក្នុងភាគីដាក់សំណើ ឬ

   ខ. ចូលខ្លួនក្នុងដំណើការរឿងក្តីព្រហ្មទណ្ឌណាមួយនៅក្នុងភាគីដាក់សំណើ លើកលែងតែជននោះគឺជាជនដែលត្រូវចោទប្រកាន់ ។

២. ប្រសិនបើភាគីទទួលសំណើ ពេញចិត្តនឹងការរៀបចំសំរាប់សុវត្ថិភាពរបស់ជននោះ ដែលនឹងត្រូវធ្វើឡើងដោយភាគីដាក់សំណើ នោះភាគីទទួលសំណើ ត្រូវអញ្ជើញជននោះឱ្យមកបង្ហាញ ឬ ផ្តល់ភស្តុតាង ឬជំនួយទាក់ទងរឿងក្តីព្រហ្មទណ្ឌនៅក្នុងភាគីដាក់សំណើ ។ ជននោះ ត្រូវទទួលបានព័ត៌មានអំពីការចំណាយ ឬ ប្រាក់ឧបត្ថម្ភសំរាប់បង់ឱ្យខ្លួន ។

៣. ប្រសិនបើជននោះយល់ព្រម ភាគីទទួលសំណើ ត្រូវជូនដំណឹងភ្លាមដល់ភាគីដាក់សំណើពីការឆ្លើយតបរបស់ជននោះ និងធានាវិធានការចាំបាច់នានាដើម្បីបង្កលក្ខណៈងាយស្រួលដល់វត្តមានរបស់ជននោះនៅក្នុងភាគីដាក់សំណើ ។

៤. នៅក្នុងមាត្រានេះគ្មានការរារាំង ដល់ការប្រើប្រាស់ ការតភ្ជាប់បណ្តាញជាវីដេអូ ឬ ទូរទស្សន៍បញ្ចាំងដោយផ្ទាល់ ឬ ឧបករណ៍ប្រាស្រ័យទាក់ទងសមស្របផ្សេងទៀតនោះទេ យោងទៅតាមច្បាប់ និងការអនុវត្តរបស់ភាគីទទួលសំណើ ប្រសិនបើវាបំរើដល់ផលប្រយោជន៍យុត្តិធម៌ឱ្យធ្វើដូចនេះ ។

## មាត្រា ១៥

## ការបញ្ជូនជនជាប់ឃុំឃាំងទៅភាគីដាក់សំណើ

១. អនុលោមតាមច្បាប់ក្នុងស្រុក និងការអនុវត្តរបស់ខ្លួន ភាគីទទួលសំណើអាចយល់ព្រមអនុញ្ញាតឱ្យជនជាប់ឃុំឃាំងនៅក្នុងភាគីទទួលសំណើ ផ្ទេរជាបណ្ដោះអាសន្នទៅឱ្យភាគីដាក់សំណើ ដើម្បីផ្ដល់ភស្តុតាង ឬ ជួយនៅក្នុងការស៊ើបអង្កេត បើមានការយល់ព្រមពីជននោះ ។

២. បើជនត្រូវផ្ទេរតំរូវឱ្យធ្វើការឃុំឃាំង យោងតាមច្បាប់របស់ភាគីទទួលសំណើ នោះភាគីដាក់សំណើត្រូវឃុំខ្លួនជននោះ និងត្រូវបញ្ជូនជនជាប់ឃុំឃាំងនោះមកឱ្យភាគីទទួលសំណើវិញ នៅពេលបញ្ចប់រឿងក្ដីទាក់ទងនឹងការស្នើសុំផ្ទេរ ឬ បញ្ជូនត្រឡប់មកភ្លាមនៅពេលវត្តមានរបស់ជននោះ លែងតំរូវតទៅទៀតហើយ ។

៣. នៅពេលភាគីទទួលសំណើ ជូនដំណឹងដល់ភាគីដាក់សំណើថា ជនដែលផ្ទេរនោះ លែងតំរូវឱ្យឃុំខ្លួនតទៅទៀតហើយ ជននោះនឹងត្រូវបានដោះលែងពីការឃុំខ្លួន ហើយត្រូវទទួលបានការប្រព្រឹត្តចំពោះខ្លួន ដូចជនដែលផ្ទេរទៅក្នុងមាត្រា ១៤ នៃសន្ធិសញ្ញានេះ ។

៤. ភាគីដាក់សំណើ មិនតំរូវឱ្យភាគីទទួលសំណើផ្ដួចផ្ដើមដំណើរការនីតិវិធីបត្យាប័ន សំរាប់ការបញ្ជូនជនដែលផ្ទេរនោះត្រឡប់មកវិញឡើយ ។

៥. រយៈពេលជននេះស្ថិតក្រោមការឃុំខ្លួនដោយភាគីដាក់សំណើ ត្រូវរាប់បញ្ចូលទៅក្នុងរយៈពេលនៃការជាប់ពន្ធនាគារ ឬ ឃុំឃាំងនៅក្នុងភាគីទទួលសំណើ ។

៦. ការផ្ទេរតាមមាត្រានេះ មិនអាចប្រព្រឹត្តទៅបាននោះទេ បើគ្មានការធានារ៉ាប់រងពីភាគីដាក់សំណើថា :

ក. ទទួលខុសត្រូវលើការចំណាយទាំងអស់ក្នុងការផ្ទេរជនជាប់ឃុំឃាំង ។

ខ. រក្សាទុកជននោះឱ្យស្ថិតនៅក្រោមការឃុំខ្លួនស្របច្បាប់ នៅក្នុងអំឡុងពេលនៃការផ្ទេរជនជាប់ឃុំឃាំងនោះ និង

គ. ត្រូវបញ្ជូនជននោះ មកឱ្យស្ថិតនៅក្រោមការឃុំឃាំងរបស់ភាគីទទួលសំណើវិញភ្លាម បន្ទាប់ពីវត្តមានរបស់ជននោះនៅចំពោះមុខ អាជ្ញាធរឬតុលាការមានសមត្ថកិច្ចរបស់ភាគីដាក់សំណើ លែងត្រូវការតទៅទៀតហើយ ។

៧. នៅក្នុងមាត្រានេះគ្មានការរារាំង ដល់ការប្រើប្រាស់ ការតភ្ជាប់បណ្ដាញជាវីដេអូ ឬ ទូរទស្សន៍បញ្ចាំងដោយផ្ទាល់ ឬ ឧបករណ៍ប្រាស្រ័យទាក់ទងសមស្របដទៃទៀតនោះទេ យោងទៅតាមច្បាប់ និងការអនុវត្តន៍របស់ភាគីទទួលសំណើ ប្រសិនបើវាបំរើដល់ផលប្រយោជន៍យុត្តិធម៌ឱ្យធ្វើដូចនេះ ។

## មាត្រា ១៦
## សុចរិតភាព

១. យោងតាមកថាខ័ណ្ឌ ២ នៅពេលជនណាមានវត្តមាននៅក្នុងភាគីដាក់សំណើ អនុលោមទៅតាមសំណើបានធ្វើឡើងក្រោមមាត្រា ១៤ ឬ ១៥ នៃសិទ្ធិសញ្ញានេះ :

ក. ជននោះមិនត្រូវបានឃុំខ្លួន ចោទប្រកាន់ ផ្តន្ទាទោស ឬ ទទួលរងនូវការដាក់កំហិតផ្សេងៗលើសេរីភាពបុគ្គលនៅក្នុងភាគីដាក់សំណើ ទាក់ទងទៅនឹងអំពើប្រព្រឹត្ត ឬការខកខាន ឬការផ្តន្ទាទោសពីបទល្មើសណាមួយ ប្រឆាំងនឹងច្បាប់របស់ភាគីដាក់សំណើ ដោយសារមានការចោទថាបានប្រព្រឹត្តបទល្មើសនោះ មុនពេលចេញដំណើររបស់ជននោះពីភាគីទទួលសំណើ ។

ខ. បើគ្មានការយល់ព្រមពីជននោះទេ ជននោះមិនតម្រូវឱ្យផ្តល់ភស្តុតាងនៅក្នុងរឿងក្តីព្រហ្មទណ្ឌណាមួយ នៅក្នុងភាគីដាក់សំណើឡើយ ក្រៅពីរឿងក្តីព្រហ្មទណ្ឌដែលទាក់ទងនឹងសំណើ ឬ

គ. ជននោះមិនត្រូវទទួលរងនូវបណ្តឹងរដ្ឋប្បវេណី ទាក់ទងទៅនឹងអំពើប្រព្រឹត្ត ឬ ការខកខានណាមួយដែលជននោះត្រូវបានចោទថា អំពើប្រព្រឹត្តឬការខកខានបានកើតឡើង នៅមុនពេលជននោះចេញដំណើរពីភាគីទទួលសំណើ ។

២. កថាខ័ណ្ឌ១ ត្រូវឈប់អនុវត្ត ប្រសិនបើជននោះមានសេរីភាព និងអាចចាកចេញបាន ប៉ុន្តែមិនទាន់បានចាកចេញពីភាគីដាក់សំណើ ក្នុងរយៈពេល ១៥ ថ្ងៃជាប់ៗគ្នា បន្ទាប់ពីជននោះត្រូវបានប្រាប់ ឬ ជូនដំណឹងជាផ្លូវការថា វត្តមានរបស់គាត់លែងចាំបាច់ទៀតហើយ ឬ ជននោះបានចាកចេញហើយបានវិលត្រឡប់មកវិញដោយស្ម័គ្រចិត្ត ។

៣. ជនណាមានវត្តមាននៅចំពោះមុខ អាជ្ញាធរឬតុលាការមានសមត្ថកិច្ច នៅក្នុងភាគីដាក់សំណើ យោងតាមសំណើធ្វើឡើងក្រោមមាត្រា ១៤ ឬ ១៥ នៃសន្ធិសញ្ញានេះ មិនត្រូវរងនូវការចោទប្រកាន់ ដោយលើកការផ្តល់ចម្លើយបែបនេះទេ លើកលែងតែជននោះត្រូវស្ថិតនៅក្រោមច្បាប់របស់ភាគីដាក់សំណើទាក់ទងនឹងការប្រមាថតុលាការ និងសក្ខីភាពទុច្ចរិត ។

៤. ជនណាមិនយល់ព្រមចូលទៅក្នុងភាគីដាក់សំណើ យោងតាមសំណើធ្វើឡើងក្រោមមាត្រា ១៤ ឬ ១៥ នៃសន្ធិសញ្ញានេះ មិនត្រូវទទួលទោស ឬ ទទួលខុសត្រូវ ដោយគ្រាន់តែផ្អែកលើមូលហេតុនៃការបដិសេធ ឬ មិនបានយល់ព្រមនោះទេ ឬ បើមិនដូច្នោះទេវាធ្វើឱ្យខូចប្រយោជន៍ខាងផ្នែកច្បាប់ ទោះបីវាផ្ទុយទៅនឹងសំណើក៏ដោយ ។

## មាត្រា ១៧
## ការឆ្លងកាត់របស់ជនស្ថិតនៅក្នុងការឃុំឃាំង

១. យោងតាមច្បាប់ និងការអនុវត្តនៅក្នុងស្រុករបស់ខ្លួន ភាគីទទួលសំណើអាចអនុញ្ញាតឱ្យ ភាគីដាក់សំណើ ឬ រដ្ឋទីបី បញ្ជូនជនស្ថិតនៅក្នុងការឃុំឃាំងឆ្លងកាត់ទឹកដីរបស់ខ្លួន ។ ការបង្ហាញខ្លួនដោយផ្ទាល់របស់ជននោះនៅក្នុងរឿងក្តីព្រហ្មទណ្ឌ បានស្នើសុំឡើងដោយភាគីដាក់សំណើ ។

២. បើជននោះត្រូវបានដឹកជញ្ជូន ចុះចត ឬ ឈប់ ដោយយន្តហោះ នាវា ឬរថភ្លើង នៅក្នុងភាគីទទួលសំណើ នោះមន្ត្រីទទួលបន្ទុកគ្រប់គ្រងឬការពាររបស់ភាគីដាក់សំណើ ឬបើអាចអនុវត្តទៅបាន ប្រទេសទីបី ដែលជួយភាគីដាក់សំណើ ដើម្បីបង្កភាពងាយស្រួលដល់ការបញ្ជូននោះ ត្រូវបន្តទទួលខុសត្រូវលើការឃុំឃាំងជនដែលត្រូវដឹកជញ្ជូននោះ នៅពេលជននោះធ្វើដំណើរឆ្លងកាត់ភាគីទទួលសំណើ លើកលែងតែភាគីទទួលសំណើមានការយល់ព្រមផ្សេងពីនេះ ។

៣. ដោយមិនធ្វើឱ្យប៉ះពាល់ដល់កថាខ័ណ្ឌ២ និងដោយមានការយល់ព្រមពីភាគីទទួលសំណើ ជនដែលត្រូវដឹកជញ្ជូន អាចត្រូវរក្សាទុកជាបណ្តោះអាសន្នឱ្យស្ថិតនៅក្នុងការឃុំខ្លួន របស់អាជ្ញាធរមានសមត្ថកិច្ចនៃភាគីទទួលសំណើ រហូតដល់ការដឹកជញ្ជូនជននេះចាប់បន្តដំណើរទៀត ។

៤. បើជនស្ថិតក្រោមការឃុំឃាំងនៅក្នុងភាគីទទួលសំណើ កំពុងធ្វើដំណើរឆ្លងកាត់ ហើយការដឹកជញ្ជូនជននោះ មិនអាចបន្តដំណើរនៅក្នុងពេលវេលាសមហេតុផលនោះទេ ភាគីទទួលសំណើអាចបង្គាប់ឱ្យដឹកជញ្ជូនជននោះ យកទៅឃុំខ្លួននៅក្នុងរដ្ឋទីមួយដែលជននោះត្រូវបានគេដឹកជញ្ជូនចេញមក ។

៥. រាល់ការចេញចំណាយនិងសោហ៊ុយរបស់រដ្ឋទទួលសំណើ ទាក់ទងនឹងកថាខ័ណ្ឌ៣ និង ៤ ត្រូវចេញសងវិញដោយភាគីដាក់សំណើ ។

## មាត្រា ១៨
## ការផែកឆេរ និងការរឹបអូស

១. អនុលោមតាមច្បាប់ក្នុងស្រុករបស់ខ្លួន ភាគីទទួលសំណើត្រូវអនុវត្តសំណើសុំឆែកឆេរ រឹបអូស និង ប្រគល់ឯកសារ កំណត់ហេតុ ឬសំភារៈណាមួយ ឱ្យទៅភាគីដាក់សំណើ ប្រសិនបើមានហេតុផលសមរម្យជឿថា ឯកសារ កំណត់ហេតុ ឬសំភារៈទាំងនោះ មានជាប់ពាក់ព័ន្ធនឹងរឿងក្តីព្រហ្មទណ្ឌ នៅក្នុងភាគីដាក់សំណើ ។

២. ភាគីដាក់សំណើត្រូវគោរពទៅតាមលក្ខខណ្ឌនានាដែលភាគីទទួលសំណើបានដាក់ ទាក់ទងទៅនឹងការរឹបអូសឯកសារ កំណត់ហេតុ ឬសំភារៈណាមួយ ដែលអាចត្រូវប្រគល់ជូនភាគីដាក់សំណើ ហើយដែល

ភាគីទទួលសំណើយល់ឃើញថាចាំបាច់ដើម្បីការពារ ឯកសារ កំណត់ហេតុ ឬសំភារៈ ដែលបានផ្ទេរទាំងនោះ ។

៣. ភាគីទទួលសំណើ ត្រូវជូនដំណឹងទៅភាគីដាក់សំណើ អោយបានឆាប់តាមដែលអាចធ្វើទៅបាន ពីលទ្ធផលនៃការឆែកឆេរ ទីកន្លែងនិងកាលៈទេសៈនៃការរឹបអូស និងការថែរក្សា ឯកសារ កំណត់ហេតុ ឬសំភារៈដែលបានដកហូតជាបន្តបន្ទាប់មក ។

## មាត្រា ១៩
## ការប្រគល់វត្ថុតាងមកវិញ

១. នៅពេលបញ្ចប់រឿងក្តីព្រហ្មទណ្ឌទាក់ទងដល់សំណើសុំជំនួយ ភាគីដាក់សំណើត្រូវបញ្ជូនត្រឡប់ទៅឱ្យភាគីទទួលសំណើវិញនូវ ឯកសារ កំណត់ហេតុ ឬសំភារៈ ដែលបានផ្តល់ជូនភាគីដាក់សំណើ យោងតាមសំណើក្រោមសន្ធិសញ្ញានេះ ។

២. ទោះបីមានចែងនៅក្នុងកថាខ័ណ្ឌ១ក្តី ភាគីដាក់សំណើនៅពេលណាក៏ដោយ បើមានសំណើ ត្រូវបញ្ជូនត្រឡប់មកអោយភាគីទទួលសំណើវិញ ជាបណ្តោះអាសន្ននូវ ឯកសារ កំណត់ហេតុ ឬ សំភារៈដែលបានផ្តល់ជូនភាគីដាក់សំណើ យោងតាមសំណើនៅក្រោមសន្ធិសញ្ញានេះ ប្រសិនបើភាគីទទួលសំណើត្រូវការចាំបាច់ចំពោះឯកសារ កំណត់ហេតុ ឬ សំភារៈទាំងនេះ នៅក្នុងរឿងក្តីព្រហ្មទណ្ឌរបស់ខ្លួន ។

## មាត្រា ២០
## ទីតាំង ឬ អត្តសញ្ញាណរបស់ជនណាមួយ

យោងតាមច្បាប់ក្នុងស្រុករបស់ខ្លួន ភាគីទទួលសំណើត្រូវប្រើប្រាស់ឱ្យអស់នូវកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ដើម្បីបញ្ជាក់អោយច្បាស់ពី ទីកន្លែង ឬ អត្តសញ្ញាណរបស់ជនដូចបានបញ្ជាក់ជូនក្នុងសំណើ ហើយជាជនដែលត្រូវបានគេជឿជាក់ដោយសមហេតុសមផលថា កំពុងស្ថិតនៅក្នុងទឹកដីរបស់ខ្លួន ។

## មាត្រា ២១

## សេវាឯកសារ

១. អនុលោមតាមច្បាប់ក្នុងស្រុករបស់ខ្លួន ភាគីទទួលសំណើត្រូវប្រើប្រាស់អោយអស់នូវកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ដើម្បីផ្តល់សេវាផ្នែកឯកសារណាមួយទាក់ទងនឹងរឿងក្តីព្រហ្មទណ្ឌ ដែលចេញដោយតុលាការរបស់ភាគីដាក់សំណើ ។

២. ភាគីដាក់សំណើ ត្រូវបញ្ជូនសំណើសំរាប់សេវាឯកសារ ដែលតំរូវឱ្យមានការឆ្លើយតប ឬ ការបង្ហាញខ្លួននៅក្នុងភាគីដាក់សំណើ មិនអោយយឺតជាង សាមសិបថ្ងៃ មុនកាលកំណត់ឱ្យឆ្លើយតប ឬ ការបង្ហាញខ្លួនឡើយ ។

៣. ភាគីទទួលសំណើ ត្រូវបញ្ជូនត្រឡប់មកវិញនូវសំអាងនៃសេវា នៅក្នុងរបៀបដែលបានព្រមព្រៀងគ្នាទៅវិញទៅមកដោយភាគីពាក់ព័ន្ធ ។

៤. សំរាប់គោលបំណងនៃកថាខ័ណ្ឌ ៣ ឃ្លា "សំអាងនៃសេវា" រួមមាន ព័ត៌មានទម្រង់ជាលិខិតថ្លែងសច្ចាពីការប្រគល់ជូនឯកសារធ្វើឡើង នៅពេលណា និង យ៉ាងដូចម្តេច និង បើអាចធ្វើទៅបាន បង្កាន់ដៃចុះហត្ថលេខាដោយបុគ្គលដែលបានទទួល ហើយប្រសិនបើមន្ត្រីទទួលបន្ទុកប្រគល់ជូននោះ មិនមានលទ្ធភាពក្នុងការប្រគល់ជូនឯកសារនោះទេ ត្រូវផ្តល់ហេតុផល និង មូលហេតុ ពីការខកខាននេះ ។

## មាត្រា ២២

## ជំនួយក្នុងចំណាត់ការរឹបអូស

១. អនុលោមតាមច្បាប់ក្នុងស្រុករបស់ខ្លួន ភាគីទទួលសំណើត្រូវខិតខំប្រឹងប្រែងរកឱ្យឃើញទីតាំង តាមដានរារាំង បង្កក ដកហូត ឬ រឹបអូសទ្រព្យសម្បត្តិបានមកពីការប្រព្រឹត្តបទល្មើស និងជាមធ្យោបាយបទល្មើស ដើម្បីឱ្យជំនួយរបៀបនេះអាចផ្តល់បាន លុះត្រាតែភាគីដាក់សំណើ ផ្តល់ព័ត៌មានទាំងអស់ដែលភាគីទទួលសំណើយល់ឃើញថាចាំបាច់ ។

២. បើសំណើត្រូវបានធ្វើឡើងតាមកថាខ័ណ្ឌ១ សំណើនោះត្រូវអមជាមួយដីកាច្បាប់ដើមដែលមានចុះហត្ថលេខា ឬ ច្បាប់ចំលងដីកាបញ្ជាក់ថាត្រឹមត្រូវ ។

៣. សំណើសុំជំនួយក្រោមមាត្រានេះ ត្រូវធ្វើឡើងទាក់ទងតែទៅនឹងដីកា ឬ សាលក្រមដែលបានចេញក្រោយពេលសន្ធិសញ្ញានេះចូលជាធរមានប៉ុណ្ណោះ ។

៤. យោងតាមច្បាប់ក្នុងស្រុករបស់ភាគីទទួលសំណើ ទ្រព្យសម្បត្តិដែលត្រូវបានដកហូត ឬ រឹបអូស អនុលោមតាមមាត្រានេះ អាចបន្ថែមពេលវេលាទៅឱ្យភាគីដាក់សំណើ លើកលែងតែមានការព្រមព្រៀងផ្សេងពីនេះ នៅក្នុងករណីជាក់លាក់នីមួយៗ ។

៥. យោងតាមច្បាប់ក្នុងស្រុក និង អនុលោមតាមកិច្ចព្រមព្រៀងជាមួយភាគីដាក់សំណើ ភាគីទទួលសំណើ ត្រូវផ្ទេរទៅឱ្យ ភាគីដាក់សំណើនូវចំណែកទ្រព្យសម្បត្តិដែលបានព្រមព្រៀងនិង ជាទ្រព្យសម្បត្តិទទួលបានតាមមាត្រានេះ ដើម្បីទូទាត់ថ្លៃចំណាយ និងសោហ៊ុយរបស់ភាគីទទួលសំណើ ទៅលើការអនុវត្តវិធីការរឹបអូស ។

## មាត្រា ២៣
## ភាពត្រូវគ្នាជាមួយការរៀបចំផ្សេងទៀត

សន្ធិសញ្ញានេះមិនរារាំងបណ្តាភាគី ក្នុងការផ្តល់ជំនួយអោយគ្នាដោយអនុលោមទៅតាមបណ្តាសន្ធិសញ្ញា ការរៀបចំ ឬ បណ្តាបញ្ញត្តិផ្សេងៗ នៃច្បាប់ជាតិរបស់ពួកគេឡើយ ។

## មាត្រា ២៤
## លិខិតបញ្ជាក់ និង លិខិតយថាភូត

១. ពេលទទួលបានសំណើ ភាគីនីមួយៗ ត្រូវធ្វើលិខិតយថាភូតលើ ឯកសារ ឬ សំភារៈផ្សេងទៀត ដែលត្រូវបញ្ជូនទៅឱ្យភាគីដទៃទៀត ក្រោមសន្ធិសញ្ញានេះ ។

២. ឯកសារដែលត្រូវបញ្ជាក់អោយបានត្រឹមត្រូវ សំរាប់គោលបំណងនៃសន្ធិសញ្ញានេះ ប្រសិនបើ :

(ក) ឯកសារនោះអះអាងដោយការចុះហត្ថលេខា ឬបញ្ជាក់ដោយចៅក្រម ឬ មន្ត្រីដែលនៅក្នុង ឬ របស់ភាគីបញ្ជូនឯកសារ ដែលទទួលបានការអនុញ្ញាតិត្រឹមត្រូវដោយច្បាប់របស់ភាគីនោះ និង

(ខ) មួយណាខាងក្រោម:

(១) ឯកសារនោះត្រូវបានផ្ទៀងផ្ទាត់ដោយសម្បថ ឬបញ្ជាក់អះអាងរបស់សាក្សី ឬ របស់មន្ត្រីរដ្ឋាភិបាលនៃភាគីនោះ ឬ

(២) ឯកសារនោះអះអាងដោយមានបោះត្រាផ្លូវការ ឬ រដ្ឋនៃភាគីនោះ ឬ បោះត្រារដ្ឋមន្ត្រី ឬ របស់ស្ថាប័ន ឬ របស់មន្ត្រីរដ្ឋាភិបាលនៃភាគីនោះ ។

៣. មាត្រានេះមិនបានរារាំងដល់ការបង្ហាញភស្តុតាងនៃបញ្ហាណាមួយ ឬ ការទទួលយកភស្តុតាងនៃឯកសារណាមួយ ស្របទៅតាមច្បាប់របស់ភាគីដាក់សំណើនោះទេ ។

៤. អនុលោមទៅតាមច្បាប់ក្នុងស្រុករបស់ភាគីនីមួយៗ:

(ក) ឯកសារចុះហត្ថលេខាដោយហត្ថលេខាឌីជីថល ឬអេឡិចត្រូនិច ស្របទៅតាមច្បាប់របស់ភាគីពាក់ព័ន្ធ ត្រូវមានចំណងកាតព្វកិច្ចតាមផ្លូវច្បាប់ ដូចឯកសារចុះហត្ថលេខាសរសេរដោយដៃ ស្នាមផ្តិតមេដៃ ឬ សញ្ញាសំគាល់ផ្សេងៗទៀត និង

ខ. ហត្ថលេខាឌីជីថល ឬអេឡិចត្រូនិចបង្កើតឡើង ស្របទៅតាមច្បាប់របស់ភាគីពាក់ព័ន្ធ ត្រូវចាត់ទុកថាជាហត្ថលេខាមានចំណងកាតព្វកិច្ចតាមច្បាប់ ។

## មាត្រា ២៥
## ការចំណាយ

១. ភាគីទទួលសំណើ ត្រូវចេញរាល់ការចំណាយធម្មតាក្នុងការបំពេញតាមសំណើសុំជំនួយ លើកលែងតែភាគីដាក់សំណើទទួលខុសត្រូវក្នុងការចំណាយ :

(ក) សោហ៊ុយសេវាអ្នកប្រឹក្សាដែលបានផ្តល់ តាមសំណើរបស់ភាគីដាក់សំណើ

(ខ) សោហ៊ុយ និងថ្លៃចំណាយលើសាក្សីជំនាញ

(គ) ថ្លៃចំណាយបកប្រែភាសាជាឯកសារ បកប្រែផ្ទាល់មាត់ និងការកត់ត្រា

(ឃ) សោហ៊ុយចំណាយទាក់ទងនឹងការដឹកជញ្ជូនជនណាមួយ ទៅកាន់ ឬ មកពីដែនដីរបស់ភាគីទទួលសំណើ និង សោហ៊ុយ ប្រាក់ឧបត្ថម្ភ និងថ្លៃចំណាយទៅលើជនពាក់ព័ន្ធនោះ ក្នុងខណៈដែលជននោះ ស្ថិតនៅក្នុងភាគីដាក់សំណើ អនុលោមតាមសំណើធ្វើឡើងក្រោមមាត្រា ១៤ ឬ ១៥នៃសន្ធិសញ្ញានេះ និង

(ង) ចំណាយទាក់ទងដល់មន្ត្រីទទួលបន្ទុកដឹកជញ្ជូន ឃុំឃាំង ឬ ការពារ ។

២. ផរាបណាបណ្តាភាគីមានការព្រមព្រៀងផ្សេងពីនេះ ភាគីដាក់សំណើត្រូវចេញសងអោយទៅភាគីទទួលសំណើវិញទៅលើ ថ្លៃចំណាយក្នុងការបង្កើតការតភ្ជាប់បណ្តាញវីដេអូ ឬទូរទស្សន៍បន្តផ្ទាល់ ឬឧបករណ៍សំរួលដល់ការប្រាស្រ័យទាក់ទងសមស្របផ្សេងៗទៀត ថ្លៃចំណាយទាក់ទងនឹងសេវាតភ្ជាប់បណ្តាញវីដេអូ ឬទូរទស្សន៍បន្តផ្ទាល់ ឬ ឧបករណ៍សំរួលដល់ការប្រាស្រ័យទាក់ទងសមស្របផ្សេងៗទៀត ប្រាក់ឈ្នួលបកប្រែភាសាដោយផ្ទាល់មាត់ផ្តល់ដោយភាគីទទួលសំណើ និងប្រាក់ឧបត្ថម្ភដល់សាក្សី និងថ្លៃចំណាយលើការធ្វើដំណើររបស់ពួកគេ ទៅក្នុងភាគីទទួលសំណើ ។

៣. ប្រសិនបើ ក្នុងអំឡុងពេលនៃការអនុវត្តសំណើ បានបង្ហាញច្បាស់ពីតំរូវការបំពេញតាមសំណើដោយការចំណាយមានលក្ខណៈខុសធម្មតា ឬតំលៃថ្លៃ នោះគូភាគីត្រូវពិគ្រោះយោបល់គ្នា ដើម្បីកំណត់លក្ខខណ្ឌអនុវត្តសំណើ ឱ្យអនុវត្តបាន ឬបន្តទៅទៀត ។

## មាត្រា ២៦
## ការពិគ្រោះយោបល់

១. នៅពេលមានការព្រមព្រៀងគ្នាទៅវិញទៅមករវាងបណ្តាភាគី អាជ្ញាធរកណ្តាលនៃភាគី ត្រូវពិគ្រោះយោបល់គ្នា ដើម្បីជំរុញការប្រើប្រាស់សន្ធិសញ្ញានេះអោយមានប្រសិទ្ធភាពខ្ពស់បំផុត ។

២. បណ្តាភាគី អាចបង្កើតនូវវិធានការអនុវត្តបែបនេះ ដែលអាចជាការចាំបាច់ ដើម្បីជួយសំរួលដល់ការអនុវត្តសន្ធិសញ្ញានេះ ។

## មាត្រា ២៧
## វិសោធនកម្ម

១. សន្ធិសញ្ញានេះ អាចត្រូវធ្វើការកែសំរួល ឬធ្វើវិសោធនកម្មនៅពេលណាមួយ តាមរយៈការព្រមព្រៀងជាលាយលក្ខណ៍អក្សរដោយបណ្តាភាគី ។ ការកែសំរួល ឬ វិសោធនកម្មបែបនេះ នឹងចូលជាធរមានតាមកាលបរិច្ឆេទ ដូចបណ្តាភាគីអាចមានការព្រមព្រៀងគ្នាទៅវិញទៅមក ហើយនឹងក្លាយទៅជាផ្នែកមួយនៃសន្ធិសញ្ញានេះ ។

២. រាល់ការកែសំរួល ឬ វិសោធនកម្ម នឹងមិនប៉ះពាល់ដល់សិទ្ធិ ឬ កាតព្វកិច្ចដែលកើតចេញពី ឬ ដែលផ្អែកលើសន្ធិសញ្ញានេះ នៅមុនពេល ឬ រហូតដល់កាលបរិច្ឆេទ ដែលការកែសំរួលឬវិសោធនកម្មនេះចូលជាធរមានឡើយ ។

## មាត្រា ២៨
## ដំណោះស្រាយវិវាទ

រាល់ការខ្វែងគំនិត ឬ វិវាទរវាងបណ្តាភាគីដែលកើតចេញពីការបកស្រាយ ឬ ការអនុវត្តបទប្បញ្ញត្តិនៃសន្ធិសញ្ញានេះ ត្រូវដោះស្រាយប្រកបដោយមេត្រីភាព តាមរយៈការពិគ្រោះយោបល់ ឬ ការចរចារវាងបណ្តាភាគី តាមរយៈបណ្តាញការទូត ឬមធ្យោបាយដោយសន្តិវិធីផ្សេងៗទៀត សំរាប់ដោះស្រាយវិវាទដូចតាមការព្រមព្រៀងគ្នារបស់បណ្តាភាគី ។

## មាត្រា ២៩
## ខដាក់លក្ខខណ្ឌ

សន្ធិសញ្ញានេះ មិនមានខដាក់លក្ខខណ្ឌឡើយ ។

## មាត្រា ៣០
## ចុះហត្ថលេខា ផ្តល់សច្ចាប័ន ការចូលជាសមាជិក ការតំកល់ និងការចុះបញ្ជី

១. សន្ធិសញ្ញានេះ តំរូវអោយមានការផ្តល់សច្ចាប័ន ការទទួលយក ការអនុម័ត ឬ ការចូលជាសមាជិក ស្របទៅតាមនីតិវិធីរដ្ឋធម្មនុញ្ញរបស់បណ្តារដ្ឋហត្ថលេខី ។

២. រដ្ឋណាមួយ អាចចូលរួមនៅក្នុងសន្ធិសញ្ញានេះបាន អាស្រ័យដោយការយល់ព្រមជាទូទៅពី បណ្តាភាគីដើម ។

៣. លិខិតុបករណ៍នៃការផ្តល់សច្ចាប័ន ការទទួលយក ការអនុម័ត ឬការចូលជាសមាជិក ត្រូវដាក់តំកល់នៅរដ្ឋាភិបាលម៉ាឡេស៊ី ដែលបានចាត់តាំងឡើងជារដ្ឋតំកល់សន្ធិសញ្ញានេះ ។

៤. រដ្ឋតំកល់សន្ធិសញ្ញា ត្រូវជូនដំណឹងដល់បណ្តារដ្ឋផ្សេងៗទៀតដែលជាភាគីនៃសន្ធិសញ្ញានេះ ពីការតំកល់លិខិតុបករណ៍នៃការផ្តល់សច្ចាប័ន ការទទួលយក ការអនុម័ត ឬ ការចូលជាសមាជិក ។

៥. រដ្ឋតំកល់សន្ធិសញ្ញា ត្រូវចុះបញ្ជីសន្ធិសញ្ញានេះ អនុលោមតាមមាត្រា១០២ របស់ធម្មនុញ្ញសហប្រជាជាតិ ។

## មាត្រា ៣១
## ការចូលជាធរមាន ការអនុវត្ត និងការបញ្ចប់

១. សន្ធិសញ្ញានេះ ត្រូវចូលជាធរមានសំរាប់ភាគីនីមួយៗដែល ផ្តល់សច្ចាប័ន ទទួលយក អនុម័ត ឬ ចូលជាសមាជិកនៃសន្ធិសញ្ញានេះ ទៅតាមកាលបរិច្ឆេទតំកល់លិខិតុបករណ៍របស់ខ្លួន នៃការផ្តល់សច្ចាប័ន ការទទួលយក ការអនុម័ត ឬ ការចូលជាសមាជិក ។

២. សន្ធិសញ្ញានេះ ត្រូវអនុវត្តចំពោះសំណើដែលបានដាក់ជូន បន្ទាប់ពីកាលបរិច្ឆេទចូលជាធរមានទាំងបណ្តាភាគីពាក់ព័ន្ធ ទោះបីជាអំពើ ឬការខកខានបង្កើតជាបទល្មើស បានកើតឡើងមុន ឬក្រោយកាលបរិច្ឆេទនោះក៏ដោយ ។

៣. ភាគីណាមួយ អាចប្រកាសមិនយល់ព្រមទៅលើសន្ធិសញ្ញានេះបាន តាមរយៈសេចក្តីជូនដំណឹង ជាលាយលក្ខណ៍អក្សរ ជូនចំពោះរដ្ឋតំកល់សន្ធិសញ្ញា ។ ការប្រកាសមិនយល់ព្រម ត្រូវចាប់មានប្រសិទ្ធភាពក្នុងរយៈពេលប្រាំមួយខែ បន្ទាប់ពីកាលបរិច្ឆេទដែលរដ្ឋតំកល់សន្ធិសញ្ញា ទទួលសេចក្តីជូនដំណឹងនេះ ។

៤. ការប្រកាសមិនយល់ព្រមលើសន្ធិសញ្ញានេះ មិនត្រូវប៉ះពាល់ដល់សិទ្ធិ និងកាតព្វកិច្ចដែលកើតចេញពី ឬផ្អែកលើសន្ធិសញ្ញានេះទេ និង មិនត្រូវប៉ះពាល់ដល់ការបញ្ចប់សំណើសុំណាមួយ យោងតាមសន្ធិសញ្ញានេះ នៅមុនពេល ឬ រហូតដល់កាលបរិច្ឆេទ នៃការប្រកាសមិនយល់ព្រមលើសន្ធិសញ្ញានេះឡើយ ។

៥. ការប្រកាសមិនយល់ព្រមលើសន្ធិសញ្ញានេះ ត្រូវមានប្រសិទ្ធិភាពចំពោះតែភាគីដែលបានជូនដំណឹងប៉ុណ្ណោះ ។ សន្ធិសញ្ញានេះ ត្រូវស្ថិតនៅជាធរមាន សំរាប់ភាគីផ្សេងដទៃទៀត ។

## មាត្រា ៣២
## ការតំកល់សន្ធិសញ្ញា

ច្បាប់ដើមនៃសន្ធិសញ្ញានេះ ត្រូវតំកល់ទុកនៅឯរដ្ឋតំកល់សន្ធិសញ្ញា ហើយរដ្ឋនេះ ត្រូវផ្ញើជូនច្បាប់ចំលងសន្ធិសញ្ញា ដោយបញ្ជាក់ត្រឹមត្រូវទៅអោយគ្រប់ភាគីទាំងអស់ ។

ដើម្បីជាសក្ខីភាពនៅក្នុងសន្ធិសញ្ញានេះ ហត្ថលេខីដែលត្រូវបានអនុញ្ញាតត្រឹមត្រូវ ឱ្យធ្វើជាតំណាងរដ្ឋាភិបាលនីមួយៗ បានចុះហត្ថលេខាលើសន្ធិសញ្ញានេះ ។

ធ្វើនៅកូឡាឡាំពួរ ថ្ងៃទី ២៩ ខែវិច្ឆិកា ឆ្នាំ ២០០៤ មានមួយច្បាប់ដើមជាភាសាអង់គ្លេស ។

តំណាងរដ្ឋាភិបាលប្រ៊ុយណេដារ៉ូសាឡឹម

..........................................

ដាតូ សេរី ផាំឌូកា ហាជីគីហ្វ្រាវី
ដាតូ ផាំឌូកា ហាជីគីហ្វ្រី
*មហាអយ្យការ*

តំណាងរដ្ឋាភិបាលព្រះរាជាណាចក្រកម្ពុជា

..........................................

អង្គ វង្ស វឌ្ឍនា
*រដ្ឋមន្ត្រីក្រសួងយុត្តិធម៌*

តំណាងរដ្ឋាភិបាលសាធារណរដ្ឋឥណ្ឌូណេស៊ី

..........................................

បណ្ឌិត ហាមីដ អាវ៉ាលូឌីន
*រដ្ឋមន្ត្រីក្រសួងច្បាប់ និងសិទ្ធិមនុស្ស*

តំណាងរដ្ឋាភិបាលសាធារណរដ្ឋប្រជាធិបតេយ្យ ប្រជាមានិតឡាវ

..........................................

ខាំ អួន បូផា
*រដ្ឋមន្ត្រីក្រសួងយុត្តិធម៌*

តំណាងរដ្ឋាភិបាលម៉ាឡេស៊ី

..........................................

តាន់ ស្រ៊ីអាប់ឌុលហ្គានីប៉ាតៃ
*មហាអយ្យការ*

តំណាងរដ្ឋាភិបាលសាធារណរដ្ឋហ្វីលីពីន

..........................................

ម៉ាកាបាងគីត ឡាខេតូ
*អនុរដ្ឋមន្ត្រីក្រសួងយុត្តិធម៌*

តំណាងរដ្ឋាភិបាលសាធារណរដ្ឋសឹង្ហបុរី

..........................................

ចាន់ សិកគ័ង
*មហាអយ្យការ*

តំណាងរដ្ឋាភិបាលសាធារណរដ្ឋសង្គមនិយមវៀតណាម

..........................................

ឡេ ថេទាម
*អនុរដ្ឋមន្ត្រីក្រសួងសន្តិសុខសាធារណៈ*

ហើយបន្ថែមទៅលើ ការយល់ព្រមជាទូទៅរបស់រដ្ឋហត្ថលេខីដែលហៅថា សហភាពមីយ៉ាន់ម៉ា , និង ព្រះរាជាណាចក្រថៃឡង់ដ៏ គួរចុះហត្ថលេខា និងផ្តល់សច្ចាប័នផងដែរទៅលើសន្ធិសញ្ញានេះ ក្នុងឋានៈជាភាគីដើម ហត្ថលេខីដែលត្រូវបានអនុញ្ញាតត្រឹមត្រូវ ឱ្យធ្វើជាតំណាងរដ្ឋាភិបាលនីមួយៗ បានចុះហត្ថលេខាលើសន្ធិសញ្ញានេះ។

ចុះហត្ថលេខានៅកូឡាឡាំពួរ ថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៦។

| តំណាងរដ្ឋាភិបាលសហភាពមីយ៉ាន់ម៉ា | តំណាងរដ្ឋាភិបាលព្រះរាជាណាចក្រថៃឡង់ដ៍ |
| --- | --- |
| ........................ | ........................... |
| អ៊ូ យិន អុង | តាំចារ៉ាយុទ្ធ ហាម៉ាំរ៉ាំរ៉ុង |
| *ឯកអគ្គរដ្ឋទូតសហភាពមីយ៉ាន់ម៉ាប្រចាំប្រទេសម៉ាឡេស៊ី* | *មហាអយ្យការ* |

ឆ្នាំទី ៥ លេខ ៨៣ ថ្ងៃ ទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០០៥ រាជកិច្ច ទំព័រ ៦៧៦៧

# ព្រះរាជក្រម

នស/រកម/១០០៥/០២៦

## យើង

## ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាស ឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងការពារជាតិ
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយ របស់សម្ដេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរបស់សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

## ប្រកាសឱ្យប្រើ

ច្បាប់ស្ដីពីការអនុម័តយល់ព្រម ឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាសមាជិក នៃអនុសញ្ញាស្ដីពីការបង្ក្រាបអំពើខុសច្បាប់ទៅនឹងសុវត្ថិភាពនៃការធ្វើនាវាចរណ៍តាមដែនសមុទ្រ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០០៥ នាសម័យ ប្រជុំរដ្ឋសភាលើកទី ៣ នីតិកាលទី ៣ និងព្រឹទ្ធសភាបានអនុម័តយល់ស្របលើទម្រង់ និងគតិនៃច្បាប់នេះ ទាំងស្រុងកាលពីថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០០៥ នាសម័យប្រជុំពេញអង្គលើកទី ១០ នីតិកាលទី ១ ដែលមានសេចក្ដីទាំងស្រុងដូចតទៅនេះ :

ឆ្នាំទី ៥ លេខ ៤៣ ថ្ងៃ ទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០០៥ រាជកិច្ច ទំព័រ ៦៧៦៨

# ច្បាប់
# ស្តីពី
# ការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាសមាជិកនៃ អនុសញ្ញាស្តីពីការបង្ក្រាបអំពើខុសច្បាប់ទៅនឹងសុវត្ថិភាពនៃ ការធ្វើនាវាចរណ៍តាមដែនសមុទ្រ

**មាត្រា ១.–**

អនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាសមាជិកនៃអនុសញ្ញាស្តីពីការបង្ក្រាបអំពើខុសច្បាប់ទៅនឹងសុវត្ថិភាពនៃការធ្វើនាវាចរណ៍តាមដែនសមុទ្រ ដែលធ្វើនៅទីក្រុងរ៉ូម នាថ្ងៃទី ១០ ខែ មីនា ឆ្នាំ ១៩៨៨ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

**មាត្រា ២.–**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តអនុសញ្ញានេះ ។

**មាត្រា ៣.–**

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០០៥

នស/រកម.១០០៥.០២៦

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

ហត្ថលេខា

ហ៊ុន សែន

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

ហត្ថលេខា

ទៀ បាញ់ ញឹក ប៊ុនឆៃ

លេខៈ ៣៩៨ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែ ១០ ឆ្នាំ២០០៥

អគ្គលេខាធិការរាជរដ្ឋាភិបាល

ឥនាទ តាន់

**ប្រការ ២១ :**

១-ស្របតាមច្បាប់របស់ខ្លួន រដ្ឋម្ចាស់ផ្ទះត្រូវសម្រួលដល់រដ្ឋដាក់ទូតនូវទីស្ថានចាំបាច់សំរាប់បេសកកម្ម ក្នុងការទិញលំនៅស្ថាន ឬជួយបេសកកម្មស្វែងរកលំនៅស្ថាន តាមមធ្យោបាយផ្សេងៗនៅលើទឹកដីរបស់ខ្លួន ។

២-ប្រសិនបើចាំបាច់ រដ្ឋម្ចាស់ផ្ទះត្រូវជួយដល់បណ្ដាបេសកកម្មឱ្យរកបាននូវលំនៅស្ថានសមរម្យសំរាប់សមាជិករបស់គេ ។

**ប្រការ ២២ :**

១-ទីស្ថានបេសកកម្ម មិនអាចត្រូវបំពារបំពានបានឡើយ ។ បណ្ដាភ្នាក់ងាររបស់រដ្ឋម្ចាស់ផ្ទះ មិនអាចចូលទៅក្នុងទីស្ថានបេសកកម្មនោះ ដោយគ្មានការយល់ព្រមពីប្រមុខបេសកកម្មបានឡើយ ។

២-រដ្ឋម្ចាស់ផ្ទះ មានកាតព្វកិច្ចពិសេស ក្នុងការចាត់គ្រប់វិធានការណ៍សមស្រប ដើម្បីទប់ស្កាត់ មិនឱ្យទីស្ថានបេសកកម្មត្រូវបំពារបំពាន ឬត្រូវខូចខាត និងរារាំងរាល់ការរំខានភាពស្ងប់ស្ងាត់របស់បេសកកម្ម ឬភាពថ្លៃថ្នូររបស់បេសកកម្ម ។

៣-ទីស្ថានបេសកកម្ម គ្រឿងសង្ហារឹម និងវត្ថុផ្សេងៗទៀតនៅទីនោះ ក៏ដូចជាមធ្យោបាយដឹកជញ្ជូនរបស់បេសកកម្ម មិនអាចត្រូវឆែកឆេរ កំណែន រឹបអូស ឬអនុវត្តតាមសេចក្ដីសំរេចរបស់តុលាការឡើយ ។

**ប្រការ ២៣ :**

១-រដ្ឋដាក់ទូត និងប្រមុខបេសកកម្ម ត្រូវបានរួចពីការបង់ពន្ធ និងអាករទាំងអស់របស់ជាតិ ថ្នាក់តំបន់ ឬឃុំ ចំពោះទីស្ថានបេសកកម្មដែលខ្លួនជាម្ចាស់កម្មសិទ្ធិ ឬជាអ្នកជួល ដែលមិនមែនជាពន្ធ ឬអាករដែលហួតជាបំណាច់នៃសេវាដោយឡែកដែលបានធ្វើ ។

បានចាត់ទុកជាហាវីទូតទេ ។ បេសកកម្មការទូត អាចបញ្ជូនសមាជិកម្នាក់របស់ខ្លួនឱ្យទៅទទួលយកហឹបទូតពីដៃនាយអាកាសយានដោយផ្ទាល់ និងដោយសេរី ។

**ប្រការ ២៨ :**

ពន្ធ និងអាករនានា ដែលបេសកកម្មការទូតប្រមូលបាន ដោយការចេញលិខិតស្នាមផ្លូវការផ្សេងៗ ត្រូវរួចពន្ធ និងអាករទាំងអស់ ។

**ប្រការ ២៩ :**

បុគ្គលភ្នាក់ងារទូត មិនអាចត្រូវបំពារបំពានបានទេ ។ ភ្នាក់ងារទូតមិនអាចត្រូវចាប់ ឬឃុំខ្លួនតាមបែបណាមួយបានឡើយ ។ រដ្ឋម្ចាស់ផ្ទះ រាប់អានភ្នាក់ងារទូតដោយការគោរព និងត្រូវចាត់គ្រប់វិធានការណ៍សមស្រប ដើម្បីរារាំងមិនឱ្យមានការបំពារបំពានណាមួយលើរូបកាយ សេរីភាព និងភាពថ្លៃថ្នូររបស់គេ ។

**ប្រការ ៣០ :**

១-លំនៅឯកជនរបស់ភ្នាក់ងារទូត ក៏ទទួលបាននូវសិទ្ធិមិនអាចបំពារបំពានបាន និងការរក្សាការពារ ដូចទីស្ថានបេសកកម្មការទូតដែរ ។

២-បណ្ណាឯកសារ ការឆ្លើយឆ្លង និងទ្រព្យសម្បត្តិរបស់ភ្នាក់ងារទូត ក៏ទទួលសិទ្ធិ មិនអាចបំពារបំពានបានដែរ វៀរលែងតែកថាខ័ណ្ឌ៣នៃប្រការ៣១។

**ប្រការ ៣១ :**

១-ភ្នាក់ងារទូត មានអភ័យឯកសិទ្ធិចំពោះអំណាចយុត្តាធិការព្រហ្មទ័ណ្ឌរបស់រដ្ឋម្ចាស់ផ្ទះ ។ គេមានអភ័យឯកសិទ្ធិផងដែរចំពោះអំណាចយុត្តាធិការរដ្ឋប្បវេណី និងរដ្ឋបាល លើកលែងតែករណី:

ក-បណ្តឹងពាក់ព័ន្ធនឹងកម្មសិទ្ធិលើអសង្ហារិមឯកជន ដែលស្ថិតនៅលើទឹកដីរបស់រដ្ឋម្ចាស់ផ្ទះ បើសិនជាភ្នាក់ងារទូតនោះមិនកាន់កាប់អសង្ហារិមនេះ ក្នុងនាមរដ្ឋដាក់ទូត និងដើម្បីទិសដៅបេសកកម្មនោះ ។

ខ-បណ្តឹងពាក់ព័ន្ធនឹងមរតក ដែលក្នុងនោះភ្នាក់ងារទូតជាអ្នកប្រតិបត្តិតាមមរតកសាសន៍ ជាអ្នកគ្រប់គ្រង ជាអ្នកទទួលមរតក ឬជាអ្នកទទួលអច្ច័យទានក្នុងនាមជាឯកជន ហើយមិនមែនក្នុងនាមរដ្ឋដាក់ទូត ។

គ-បណ្តឹងពាក់ព័ន្ធនឹងសកម្មភាពវិជ្ជាជីវៈ ឬពាណិជ្ជកម្មដែលភ្នាក់ងារទូតបានធ្វើក្នុងរដ្ឋម្ចាស់ផ្ទះ ក្រៅពីមុខងារផ្លូវការរបស់ខ្លួន ។

២-ភ្នាក់ងារទូត មិនមានកាតព្វកិច្ចត្រូវផ្តល់ភស្តុតាងជាសាក្សីទេ ។

៣-គ្មានវិធានការអនុវត្តសាលក្រមណាមួយ អាចត្រូវធ្វើឡើងទៅលើភ្នាក់ងារទូតទេ វៀរលែងតែក្នុងករណីដែលបានចែងក្នុងវគ្គខ័ណ្ឌ ក ខ គ នៃកថាខ័ណ្ឌ១នៃប្រការនេះ ហើយលុះណាតែការអនុវត្តនោះ មិនបានធ្វើឱ្យប៉ះពាល់ដល់ភាពមិនអាចត្រូវគេបំពារបំពានលើបុគ្គល ឬលើទីលំនៅរបស់ភ្នាក់ងារទូតរូបនោះ ។

៤-អភ័យឯកសិទ្ធិរបស់ភ្នាក់ងារទូត ចំពោះអំណាចយុត្តាធិការនៃរដ្ឋម្ចាស់ផ្ទះ មិនបានលើកលែងដល់ភ្នាក់ងារទូតរូបនោះ ឱ្យរួចផុតពីអំណាចយុត្តាធិការរបស់រដ្ឋដាក់ទូតឡើយ ។

**ប្រការ ៣២ :**

១-រដ្ឋដាក់ទូតអាចបោះបង់អភ័យឯកសិទ្ធិចំពោះអំណាចយុត្តាធិការសំរាប់ភ្នាក់ងារទូត និងជនទាំងឡាយដែលទទួលនូវអភ័យឯកសិទ្ធិ ដែលចែងក្នុងប្រការ ៣៧ ។

២-ការបោះបង់នេះ ត្រូវបញ្ជាក់ឱ្យច្បាស់លាស់ជានិច្ច ។

៣-ប្រសិនបើភ្នាក់ងារទូតម្នាក់ ឬជនម្នាក់ដែលទទួលអភ័យឯកសិទ្ធិចំពោះអំណាចយុត្តាធិការ តាមខ្លឹមសារនៃប្រការ៣៧ ដាក់ពាក្យបណ្តឹងទៅតុលាការភ្នាក់ងាររូបនោះនឹងអស់សិទ្ធិលើកសំអាងពីអភ័យឯកសិទ្ធិចំពោះអំណាចយុត្តាធិការលើពាក្យបណ្តឹងតបវិញ ដែលទាក់ទងដោយផ្ទាល់ទៅនឹងពាក្យបណ្តឹងដើម ។

៤-ការបោះបង់អភ័យឯកសិទ្ធិចំពោះអំណាចយុត្តាធិការលើបណ្តឹងផ្នែករដ្ឋប្បវេណី ឬរដ្ឋបាល មិនត្រូវចាត់ទុកជាការបោះបង់អភ័យឯកសិទ្ធិ ចំពោះវិធានការអនុវត្តសាលក្រមឡើយ ។ ការបោះបង់អភ័យឯកសិទ្ធិបែបនោះ ចាំបាច់ត្រូវធ្វើការបដិសេធមួយដាច់ដោយឡែក ។

**ប្រការ ៣៣ ៖**

១-ទាក់ទងនឹងបទបញ្ញត្តិកថាខ័ណ្ឌ៣នៃប្រការនេះ ភ្នាក់ងារទូតត្រូវបានរួចផុតពីបទបញ្ញត្តិស្តីពីសន្តិសុខសង្គម(social security provisions) ដែលអាចស្ថិតជាធរមាននៅក្នុងរដ្ឋម្ចាស់ផ្ទះ លើសេវាទាំងឡាយដែលបានធ្វើជូនរដ្ឋម្ចាស់ផ្ទះ ។

២-ការរួចផុតដែលចែងក្នុងកថាខ័ណ្ឌ១នៃប្រការនេះ ក៏អនុវត្តផងដែរចំពោះអ្នកបំរើឯកជនដែលបំរើការងារដាច់មុខឱ្យភ្នាក់ងារទូតក្នុងល័កខ័ណ្ឌ ៖

ក-អ្នកបំរើទាំងនោះ មិនមែនជាពលរដ្ឋរបស់រដ្ឋម្ចាស់ផ្ទះ ឬអ្នកស្នាក់នៅអចិន្ត្រៃយ៍ក្នុងរដ្ឋម្ចាស់ផ្ទះ ហើយ

ខ-អ្នកបំរើទាំងនោះ ស្ថិតនៅក្រោមបទបញ្ញត្តិសន្តិសុខសង្គមដែលអាចស្ថិតនៅជាធរមានក្នុងរដ្ឋដាក់ទូត ឬក្នុងរដ្ឋដទៃទៀត ។

៣-ភ្នាក់ងារទូតណាដែលប្រើប្រាស់ ក្នុងការងាររបស់ខ្លួននូវជនទាំងឡាយណាដែលការរួចផុតចែងក្នុងកថាខ័ណ្ឌ២នៃប្រការនេះ មិនអាចយកមកអនុវត្តបានត្រូវគោរពកាតព្វកិច្ចដែលបទបញ្ញត្តិស្តីពីសន្តិសុខសង្គមរបស់រដ្ឋម្ចាស់ផ្ទះ ដាក់ឱ្យនិយោជកអនុវត្ត ។

ភ្នំពេញ , ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ១៩៩៣

**សេចក្ដីសំរេច លេខ ១២ សសរ**

**ស្ដីពីការឆ្លាក់ និង ប្រើប្រាស់ត្រារបស់ក្រសួង**

**ស្ថាប័ន រដ្ឋអំណាចគ្រប់ជាន់ថ្នាក់**

* * * *

**រដ្ឋាភិបាលជាតិបណ្ដោះអាសន្ននៃកម្ពុជា**

- បានឃើញក្រឹត្យរបស់សម្ដេចព្រះឧបយុវរាជ នរោត្តម សីហនុ ប្រមុខរដ្ឋ នៃកម្ពុជា ចុះថ្ងៃទី ០២ ខែ កក្កដាឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរដ្ឋាភិបាលជាតិបណ្ដោះអាសន្ននៃកម្ពុជា
- យោងសារាចរ ចុះថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ ១៩៩៣ ស្ដីពីនាមប្រទេស ទង់ជាតិ ភ្លេងជាតិ និង ព្រះឆាយាលក្ខណ៍
- ពិនិត្យតាមសំណូមពរចាំបាច់ ក្នុងសភាពការណ៍បច្ចុប្បន្ន

សំរេច

ប្រការ ១ : អនុញ្ញាតអោយគ្រប់ក្រសួង ស្ថាប័ន រដ្ឋអំណាចគ្រប់ជាន់ថ្នាក់ប្រើប្រាស់ត្រាថ្មី ដែលមានរូបភាពប្រាសាទកំពូលបីជុំវិញរង្វង់ដែលសរសេរអក្សរឈ្មោះកម្ពុជា នៅខាងលើ និង ឈ្មោះអង្គភាពនៅខាងក្រោម ។

ប្រការ ២ : គំរូត្រាទាំងអស់ត្រូវមានការយល់ព្រមពីរដ្ឋាភិបាលជាតិបណ្ដោះអាសន្ននៃ កម្ពុជា
- ប្រគល់ភារកិច្ចអោយក្រសួងមហាផ្ទៃ និង សន្តិសុខជាតិ កំណត់ពីរូបភាពទំហំ និង ផ្ទាក់អោយប្រើប្រាស់តាមលំដាប់ថ្នាក់ ។

ប្រការ ៣ : គ្រប់ក្រសួងស្ថាប័ន និង អភិបាលគ្រប់ខេត្ត ក្រុង ធ្វើបញ្ជីរាយនាមឈ្មោះអង្គភាព ដែលត្រូវប្រើប្រាស់ត្រា ហើយមកទំនាក់ទំនងជាមួយក្រសួងមហាផ្ទៃ និង សន្តិសុខជាតិ ដើម្បីឆ្លាក់ជូនប្រើប្រាស់ ។

ប្រការ ៤ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានស្ថាប័ន និង អភិបាលគ្រប់ ខេត្ត ក្រុង មានភារកិច្ចអនុវត្តសេចក្ដីសំរេចនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខានេះតទៅ ។

សហប្រធាន

**រដ្ឋាភិបាលជាតិបណ្ដោះអាសន្ននៃកម្ពុជា**

ព្រះហស្តលេខា និង ហត្ថលេខា

ស្ដេចក្រុមហ្លួង **នរោត្តម រណឫទ្ធិ** ហ៊ុន សែន

ធ្វើនៅភ្នំពេញ , ថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ ១៩៩៣

**សារាចរ**

**ស្ដីពី**

**នាមប្រទេស ទង់ជាតិ ភ្លេងជាតិ**

**និង ព្រះឆាយាលក្ខណ៍**

* * * *

យោងតាមក្រឹត្យរបស់ព្រះប្រមុខរដ្ឋ នៃកម្ពុជា ចុះថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ១៩៩៣ រដ្ឋាភិបាលជាតិបណ្ដោះអាសន្នកម្ពុជា សូមធ្វើការណែនាំគ្រប់ក្រសួងស្ថាប័ន និង គ្រប់អភិបាលខេត្ត ក្រុងដូចតទៅ ÷

១. នាមរបស់រដ្ឋកម្ពុជាគឺ " កម្ពុជា " ជាភាសាខ្មែរ Cambodge ជាភាសាបារាំង និង Cambodia ជាភាសាអង់គ្លេស ។

២. ទង់ជាតិរបស់កម្ពុជាគឺ ទង់ជាតិដែលកម្ពុជាធ្លាប់មានមុនថ្ងៃទី ១៨ ខែ មិនា ឆ្នាំ ១៩៧០ ។ គំរូនិងខ្នាតនឹងផ្ញើជូននៅពេលក្រោយ ។

៣. ភ្លេងជាតិ នៃកម្ពុជា គឺ បទនគររាជ ដែលកម្ពុជាធ្លាប់មានជំនាន់ទសវត្ស ៤០ ៥០ និង ៦០ ដោយដកនូវឃ្លាចំរៀងទី ១ ចេញ ចំណែកឯអក្សរភ្លេងវិញ គឺនៅដដែល ឥតមានផ្លាស់ប្ដូរឡើយ ។

ដោយឡែក រដ្ឋាភិបាលជាតិបណ្ដោះអាសន្នកម្ពុជាបានសំរេចថា នៅគ្រប់ទីកន្លែងធ្វើការរបស់ទីស្ដីការ ក្រសួង ស្ថាប័ន មន្ទីរ អង្គភាព ត្រូវតាំងព្រះឆាយាលក្ខណ៍នៃសម្ដេច ព្រះនរោត្ដម សីហនុ ព្រះប្រមុខរដ្ឋដែលជាព្រះបិតាជាតិ ជាទីសក្ការៈរបស់យើង ។ គំរូព្រះឆាយាលក្ខណ៍ នឹងផ្ញើជូននៅពេលក្រោយ ។

សារាចរនេះ ត្រូវអនុវត្តចាប់ពីពេលនេះតទៅ ។

**សហប្រធាន**

**នៃរដ្ឋាភិបាលជាតិបណ្ដោះអាសន្នកម្ពុជា**

ព្រះហស្ដលេខា ហត្ថលេខា

ខេមបូឌា ដេលី
The Cambodia Daily

មាតិកា

# សមាជិករណសិរ្សរំដោះជាតិខ្មែរបដិសេធថាមិនបានរៀបចំផែនការផ្តួលរំលំរដ្ឋាភិបាល

ដោយ រីកា ម៉េងឡេង | ថ្ងៃអង្គារ ទី 20 ខែឧសភា ឆ្នាំ2014

F T L E W

ហេន ចាន់ អាយុ៣៣ឆ្នាំ ជាសមាជិករណសិរ្សរំដោះជាតិខ្មែរ ដែលត្រូវបានចាប់ខ្លួនកាលពីសប្តាហ៍មុន និងត្រូវបានចោទប្រកាន់ពីបទក្លែងបន្លំលិខិតឆ្លងដែន និងរៀបចំផែនការផ្តួលរំលំរដ្ឋាភិបាលនោះ បាននិយាយនៅតុលាការកាលពីម្សិលមិញថា គាត់មិនមានគោលបំណងហិង្សាទេ ហើយគ្រាន់តែមានផែនការផ្សព្វផ្សាយសៀវភៅរិះគន់រដ្ឋាភិបាលប៉ុណ្ណោះ។

លោក ហេន ចាន់ បាននិយាយនៅក្នុងបន្ទប់រង់ចាំទាំងដៃជាប់ខ្នោះ ស្លៀកពាក់ឯកសណ្ឋានពន្ធនាគារពណ៌ទឹកក្រូចនៅមុនពេលសាកសួរនៅសាលាដំបូងរាជធានីភ្នំពេញកាលពីម្សិលមិញថា គាត់ត្រូវបានសមាជិករណសិរ្សរំដោះជាតិខ្មែរស្នើសុំឲ្យដឹកសៀវភៅទាំងនោះ។ រណសិរ្សរំដោះជាតិខ្មែរ គឺជាក្រុមតស៊ូមតិផ្នែកនយោបាយគាំទ្រលទ្ធិប្រជាធិបតេយ្យ ដែលត្រូវបានលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ចាត់ទុកថា ជាអង្គការភេរវកម្ម។

គាត់បាននិយាយសំដៅដល់សៀវភៅ "អាថ៌កំបាំងនៃកម្ពុជា" ជាសៀវភៅប្រឆាំងគណបក្សប្រជាជនកម្ពុជា ដែលនិពន្ធដោយស្ថាបនិកក្រុមនេះថា "ខ្ញុំបានឆ្លងដែនតាមច្រកទ្វារព្រំដែនជាំសាងាំ នៅក្នុងស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ កាលពីសប្តាហ៍មុន ជាមួយសៀវភៅជាង២០០ក្បាលរបស់រណសិរ្សរំដោះជាតិខ្មែរ"។ គាត់បាននិយាយថា "គេឲ្យខ្ញុំចែកចាយសៀវភៅទាំងនេះនៅកម្ពុជា"។

លោក សំ សេរី ប្រធានរណសិរ្សរំដោះជាតិខ្មែររស់នៅក្នុងប្រទេសដាណឺម៉ាក ជាប្រទេសដែលគាត់បានទទួលសិទ្ធិជ្រកកោនផ្នែកនយោបាយ។ កាលពីខែមេសា គាត់និងសមាជិក១២នាក់ទៀតរបស់រណសិរ្សនេះត្រូវបានរកឃើញពិរុទ្ធភាពពីបទរៀបចំផែនការផ្តួលរំលំរដ្ឋាភិបាល ហើយត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារចន្លោះពីប្រាំឆ្នាំដល់ប្រាំបួនឆ្នាំ និងមានប្រាំពីរនាក់កំពុងជាប់ឃុំនៅពន្ធនាគារព្រៃស។

និយាយជាសាធារណៈជាលើកដំបូងចាប់តាំងពីការចាប់ខ្លួនគាត់មក លោក ចាន់ បាននិយាយកាលពីម្សិលមិញថា គាត់អាចឆ្លងដែនដោយគ្មានបញ្ហាឡើយ ប៉ុន្តែគាត់ត្រូវបានចាប់ខ្លួននៅទីក្រុងភ្នំពេញនៅពេលធ្វើដំណើរទៅផ្ទះម្តាយគាត់នៅក្នុងខេត្តកំពង់ស្ពឺ។

គាត់បាននិយាយថា "ខ្ញុំមានសៀវភៅរណសិរ្សរំដោះជាតិខ្មែរចំនួន២៥០ក្បាល នៅក្នុងតាក់ស៊ី ហើយនៅពេលដែលនគរបាលឆែកឆេរ នគរបាលបានចាប់ខ្លួនខ្ញុំនៅក្នុងសង្កាត់ជ្រោយចង្វាតែម្តង"។

គាត់បាននិយាយអំពីថ្ងៃដែលខ្មែរក្រហមដួលរលំថា "សៀវភៅទាំងនេះត្រូវបានបោះពុម្ពនៅក្នុងប្រទេសថៃ និងរៀបចំដោយរណសិរ្សរំដោះជាតិខ្មែរ។ ពួកគេបានឲ្យខ្ញុំយកសៀវភៅនេះមកកម្ពុជា ប៉ុន្តែខ្ញុំដឹងថា សៀវភៅដែលនិយាយអំពីរណសិរ្សរំដោះជាតិខ្មែរនេះគឺជាសៀវភៅប្រឆាំងគណបក្សប្រជាជនកម្ពុជា និងថ្ងៃ៧មករា"។ លោក ចាន់ បាននិយាយថា "ខ្ញុំមិនដឹងថាលិខិតឆ្លងដែននេះក្លែងក្លាយទេ។ រណសិរ្សរំដោះជាតិខ្មែរបានរៀបចំឲ្យខ្ញុំ ប៉ុន្តែឯកសារទាំងអស់ត្រូវបានបោះពុម្ពនៅក្នុងប្រទេសថៃ"។

ប៉ុន្តែចំពោះការចោទប្រកាន់ពីបទរៀបចំផែនការផ្តួលរំលំរដ្ឋាភិបាលជាបទឧក្រិដ្ឋដែលអាចមានទោសជាប់ពន្ធនាគាររហូតដល់១០ឆ្នាំនេះ លោក ចាន់ បាននិយាយថា គាត់គ្មានកំហុសទេ។ គាត់បាននិយាយថា "ឥឡូវនេះ គេបានបញ្ជូនខ្ញុំទៅឲ្យចៅក្រមស៊ើបសួរដើម្បីសាកសួរបន្ថែមទៀត ដោយគ្មានមេធាវីការពារ។ ខ្ញុំគ្មានទោសទេ"។

គេមិនអាចទាក់ទងលោក អ៊ឹម វណ្ណៈ ចៅក្រមស៊ើបសួរដើម្បីសុំអត្ថាធិប្បាយបានទេ។

លោក សេរី បាននិយាយតាមទូរស័ព្ទពីប្រទេសដាណឺម៉ាក កាលពីម្សិលមិញថា ក្រុមរបស់លោកមិនបានធ្វើលិខិតឆ្លងដែនក្លែងក្លាយទេ ហើយខ្ញុំក៏មិនបានឲ្យលោក ចាន់ ឆ្លងចូលមកកម្ពុជាដែរ។ គាត់បាននិយាយថា "អំពីលិខិតឆ្លងដែនក្លែងក្លាយនេះ យើងមិនដឹងរឿងនេះទេ។ រណសិរ្សរំដោះជាតិខ្មែរមិនមានគោលការណ៍ធ្វើឯកសារក្លែងក្លាយទេ។ លោក ចាន់ បានសម្រេចចិត្តវិលត្រឡប់មកកម្ពុជាដោយខ្លួនឯង ហើយបន្ទាប់ពីគាត់បានសម្រេចចិត្តរួចហើយ យើងបានឲ្យសៀវភៅគាត់ខ្លះ"។ លោក សេរី បាននិយាយថា លោកកំពុងរកមេធាវីឲ្យលោក ចាន់៕ ***គីមហឿន***

ខេមបូឌា ដេលី
The Cambodia Daily

មាតិកា

# មេខ្លោងក្នុងឃាតកម្មនៅថៃត្រូវបានបញ្ជូនទៅសាលាដំបូងរាជធានី

ដោយ ឆន ករុណា និង អ៊ុច សុនី | ថ្ងៃព្រហស្បតិ៍ ទី 16 ខែកុម្ភៈ ឆ្នាំ2017 |

READ IN ENGLISH

F T L E W

យោងតាមក្រុមមន្ត្រីបានឱ្យដឹងថា មេខ្លោងនៅពីក្រោយការសម្លាប់ពាណិជ្ជករជនជាតិអង់គ្លេសម្នាក់ក្នុងទីក្រុងរមណីយដ្ឋានប៉ាតាយ៉ា ប្រទេសថៃ ត្រូវបានចាប់ខ្លួនក្នុងប្រទេសកម្ពុជា ហើយត្រូវបានសាកសួរនៅសាលាដំបូងរាជធានីភ្នំពេញកាលពីម្សិលមិញ។

មន្ត្រីនគរបាលអន្តោប្រវេសន៍ម្នាក់ឈរនៅខាងក្រៅតុលាការដែលសុំមិនបញ្ចេញឈ្មោះ ពីព្រោះលោកមិនត្រូវបានអនុញ្ញាតឱ្យនិយាយជាមួយប្រព័ន្ធផ្សព្វផ្សាយនោះ បាននិយាយថា Toby Nelhams ដែលបានបញ្ជាឱ្យបាញ់សម្លាប់ Tony Kenway កាលពីថ្ងៃទី២៤ ខែមករា ត្រូវបានចាប់ខ្លួនកាលពីបីថ្ងៃមុននៅក្នុងខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ។



Toby Nelhams ជនជាតិអង់គ្លេសដែលជាមេខ្លោងនៅពីក្រោយការសម្លាប់ពាណិជ្ជករជនជាតិអង់គ្លេសម្នាក់ក្នុងទីក្រុងប៉ាតាយ៉ា ប្រទេសថៃ បង្ហាញខ្លួននៅតុលាការកាលពីម្សិលមិញ បន្ទាប់ពីត្រូវបានចាប់ខ្លួនក្នុងប្រទេសកម្ពុជា។ រូបថត: ស៊ី ចាន់ណា/ឌឹ ខេមបូឌា ដេលី

យោងតាមមន្ត្រីរូបនេះបានឱ្យដឹងថា មន្ត្រីរបស់យើងបានតាមដានបុរសជនជាតិអង់គ្លេសរូបនេះច្រើនសប្តាហ៍មកហើយ បន្ទាប់ពីទទួលបានព័ត៌មានពីអាជ្ញាធរថៃថា ជននេះស្ថិតក្នុងប្រទេសកម្ពុជា។ "យើងបានស៊ើបអង្កេតរយៈពេលប្រហែល១ខែ មុនឈានដល់ការចាប់ខ្លួននេះ"។

កាលពីថ្ងៃអាទិត្យ នគរបាលបានឱ្យដឹងថា ពួកគេមិនអាចបញ្ជាក់អះអាងពីរបាយការណ៍ចុះផ្សាយនៅក្នុងកាសែតបាងកកប៉ុស្តិ៍ដែលថា Nelhams អាយុ៤៤ឆ្នាំ ត្រូវបានចាប់ខ្លួនក្នុងប្រទេសកម្ពុជាបានឡើយ។ ប៉ុន្តែ កាលពីព្រឹកម្សិលមិញ Nelhams បានបង្ហាញខ្លួននៅតុលាការដែលត្រូវបានសាកសួរដោយព្រះរាជអាជ្ញារង សៀង សុខ។

ដោយសំដៅដល់ជនសង្ស័យពីរនាក់ទៀតដែលកំពុងតាមរកចាប់ខ្លួនពាក់ព័ន្ធករណីមនុស្សឃាតដែលគេជឿថា ក៏បានរត់គេចខ្លួនចូលមកក្នុងប្រទេសកម្ពុជាដែរនោះ មន្ត្រីនគរបាលអន្តោប្រវេសន៍រូបនេះបាននិយាយថា "ជននេះគឺជាមេខ្លោងនៅពីក្រោយករណីមនុស្សឃាតនេះ ហើយជនពីរនាក់ទៀតដែលជាជនដៃដល់ដែរនោះ មិនទាន់ត្រូវបានរកឃើញនៅឡើយទេ"។

អាជ្ញាធរបានឱ្យដឹងថា Abel Caldeira Bonito ជនជាតិអាហ្វ្រិកខាងត្បូងត្រូវគេសង្ស័យថា បានបាញ់សម្លាប់ Kenway ក្នុងរថយន្ត Porsche នៅខាងក្រៅក្លិបកីឡាមួយទាំងកណ្តាលថ្ងៃចំណែក Miles Dicken Turner ជនជាតិអង់គ្លេសជាអ្នកបើករថយន្តគេចខ្លួន។ នគរបាលក្រុងព្រះសីហនុបានអំពាវនាវឱ្យសាធារណជនជួយស្វែងរកបុរសទាំងពីរនាក់នេះកាលពីដើមខែនេះ ប៉ុន្តែនគរបាលព្រំដែនគ្រាន់តែបញ្ជាក់ថា Turner បានចូលមកក្នុងប្រទេសកម្ពុជាប៉ុណ្ណោះ។

Nelhams បានបដិសេធថា ខ្លួនមិនជាប់ពាក់ព័ន្ធក្នុងករណីមនុស្សឃាតនេះទេនៅពេលអ្នកយកព័ត៌មានសាកសួរនៅខាងក្រៅតុលាការកាលពីម្សិលមិញ។



Abel Caldeira Bonito និង Miles Dicken Turner ជាជនសង្ស័យក្នុងឃាតកម្មសម្លាប់បុរសជនជនជាតិអង់គ្លេសម្នាក់នៅប៉ាតាយ៉ា ប្រទេសថៃ នាខែមករា ក្នុងរូបថតផ្តល់ដោយប៉ូលិសថៃ។

លោក ឆៃ ស៊ីណារិទ្ធ អគ្គស្នងការរងនគរបាលជាតិ កាលពីម្សិលមិញបានបញ្ជាក់ថា ពិតជាមានការចាប់ខ្លួនជនជាតិអង់គ្លេសម្នាក់ដែលជាប់ពាក់ព័ន្ធករណីមនុស្សឃាតក្នុងប្រទេសថៃមែន ប៉ុន្តែក្រោយមកបានក្រឡាស់សម្តីរបស់ខ្លួន ដោយលើកឡើងថា លោកមិនច្បាស់ពីករណីនេះទេ។

លោក អ៊ុក ហៃសិលា ប្រធានផ្នែកស៊ើបអង្កេតនៅនាយកដ្ឋានអន្តោប្រវេសន៍នៃក្រសួងមហាផ្ទៃបានបញ្ជាក់ថា ជនជាតិអង់គ្លេសម្នាក់ត្រូវបានចាប់ខ្លួនមែន ប៉ុន្តែអះអាងថា ការចាប់ខ្លួននេះគឺដោយសារជននេះមិនមានលិខិតឆ្លងដែន។

យោងតាមលោក លី សុផាណា អ្នកនាំពាក្យ និងជាព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីបានឱ្យដឹងថា Nelhams មិនទាន់ត្រូវបានចោទប្រកាន់នៅឡើយទេរហូតមកដល់ល្ងាចម្សិលមិញនេះ។

លោកមានប្រសាសន៍ថា "អង្គហេតុដែលឈានដល់ការចាប់ខ្លួននេះគឺជាកម្មវត្ថុនៃការស៊ើបអង្កេតរបស់ព្រះរាជអាជ្ញាដែលត្រូវរក្សាការសម្ងាត់"។ ***សារុន***

© 2017, *ខេមបូឌា ដេលី*. *All rights reserved. No part of this article may be reproduced in print, electronically, broadcast, rewritten or redistributed without written permission.*

# ជនបរទេសដែលសង្ស័យធ្វើចារកម្មនៅកម្ពុជា ត្រូវតុលាការសម្រេចចោទប្រកាន់ជាផ្លូវការ ដែលអាចជាប់ពន្ធនាគារពី៥ ទៅ១០ឆ្នាំ តាមមាត្រា៤៤៦ នៃក្រមព្រហ្មទណ្ឌ

**(ភ្នំពេញ)៖** បុរសជនជាតិអូស្ត្រាលីម្នាក់ ឈ្មោះ James Ricketson ដែលសង្ស័យធ្វើចារកម្មនៅកម្ពុជា នៅថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១៧នេះ ត្រូវបានលោក សៀង សុខ ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ សម្រេចចោទប្រកាន់ពីបទ ប្រមូលផ្តុំព័ត៌មាន ជាអាទិ៍ដែលធ្វើឲ្យអន្តរាយការការពារជាតិ តាមមាត្រា៤៤៦ នៃក្រមព្រហ្មទណ្ឌ។

ចំពោះបទចោទប្រកាន់នេះ ជនបរទេសជាប់ចោទ នឹងត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ)ឆ្នាំ ទៅ១០ (ដប់)ឆ្នាំតាមមាត្រាខាងលើ។

ជនសង្ស័យបានធ្វើចារកម្មនៅកម្ពុជា នាអំឡុងពេលឃោសនារកសំឡេងឆ្នោត ពោលជននេះបានធ្វើសកម្មភាពដោយគ្មានការជូនដំណឹង និងគ្មានការអនុញ្ញាតពីសមត្ថកិច្ចនោះទេ ហើយត្រូវបានកម្លាំងនគរបាល នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ បានឃាត់ខ្លួននៅថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៧ កន្លងទៅ។

បុរសជនជាតិអូស្ត្រាលីម្នាក់នេះ បានចូលក្នុងប្រទេសកម្ពុជា ធ្វើសកម្មភាពលួចយកព័ត៌មាននានា ពិសេសព័ត៌មានពាក់ព័ន្ធនឹងការឃោសនាបោះឆ្នោត ដើម្បីយកទៅផ្សព្វផ្សាយនៅក្រៅប្រទេស ដោយគ្មានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច និងព្យាយាមបិទបាំងអត្តសញ្ញាណ កន្លែងស្នាក់នៅ និងលិខិតឆ្លងដែនរបស់ខ្លួនថែមទៀតផង៕




# សាលាដំបូងខេត្តរតនគិរី សម្រេចឃុំខ្លួនជនជាតិវៀតណាម៨នាក់ រឿងចូលកាប់ឈើខុសច្បាប់



**ខេត្តរតនគិរី៖** សាលាដំបូងខេត្តរតនគិរី កាលពីថ្ងៃទី២១ មីនា ម្សិលមិញ បានសម្រេចឃុំខ្លួនបុរសជនជាតិវៀតណាមចំនួន៨នាក់ ក្នុងសំណុំរឿងឆ្លងដែនចូលមកកាប់ឈើ ក្នុងដែនដីខេត្តរតនគិរី ដោយខុសច្បាប់។

លោក កែវ ពិសិដ្ឋ អ្នកនាំពាក្យសាលាដំបូងខេត្តរតនគិរី បានថ្លែងប្រាប់ក្រុមអ្នក រាយការណ៍ព័ត៌មានថា បុរសជនជាតិវៀតណាមទាំងនោះ ត្រូវបានចោទប្រកាន់ចំនួន៣បទល្មើស ក្នុងនោះរួមមាន ទី១.ចូលព្រះរាជាណាចក្រកម្ពុជា ដោយគ្មានការអនុញ្ញាត ទី២.ប្រើប្រាស់គ្រឿងចក្របម្រើឲ្យការប្រមូលផល-អនុផលព្រៃឈើ ដោយគ្មានលិខិតអនុញ្ញាត និង៣ទី.ប្រើប្រាស់វណាយន្តគ្រប់ប្រភេទ ដែលបម្រើឲ្យការប្រមូលផល-អនុផលព្រៃឈើ ដោយគ្មានលិខិតអនុញ្ញាត។

គួរបញ្ជាក់ថា ក្រុមជនល្មើសដែលជាជនជាតិវៀតណាមទាំងនោះ ត្រូវបានកម្លាំងនគរបាលអន្តោប្រវេសន៍ នៃស្នងការដ្ឋាននគរបាលខេត្តរតនគិរី ចាប់ខ្លួនកាលពីថ្ងៃទី១៨ មីនា ឆ្នាំ២០១៧ ខណៈដែលពួកគេកំពុងធ្វើសកម្មភាពកាប់ឈើ នៅចំណុចតំបន់ព្រំប្រទល់៣ស្រុក គឺស្រុកអូរយ៉ាដាវ, ស្រុកបរកែវ និងស្រុកអណ្ដូងមាស។

យ៉ាងណាក៏ដោយក្រុមប្រជាពលរដ្ឋបានបង្ហើបថា បុរសជនជាតិវៀតណាមទាំងនោះជាផ្នែកមួយ នៃកកម្មករកាប់ឈើជនជាតិវៀតណាមជាច្រើនទៀត ដែលត្រូវបានឈ្មួញឈើក្នុងស្រុកជួលមក៕

ភ្នំពេញ ប៉ុស្តិ៍




# សមត្ថកិច្ចសម្រេចចោទប្រកាន់អ្នកនេសាទវៀតណាម ១៦ នាក់

22 Mar, 2017- ឃុត សុភចរិយា



**កំពត:** អ្នកនេសាទជាតិវៀតណាម ១៦ នាក់ត្រូវបានរដ្ឋបាលជលផលខេត្តកំពតចោទពីបទ «ប្រើឧបករណ៍អួនអូសត្វ» ដោយផ្អែកតាមមាត្រា ៩៨ នៃច្បាប់ជលផលកម្ពុជា ប៉ុន្តែបើតាមមាត្រានេះពួកគេនឹងមិនត្រូវបានឃុំខ្លួន ឬផ្តន្ទាទោសឲ្យជាប់ពន្ធនាគារទេ។ នេះបើតាមលោក សរ សុរិន្ទ នាយខណ្ឌរដ្ឋបាលជលផលខេត្តពីម្សិលមិញ។

លោក សុរិន្ទ បានបញ្ជាក់ថា៖ «តាមច្បាប់ស្តីពីជលផលនៃព្រះរាជាណាចក្រកម្ពុជាយើងមាត្រា ៩៨ ចំណុចទី ១ កំហុសរបស់ពួកគេពុំធ្ងន់ធ្ងរហួតដល់ឃុំខ្លួន ឬផ្តន្ទាទោសទេគឺគ្រាន់តែធ្វើការណែនាំ និងផាកពិន័យអន្តរកាលតាមច្បាប់ស្តីពីជលផលប៉ុណ្ណោះ។ មានន័យថាពួកគេត្រូវបង់ពិន័យជាប្រាក់ពីមួយដងទៅពីរដងលើតម្លៃទីផ្សារនៃវត្ថុតាងពិតប្រាកដ»។

លោកបានឲ្យដឹងថាពេលនេះមន្ត្រីជំនាញបានកសាងសំណុំរឿងបញ្ជូនទៅរដ្ឋបាលជលផលថ្នាក់ជាតិដើម្បីពិនិត្យ និងសម្រេចខណៈពួកគេមិនត្រូវបានអនុញ្ញាតឲ្យចេញពីទូកមកលើគោក។

ពួកគេនឹងត្រូវបញ្ជូនទៅខេត្តគៀងយ៉ាង ប្រទេសវៀតណាមវិញក្រោយបង់ពិន័យអន្តរកាលតាមការសម្រេចពីរដ្ឋបាលជលផលថ្នាក់ជាតិ។

បើតាមការអះអាងរបស់លោក សុរិន្ទ អ្នកនេសាទជនជាតិវៀតណាមទាំងនោះត្រូវបានកម្លាំងរដ្ឋបាលជលផលខេត្តកំពតបង្ក្រាបបានកាលពីយប់ថ្ងៃចន្ទ ខណៈពួកគេកំពុងនេសាទត្រីខុសច្បាប់ក្នុងដែនសមុទ្រកម្ពុជានៅចំណុចខាងមុខកំពង់ផែវេញហូរចម្ងាយប្រមាណ ២ គីឡូម៉ែត្រក្នុងភូមិតិឡូ ១២ ឃុំព្រែកអម្ពិល ស្រុកទឹកឈូ ខេត្តកំពត។

ក្នុងប្រតិបត្តិការនាយប់នោះសមត្ថកិច្ចបានរឹបអូសទូកនេសាទ ៣ គ្រឿងក្នុងចំណោមទូកនេសាទចំនួន ៤ គ្រឿងដែលបានលួចឆ្លងចូលមកនេសាទក្នុងដែនទឹកសមុទ្រកម្ពុជារួមទាំងឧបករណ៍នេសាទអួនអូសត្វមួយចំនួនផងដែរ។

The Phnom Penh Post
back up ↑
Post Media Co Ltd

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
=======

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**
=======

**ស្ថានតំណាងកម្ពុជាប្រចាំប្រទេសវៀតណាម សម្របសម្រួលជួយដល់ពលករខ្មែរ ១៧នាក់**

* * * * * *

ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសវៀតណាម បានរាយការណ៍ជូនក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ថាមានពលករខ្មែរចំនួន **១៧នាក់** ដូចខាងក្រោម ត្រូវបាននគរបាលសមុទ្រវៀតណាមឃាត់ខ្លួន កាលពីថ្ងៃទី ២១ ខែឧសភា ឆ្នាំ២០១៧ ក្នុងពេលឃាត់នាវារបស់ថៃ ០៣គ្រឿង (VOR LUCKY, BPP3, HAKUYO MARU) និងនាវានេសាទវៀតណាម ០៤គ្រឿង ដែលកំពុងធ្វើសកម្មភាពជួញដូរ និងដឹកជញ្ជូនប្រេងខុសច្បាប់ នៅក្នុងដែនសមុទ្រវៀតណាម។ បច្ចុប្បន្នពលករខ្មែរទាំង១៧នាក់ កំពុងត្រូវបានឃុំខ្លួនបណ្តោះអាសន្ននៅលើកោះ Phu Quoc ខេត្ត Kien Giang ប្រទេសវៀតណាម។

| | | |
|---|---|---|
| ១. ឈ្មោះ ស្វា | អាយុ ៣០ឆ្នាំ | មកពីខេត្តសៀមរាប |
| ២. ឈ្មោះ ប៊ុន | អាយុ ៣៥ឆ្នាំ | មកពីខេត្តសៀមរាប |
| ៣. ឈ្មោះ សុជា | អាយុ ២៤ឆ្នាំ | មកពីខេត្តសៀមរាប |
| ៤. ឈ្មោះ ទូល | អាយុ ២៣ឆ្នាំ | មកពីខេត្តសៀមរាប |
| ៥. ឈ្មោះ ចិន វិន | អាយុ ២៥ឆ្នាំ | មកពីខេត្តសៀមរាប |
| ៦. ឈ្មោះ អ៊ុំ វុធ | អាយុ ៣៥ឆ្នាំ | មកពីខេត្តសៀមរាប |
| ៧. ឈ្មោះ កេង ហឿ | អាយុ ៣៤ឆ្នាំ | មកពីខេត្តសៀមរាប |
| ៨. ឈ្មោះ ឡឿង គី | អាយុ ២៦ឆ្នាំ | មកពីខេត្តសៀមរាប |
| ៩. ឈ្មោះ គង់ រ៉ា | អាយុ ២៤ឆ្នាំ | មកពីខេត្តសៀមរាប |
| ១០. ឈ្មោះ ហុង សុភាព | អាយុ ៣០ឆ្នាំ | មកពីខេត្តសៀមរាប |
| ១១. ឈ្មោះ ផាត | អាយុ ២៥ឆ្នាំ | មកពីខេត្តសៀមរាប |
| ១២. ឈ្មោះ សួល | អាយុ ៥០ឆ្នាំ | មកពីខេត្តកំពង់ធំ |
| ១៣. ឈ្មោះ សៀត | អាយុ ១៨ឆ្នាំ | មកពីខេត្តកំពង់ធំ |
| ១៤. ឈ្មោះ វៀម | អាយុ ២៥ឆ្នាំ | មកពីខេត្តកំពង់ធំ |
| ១៥. ឈ្មោះ អេង ធួល | អាយុ ២៣ឆ្នាំ | មកពីខេត្តកំពង់ចាម |
| ១៦. ឈ្មោះ ធាត | អាយុ ៣៥ឆ្នាំ | មកពីខេត្តកំពង់ចាម |
| ១៧. ឈ្មោះ គា ធី | អាយុ ៣៨ឆ្នាំ | មកពីខេត្តកោះកុង |

ក្រោយទទួលបានដំណឹងពីការឃាត់ខ្លួននេះ ស្ថានទូតបានជូនដំណឹង និងស្នើស្ថានអគ្គកុងស៊ុលកម្ពុជាប្រចាំទីក្រុងហូជីមិញ ចុះទៅជួបសួរសុខទុក្ខពលករខ្មែរទាំង ១៧នាក់ និងសម្របសម្រួលជាមួយអាជ្ញាធរវៀតណាម ដើម្បីរៀបចំមាតុភូមិនិវត្តន៍ពួកគាត់មកកម្ពុជាវិញ។

ភ្នំពេញ, ថ្ងៃទី៣១ ខែ ឧសភា ឆ្នាំ ២០១៧
**ជុំ សុន្ទរី**
**អ្នកនាំពាក្យ**
ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ